**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of law and Economics

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិជនជាប់ឃុំនៅកម្ពុជា

ស្រាវជ្រាវថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **លោក រ៉េត សៀនី**

**កញ្ញា តាំង អ៊ី**

សាស្ត្រាចារ្យណែនាំ

លោក **រុន ពណ្ណារិទ្ធ**


**ថ្នាក់បរិញ្ញាបត្រផ្នែក នីតិសាស្ត្រ**

**ជំនាន់ទី ២២**

**ឆ្នាំចូលសិក្សា ២០១៨**

**ឆ្នាំសរសេរសារណា ២០២២**

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **វ៉េត សៀនី** និងឈ្មោះ **តាំង អ៊ី** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី២២ **ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ**នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណ និងសំដែងនូវកតញ្ញូតាធម៌ចំពោះ**

| | |
|---|---|
| លោកឪពុក **ព្រហ្ម ស៊ីណា** | លោកឪពុក **សុខ គី** |
| អ្នកម្តាយ **ហួត សៀក** | អ្នកម្តាយ **តាំង មួយ** |

ជាកិច្ចបឋមកូនៗសូមឱនកាយថ្វាយបង្គំប្រណិបតន៍ និងសម្តែងនូវកត្តញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់ចំពោះអ្នកមានគុណទាំងបួនដែលបានផ្តល់នូវកំណើតចិញ្ចឹមបីបាច់ថែរក្សាខិតខំលះបង់កម្លាំងកាយ និងកម្លាំងចិត្តព្រមទាំងសម្ភារៈសព្វបែបយ៉ាងក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនៗទាំងអស់ដោយដៃផ្ទាល់ជាមួយ និងក្តីស្រលាញ់ប្រកបដោយព្រហ្មវិហារធម៌ចាប់តាំងពីកំណើត រហូតដល់កូនបានធំពេញវ័យ និងថែមទាំងបានជួយឧបត្ថម្ភដល់កូនទទួលបានការអប់រំ ចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។ ហើយពេលនេះរូបកូនទាំងពីរនាក់ក៏ជិតបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រក្នុងរយៈពេលដ៏ខ្លីខាងមុននេះ។ លទ្ធផលដែលទទួលបានកន្លងមក និងរួមទាំងការជិតឈានដល់ការបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សាទាំងអស់នេះ គឺកើតចេញពីកម្លាំងញើសឈាមរបស់លោកអ្នកមានគុណទាំងបួនក្នុងការតស៊ូជម្នះនូវភាពលំបាកគ្រប់បែបយ៉ាងដើម្បីអោយកូនៗបានសម្រេចនូវក្តីស្រម៉ៃរបស់ខ្លួនទៅថ្ងៃអនាគត់។

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ** ទាំងអស់ដែលបង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយពន្យល់ និងផ្តល់ការអប់រំល្អៗ កាលពីឆ្នាំសិក្សាកន្លងទៅ។

ជាពិសេសយើងខ្ញុំក៏សូមថ្លែងអំណរគុណដ៏ឧត្តុងឧត្តមចំពោះ**លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណានេះចំពោះប្រធានបទ **សិទ្ធិជនជាប់ឃុំនៅកម្ពុជា** ដោយលោកសាស្ត្រាចារ្យបានចំណាយពេលដ៏មានតម្លៃដើម្បីជួយផ្តល់ជាគំនិតយោបល់ល្អៗ រហូតសម្រេចបានលទ្ធផលគួរជាទីពេញចិត្ត។

ជាចុងបញ្ចាប់យើងខ្ញុំទាំងអស់គ្នាសូមប្រសិទ្ធិពរជ័យជូនមាតាបិតា លោកសាស្ត្រាចារ្យ សូមឱ្យមានសុខភាពល្អ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ដោយកាលពីឆ្នាំកន្លងទៅ យើងខ្ញុំធ្លាប់បានសិក្សាអំពីសិទ្ធិនានាដែលសាលាបានរៀបចំ និងបានសិក្សាអំពីច្បាប់នានាដែលមានចែងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ មួយចំនួន និងយល់ឃើញថាសិទ្ធិមនុស្សគឺមានសារៈសំខាន់ណាស់មិនថាស្ថិតនៅទីណា ឬក្នុងដំណាក់កាលណានោះទេ គឺត្រូវតែទទួលបានសិទ្ធិគ្រប់ពេលវេលា ជាពិសេសគឺការអនុវត្តចំពោះជនជាប់ឃុំ។ ក្នុងរយៈកាលចុងក្រោយនេះសង្កេតឃើញថាការអនុវត្តការការពារសិទ្ធិមនុស្ស និងសិទ្ធិជនជាប់ឃុំនៅកម្ពុជាមួយចំនួនមានភាពល្អប្រសើជាមុន ប៉ុន្តែក្នុងនោះយើងឃើញថាចំនុចមួយចំនួនមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយនោះទេពោល គឺមានភាពខ្វះចន្លោះមិនទាន់បានពេញលេលេញនោះទេ។ ហេតុដូចនេះយើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តជ្រើសរើសយកនូវប្រធានបទ **"សិទ្ធិជនជាប់ឃុំនៅកម្ពុជា"** នេះមកស្រាវជ្រាវសរសេរចងក្រងជាសារណាបញ្ចប់ការសិក្សា។ សារណានេះគឺមានគោលបំណងអោយអ្នកសិក្សាក៏ដូចជាពលរដ្ឋទាំងអស់បានស្វែងយល់អំពីសិទ្ធិរបស់ខ្លួនដែលមាននៅពេលជាប់ឃុំនៅក្នុងដំណើរការនីតិវិធីរបស់តុលាការនិងដើម្បីជៀសវាងនូវការរំលោភបំពានសិទ្ធិពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នតុលាការឬទីកន្លែងឃុំឃាំង។

យើងខ្ញុំទាំងពីរនាក់សូមអភ័យទោសជាមុនចំពោះការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំដែលបានចងក្រងជាសារណានេះប្រាកដជាមានចំណុចខ្វះចន្លោះមិនទាន់គ្រប់គ្រាន់នៅត្រង់ចំណុចណាមួយជាមិនខានឡើយ ប៉ុន្តែក្រុមខ្ញុំរីករាយនិងទទួលយកការរិះគន់ដើម្បីស្ថាបនាពីសំណាក់អ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យមិត្តរួមជំនាន់និងប្អូនៗជំនាន់ក្រោយរាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនា នូវពាក្យពេចន៍ វគ្គ ឃ្លា វេយ្យាករណ៍ ទាំងផ្នែកខ្លឹមសារ អក្ខរាវិរុទ្ធ និងវិធីសាស្ត្រក្នុងការសរសេរ។

សូមអ្នកសិក្សាក៏ដូចជានិស្សិតមេត្តាអភ័យទោសនូវរាល់កំហុសឆ្គងរបស់យើងខ្ញុំទាំងពីរនាក់ និងសូមមិត្តនិស្សិត ធ្វើការសិក្សាស្រាវជ្រាវបន្ថែមដើម្បីបំពេញចំណុចខ្វះខាត់របស់ពួកយើងខ្ញុំទាំងពីរនាក់ និងដើម្បីទុកជាឯកសារដល់អ្នកមិត្តនិស្សិត

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ............ ១

**ជំពូកទី១**

**សិទ្ធិ និងភាតព្វកិច្ចទូទៅ របស់ជនជាប់ឃុំ នៅក្នុងពន្ធនាគារ**

**ផ្នែកទី១៖ សិទ្ធិ របស់ជនជាប់ឃុំ** ............ ៣

១. ជនជាប់ឃុំទាំងអស់មានសិទ្ធិទទួលបានការការពារសិទ្ធិមនុស្ស ............ ៣

២. សិទ្ធិទទួលបានផ្នែកសេវាសុខាភិបាល ............ ៣

៣. សិទ្ធិរក្សាទុក និងប្រើប្រាស់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ............ ៥

៤. សិទ្ធិចូលរួមកម្មវិធីសិក្សាអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ............ ៥

៥. សិទ្ធិទទួលបានការប្រាស្រ័យទាក់ទង និងទទួលព័ត៌មាន ............ ៦

៦. សិទ្ធិទទួលបានការសួរសុខទុកពីក្រុមគ្រួសារ និងមិត្តភក្តិ ............ ៦

៧. សិទ្ធិក្នុងការគោរពសាសនា ............ ៧

៨. សិទ្ធិរួចផុតពីការធ្វើទារុណកម្ម ............ ៨

៩. សិទ្ធិរួចផុតពីការដាក់ខ្នោះ ............ ៩

១០. សិទ្ធិជនជាប់ឃុំជាអនីតិជន ............ ១០

១០.១ការរក្សាអនីតិជន ............ ១០

១០.២ បញ្ជីឈ្មោះអនីតិជន ............ ១១

១០.៣ សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ឃុំជាអនីតិជន. ............ ១១

១០.៤ សិទ្ធិទទួលបានការបែងចែងការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ............ ១២

១០.៥ សិទ្ធិទទួលបានសេវាសម្រាប់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ............ ១២

១០.៦ សិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌ ............ ១៣

១១. យន្តការក្នុងការលើកកម្ពស់ចំពោះសិទ្ធជនជាប់ឃុំ ............ ១៣

១២. វិធានអង្គការសហប្រជាជាតិសម្រាប់ប្រព្រឹត្តកម្មលើសិទ្ធិជនជាប់ឃុំជាស្ត្រី ............ ២០

១២.១ សេវាថែទាំសុខភាព ............ ២០

១២.២ ការត្រួតពិនិត្យសុខភាពពេលចូលពន្ធនាគារ ............ ២១

១២.៣ ការទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅ ............ ២៣

១២.៤ ជនជាប់ឃុំជាអនីតិជនស្ត្រី ............ ២៣

១២.៥ ស្ត្រីមានគភ៌ម្តាយបំបៅកូនដោយទឹកដោះនិងម្តាយរស់នៅជាមួយកូនក្នុងពន្ធនាគារ .. ២៣
១២.៦ ជនជាប់ឃុំបរទេស.......................................................................................២៤
១២.៧ ជនដែលត្រូវគេចាប់ខ្លួនឬរងចាំសវនាការជំនុំជម្រះទោស ...................................២៥
**ផ្នែកទី២៖ ភាតព្វកិច្ចរបស់ជនជាប់ឃុំ**.......................................................២៦
១. ការគោរពបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ.......................................................២៦
២. កាតព្វកិច្ចតាមវិធានការណ៍ត្រួតពិនិត្យ.............................................................២៦
៣. កាតព្វកិច្ចដោយឡែក ..................................................................................២៧
៤. កាតព្វកិច្ចមិនលួចរត់.....................................................................................២៧
៥. កាតព្វកិច្ចមិនរក្សាទុកនិងមិនប្រើប្រាស់គ្រឿងញៀនគ្រឿងស្រវឹង ..........................២៨

## ជំពូកទី២

## សិទ្ធិទទួលបានការលើកលែងទោស និងបន្ធូបន្ថយទោស

១. សិទ្ធិទទួលបានការលើកលែងទោសនិងបន្ធូបន្ថយទោស ...........................................២៩
២. លក្ខខណ្ឌសម្រាប់ធ្វើការលើកលែងទោសនិងបន្ធូបន្ថយទោស.....................................៣១
៣. រយៈពេលនៃការបន្ធូបន្ថយទោស........................................................................៣២
៤. ថ្ងៃសម្រាប់ធ្វើការលើកលែងទោសនិងបន្ធូរបន្ថយទោស............................................៣២
៥. បែបបទស្នើសុំការលើកលែងទោសនិងបន្ធូបន្ថយទោស............................................៣៣

## ជំពូកទី៣

## ការអនុវត្តសិទ្ធិជនជាប់ឃុំក្នុងដំណាក់កាលសវនាការ

**ផ្នែកទី១៖ សិទ្ធិរបស់ជនជាប់ឃុំមុនពេលសវនាការ**.............................................៣៤
១. សិទ្ធិជនជាប់ចោទមុនពេលចាប់ខ្លួន..................................................................៣៤
១.១ សិទ្ធិទទួលដំណឹងពីបទចោទ......................................................................៣៥
១.២ សិទ្ធិដឹងពីមូលហេតុនៃការចាប់ខ្លួន.............................................................៣៥
១.៣ សិទ្ធិបង្ហាញខ្លួនចំពោះមុខចៅក្រម ..............................................................៣៥
២. សិទ្ធិការពារខ្លួននៅពេលចាប់ខ្លួន...................................................................៣៦
៣. សិទ្ធិដឹងពន្ធនូវភស្តុតាងនិងព័ត៌មាន..................................................................៣៦
៤. សិទ្ធិជនជាប់ចោទក្នុងដំណាក់កាលឃុំខ្លួនបណ្តោះអាសន្ន.......................................៣៧
៥. សិទ្ធិទទួលបានការជំនុំជំរះដោយមិនពន្យាពេលយូរ ...............................................៣៧
៦. សិទ្ធិបង្ហាញភស្តុតាង.......................................................................................៣៨

៧. សិទ្ធិមិនត្រូវបានគេបង្ខំឱ្យឆ្លើយ ឬ សារភាពដាក់បន្ទុកមកលើខ្លួន ....................................៣៨
៨. សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម ...........................................................................៣៩
៩. សិទ្ធិជ្រើសរើសមេធាវី................................................................................................៤០
១០. សិទ្ធិប្រាស្រ័យជាមួយសាច់ញាតិ ...........................................................................៤១
**ផ្នែកទី២៖ សិទ្ធិជនជាប់ឃុំនៅពេលសវនាការ** ..........................................................៤២
១. សិទ្ធិការពារខ្លួនក្នុងពេលសវនាការ...............................................................................៤២
២. សិទ្ធិទទួលបានការជំនុំជំរះដោយយុត្តិធម៌ ....................................................................៤២
៣. សិទ្ធិទទួលបានការជំនុំជំរះដោយសាធារណៈ..................................................................៤៤
៤. សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះ .............................................................................៤៥
៥. សិទ្ធិមានអ្នកបកប្រែ....................................................................................................៤៦
៦. សិទ្ធិសុំធ្វើការផ្លាស់ប្តូរមេធាវី ......................................................................................៤៦
៧. សិទ្ធិឆ្លើយសំណួររបស់ចៅក្រមដោយគ្មានវត្តមានពីមេធាវី..................................................៤៧
៨. សិទ្ធិជនជាប់ចោទជាអនីតិជនក្នុងពេលសវនាការ ..........................................................៤៨
**ផ្នែកទី៣៖ សិទ្ធិជនជាប់ចោទក្រោយពេលសវនាការ** .....................................៤៩
១. បណ្តឹងទាស់................................................................................................................៤៩
២. បណ្តឹងឧទ្ធរណ៍ .............................................................................................................៥០
៣. បណ្តឹងសាទុក្ខ ...............................................................................................................៥១
**សេចក្តីសន្និដ្ឋាន** .........................................................................................................៥៣
**អនុសាសន៍**.................................................................................................................៥៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. មូលហេតុនៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជាមានការផ្លាស់ប្តូរសម័យការ និងរបបនយោបាយជាច្រើន ក្នុងការផ្លាស់ប្តូរសម័យការ និង របបនយោបាយនោះដែរគឺតែងតែមានចែងច្បាប់ដើម្បីការពារ និងគ្រប់គ្រងក្នុងរបបរបស់ខ្លួនហើយច្បាប់ទាំងនោះគឺស្របទៅតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល និងគោរពទៅលើសិទ្ធិប្រជាពលរដ្ឋដែលរស់នៅសង្គមបច្ចុប្បន្ន។ យើងក្រឡេកទៅមើល នៅក្នុងសម័យកាលនៃរបបខ្មៅងងឹត គឺរបបកម្ពុជាប្រជាធិបតេយ្យ ការអនុវត្តសិទ្ធិផ្ទុយខុសពីច្បាប់ ការអនុវត្តបំពានទៅនិងរដ្ឋធម្មនុញ្ញរបស់ខ្លួនទាំងស្រុងមិនបានការពារទៅលើសិទ្ធិមនុស្សនោះទេ ថែមទាំងបានបំពានទៅលើសិទ្ធិមនុស្សទាំងស្រុង ដែរមានការបំបាត់សិទ្ធិក្នុងការនិយាយស្តី សិទ្ធិក្នុងរស់នៅ សិទ្ធិក្នុងការដើរហើរ និងជាពិសេសគឺសិទ្ធិរស់រានមានជីវិតដែលជាសិទ្ធិចំបងរបស់មនុស្សពោលគឺមនុស្សទាំងអស់គ្មានសិទ្ធិតវ៉ាគ្រប់បញ្ហាដែលកើតមានឡើង ដែលបានធ្វើអោយបាត់បង់ជីវិតមនុស្សជាង២លាននាក់។ បន្ទាប់ពីរបបមួយនោះបានដួលរលំ មកដល់របបគ្រប់គ្រងក្រោយៗមកច្បាប់មានការវិវត្តន៍ដែលមនុស្សទាំងអស់មានសិទ្ធិស្មើៗគ្នាដោយមិនគិតពីពណ៌សម្បុរ ឬជាតិសាសន៍ដទៃទៀតពោលគឺមានសិទ្ធិស្មើគ្នាទាំងអស់ ព្រមទាំងមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ទៀតផង ចំពោះសិទ្ធិក្នុងផ្លូវច្បាប់នេះគឺបានន័យថាប្រជាពលរដ្ឋទាំងអស់មានសិទ្ធិទទួលបានការការពារតាមផ្លូវច្បាប់ និងសិទ្ធិក្នុងការកាត់ក្តីតាមផ្លូវតុលាការទៅតាមផ្លូវច្បាប់ដូចគ្នា ដោយមិនមានជនណាម្នាក់ត្រូវបានរំលោភបំពានចំពោះសិទ្ធិរបស់ខ្លួនឡើយ ទាំងសិទ្ធិនៅក្នុងដំណាក់កាលចាប់ខ្លួន និងដំណាក់កាលឃុំខ្លួន។ សិទ្ធិរបស់មនុស្សត្រូវទទួលបានការពារគ្រប់កន្លែងមិនត្រឹមតែប៉ុណ្ណោះច្បាប់ក៏បានការពារសិទ្ធិទៅលើជនជាប់ឃុំគឺការពារយ៉ាងខ្លាំងមិនត្រឹមច្បាប់ជាតិនោះទេ សិទ្ធិនេះផងដែរក៏ត្រូវបានការពារពីអង្គការសហប្រជាជាតិផងដែរ ។

ចំពោះច្បាប់ជាតិ និងច្បាប់អន្តរជាតិ តាក់តែងឡើងដើម្បីគ្រប់គ្រងទៅលើបទល្មើសផ្សេងៗ ដើម្បីការពារដល់សន្តិសុខប្រជាពលរដ្ឋរបស់ខ្លួន ក៏ដូចជាសង្គមប្រជាជាតិទាំងមូល។ ដូចគ្នានេះដែរនៅក្នុងច្បាប់នៃប្រទេសកម្ពុជាក៏ បានចែងការពារទៅលើជនដែលត្រូវបានជាប់ឃុំផងដែរ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ដូចដែលបានរៀបរាប់ខាងលើបានបង្ហាញឱ្យឃើញថា សិទ្ធិរបស់ជនជាប់ឃុំនៅពន្ធនាគារ ក៏មានការការពារពីច្បាប់ផងដែរ គ្រាន់តែសិទ្ធិមួយចំនួនរបស់ពួកគេត្រូវបានដកហូត ជាបណ្តោះអាសន្ន ដូចជាសិទ្ធិសេរីភាពក្នុងការដើរហើរជាដើម។ ដូចនេះដើម្បីជាចង្កៀងបំភ្លឺផ្លូវ ក្នុងការបកស្រាយនូវសិទ្ធិទាំងឡាយរបស់ជនជាប់ឃុំនៅកម្ពុជា ក្នុងនាមជាអ្នកអានគួរគប្បីយល់ដឹងពីចំណោទបញ្ហាដែលបានចោទឡើងថា :

**តើសិទ្ធិនិងកាតព្វកិច្ចជនជាប់ឃុំនៅកម្ពុជាមានអ្វីខ្លះ? ម៉្យាងទៀត តើជនជាប់ឃុំទាំងនោះ មានសិទ្ធិ**

**ទទួលបាននូវការលើកលែងទោស និងបន្ធូបន្ថយទោសក្នុងករណីណាខ្លះ? ជាពិសេស សិទ្ធិនៅមុនពេលសវនាការ ក្នុងពេលសវនាការ និងក្រោយពេលសវនាការ អាចជួយដល់ជនជាប់ឃុំក្នុងការសម្រាលទោស ឬ ធ្វើការប្រឆាំងតបតបានដែរ ឬទេ?**

## ៣. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចាប់ផ្ដើមពីការជ្រើសរើសប្រធានបទ ការស្រាវជ្រាវរកឯកសារដែរពាក់ព័ន្ធ រហូតដល់ការសរសេរសារណានេះឡើង គឺក្នុងគោលបំណងធ្វើការរៀបរាប់ឱ្យកាន់តែលំអិត ពាក់ព័ន្ធនិងប្រធានបទមួយនេះ។ ជាពិសេស សិទ្ធិដែលជាប់ពាក់ព័ន្ធទៅនិងជនជាប់ឃុំក្នុងពន្ធនាគារ។ ចំពោះការស្រាវជ្រាវទៅលើប្រធានបទមួយនះ បានផ្អែកទៅលើបញ្ញត្តិច្បាប់ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ច្បាប់ស្ដីពីពន្ធនាគារ និងច្បាប់ផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធទៅនិងជនជាប់ឃុំក្នុងពន្ធនាគារ។ ក្នុងនោះដែរ ក៏មានការចូលរួមពីសំណាក់សាស្ត្រាចារ្យលោកគ្រូ អ្នកគ្រូ ក្នុងការជួយជ្រោមជ្រែង ផ្ដល់គំនិត យោបល់ល្អៗ និងចង្អុលបង្ហាញទិសដៅដល់សិស្សក្នុងការស្រាវជ្រាវឱ្យចំគោលដៅ។ ក្នុងនោះដែរ ការសិក្សាទៅលើប្រធានបទមួយនេះ បានធ្វើឱ្យខ្ញុំផ្ទាល់ ក៏ដូចជាមិត្តរួមក្រុម មានការយល់ដឹងកាន់តែច្បាស់ ពាក់ព័ន្ធនិង ក្រមនីតិវិធីព្រហ្មទណ្ឌ ផ្ដើមពីការចាប់ផ្ដើម រហូតដល់បញ្ចប់។ ចំពោះការស្រាវជ្រាវក្រុមយើងខ្ញុំបានលើកយកច្បាប់ដែលជាប់ពាក់ព័ន្ធជាច្រើនក៏ដូចជាមាត្រាសម្រាប់បកស្រាយលម្អិតឱ្យកាន់តែស៊ីជម្រៅផងដែរ ។

## ៤. សារៈសំខាន់នៃប្រធានបទ

កន្លងមកយើងតែងតែឃើញសៀវភៅ បោះពុម្ព ទាក់ទងនិងសិទ្ធិផ្សេងៗជាច្រើន។ ប៉ុន្តែយើងកម្រឃើញគេនិយាយបកស្រាយលម្អិតពាក់ព័ន្ធនិងសិទ្ធិរបស់ជនជាប់ឃុំនោះណាស់។ ហេតុដូចនេះបានជាក្រុមខ្ញុំសម្រេចជ្រើសរើសប្រធានបទសិទ្ធិជនជាប់ឃុំនៅកម្ពុជា មកបកស្រាយលម្អិត។ ដោយសារបុគ្គលមួយចំនួនតូចនៅក្នុងសង្គមមានការយល់ដឹងពុំស៊ីជម្រៅ គួបផ្សំនិងប្រទេសកម្ពុជាយើងស្ថិតនៅក្នុងស្ថានភាពកំពុងអភិវឌ្ឍន៍ ជាពិសេសពាក់ព័ន្ធនិងផ្លូវច្បាប់ក៏នៅមានកម្រិត ទោះបុគ្គលទាំងនោះពុំបានប្រព្រឹត្តអំពើដែលនាំផលវិបាកដល់សង្គមក៏ពួកគេគួរតែចូលរួមក្នុងការស្វែងយល់ពាក់ព័ន្ធនិងច្បាប់នានា ជាពិសេ សអំពីសិទ្ធិនេះផងដែរ។

# ជំពូកទី១

# សិទ្ធិ និងភារកិច្ចទូទៅ របស់ជនជាប់ឃុំ នៅក្នុងពន្ធនាគារ

# ជំពូកទី១

# សិទ្ធិ និងភាតព្វកិច្ចទូទៅ របស់ជនជាប់ឃុំនៅក្នុងពន្ធនាគារ

## ផ្នែកទី១៖ សិទ្ធិ របស់ជនជាប់ឃុំ

### ១. ជនជាប់ឃុំទាំងអស់មានសិទ្ធិទទួលបានការការពារសិទ្ធិមនុស្ស

ការឃុំខ្លួន ឬការដាក់ពន្ធនាគារទៅលើជនណាម្នាក់មិនមែនមានន័យថា ជនទាំងនោះត្រូវបានដកហូតសិទ្ធិមនុស្សទាំងស្រុងនោះទេ បើទោះបីជាជននោះត្រូវបានតុលាការចេញសេចក្តីសម្រេចផ្តន្ទាទោស ឬជនទាំងនោះជាប់ចោទមានពិរុទ្ធភាពពីបទល្មើសក្នុងកម្រិតធ្ងន់យ៉ាងណាក៏ដោយ។ សិទ្ធិមនុស្សត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កតិកាសសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ អង្គការសហប្រជាជាតិ តុលាការ ឬទីភ្នាក់ងារដទៃទៀតដែលមានតួនាទី ដោះស្រាយករណីរបស់ជនជាប់ឃុំបានសម្រេចដកហូតសេរីភាពពីជនទាំងនោះ ប៉ុន្តែមិនបានដកហូតសិទ្ធិរបស់ពួកគេទាំងស្រុងឡើយ។ ការអនុវត្តសិទ្ធិមនុស្សគឺអនុវត្តដោយមិនប្រកាន់ជាតិសាសន៍ ភេទ សាសនា ពណ៌សម្បុរ ឬទីកន្លែងណាមួយឡើយ ជនគ្រប់រូបត្រូវទទួលបានការការពារសិទ្ធិស្មើៗគ្នា សិទ្ធិទាំងនោះរួមមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួនសិទ្ធិរួចផុតពីការធ្វើទារុណកម្មជាដើម។ ទោសប្រហារជីវិតមិនត្រូវមានឡើយ[1]គ្មានជនណាម្នាក់ត្រូវបានដកហូតសិទ្ធិដោយបំពានឡើយ។

### ២. សិទ្ធិទទួលបានផ្នែកសេវាសុខាភិបាល

ជនជាប់ឃុំមានសិទ្ធិទទួលបានសេវាថែទាំសុខភាពជាប្រចាំដោយមន្ត្រីពេទ្យពន្ធនាគារ។ ក្នុងករណីដែលជនជាប់ឃុំមានជម្ងឺធ្ងន់ដែលតម្រូវឱ្យមានការសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យខាងក្រៅ ប្រធានពន្ធនាគារត្រូវបញ្ជូនអ្នកជម្ងឺទៅមន្ទីរពេទ្យជាបន្ទាន់តាមសំណើរមន្ត្រីពេទ្យពន្ធនាគារ ហើយត្រូវជូនដំណឹងដល់អគ្គនាយកនៃអគ្គនាយកដ្ឋាន អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ចត្រូវជូនដំណឹងដល់គ្រួសារសាច់ញាតិ ឬមិត្តភក្តិជិតស្និទ្ធបំផុតតាមសំណើរបស់ជនជាប់ឃុំ។

មណ្ឌលអប់រំកែប្រែ និងពន្ធនាគាររបស់កម្ពុជានាពេលបច្ចុប្បន្នមានជនជាប់ឃុំជាច្រើនដែលកំពុងជួបប្រទះ និងបញ្ហាសុខភាពដែលបញ្ហានេះបណ្តាលមកពីកត្តាជាច្រើន ប៉ុន្តែក្នុងនោះយើងសង្កេតឃើញថាមានកត្តាពីរជាសំខាន់គឺ **កត្តាបរិយាកាស** និង**កត្តាបរិស្ថាន** ។

- **បរិយាកាស៖** នៅក្នុងបន្ទប់ពន្ធនាគារនៅប្រទេសកម្ពុជាភាគច្រើនគឺផ្ទុកជនជាប់ឃុំលើសចំនួនដោយសារចំនួនជាប់ឃុំចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំឥតឈប់ឈរធ្វើឱ្យ

[1] មាត្រា ៣២ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

ពន្ធនាគារខ្លះមានជនជាប់ឃុំលើសទ្វេដង។ បន្ទប់ពន្ធនាគារដែលមានជនជាប់ឃុំច្រើន នេះហើយដែលបណ្តាលឱ្យបរិយាកាសនៃការរស់នៅរបស់ជនជាប់ឃុំមានការលំបាកដែលជួបប្រទះទៅនិងបញ្ហាខ្យល់ដកដង្ហើម បញ្ហាអនាម័យក្នុងការរស់នៅផងដែរ។

- **បរិស្ថានៈ** ចំពោះបញ្ហានេះវិញគឺជាបញ្ហាធំដែលកើតមានផងដែរដូចជា កង្វះទឹកស្អាតបរិភោគមិនគ្រប់គ្រាន់ជាដើម ។

ចំពោះបញ្ហាទាំងពីរខាងលើកំពុងតែប្រឈមយ៉ាងខ្លាំងនៅក្នុងពន្ធនាគារដែលធ្វើឱ្យជនជាប់ឃុំចេះតែមានជម្ងឺញឹកញាប់ ហើយចំពោះប្រភេទជម្ងឺដែលបានកើតមានឡើងនៅក្នុងមណ្ឌលអប់រំកែប្រែក៏ ដូចជាពន្ធនាគារគឺមានដូចជា ផ្តាសាយ រាគ គ្រុនក្តៅ របេង ជម្ងឺផ្លូវចិត្ត ជម្ងឺលើសឈាម ឈឺក្រពះ រមាស់ រោគស្ត្រីជាដើម។ បញ្ហាទាំងអស់ខាងលើយើងសង្កេតឃើញថារដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ដោយបានបង្កើតប៉ុស្តិ៍សុខភាព ឬអាគារសុខាភិបាលនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ ដើម្បីព្យាបាល និងថែទាំសុខភាពដល់ជនជាប់ឃុំ ។

ចំពោះការព្យាបាលជម្ងឺនៅពន្ធនាគារ គឺ ពន្ធនាគារមានអាគារសុខាភិបាលមួយសម្រាប់ទទួលអ្នកជម្ងឺដែលជាជនជាប់ឃុំ។ ក៏ប៉ុន្តែទោះបីជាមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារមានអាគារសុខាភិបាលសម្រាប់មើលថែរក្សាអ្នកជម្ងឺពិតមែន តែការព្យាបាល គឺមិនបាន១០០ភាគរយនោះទេដោយសារតែ មណ្ឌលអប់រំកែប្រែ ឬពន្ធនាគារគ្មានឱសថគ្រប់គ្រាន់ អាគារសម្រាកព្យាបាលកំណត់ចំនួនអ្នកជម្ងឺ។ ដោយសារតែបញ្ហានេះ មណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ បានចុះអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយមន្ទីរពេទ្យមួយចំនួនផងដែរដើម្បីនៅពេលដែលពន្ធនាគារគ្មានលទ្ធភាពក្នុងការព្យាបាល ឬ ពេលដែលអ្នកជម្ងឺមានលក្ខណៈធ្ងន់ធ្ងរ ឬត្រូវការវះកាត់ជាដើម។ ចំពោះការថែទាំអ្នកជម្ងឺវិញក៏មិនសូវបានដិតដល់ដែរដោយសារបញ្ហាដូចដែលបានរៀបរាប់ខាងលើ គឺការកង្វះទាំងសម្ភារៈ និងឱសថសម្រាប់ព្យាបាល។ ការកង្វះខាតបែបនេះធ្វើឱ្យអង្គការសប្បុរសធម៌ដែលមិនមែន ជាអង្គការរបស់រដ្ឋាភិបាល បានចុះជួយព្យាបាលជនជាប់ឃុំ។ ក្រៅពីអង្គការដែលបានជួយក៏មានមន្ត្រីពន្ធនាគារក៏បានខ្នះខ្នែងជួយទំនុកបម្រុង ផងដែរគឺមន្ត្រីទាំងនោះបានធ្វើកំណត់ហេតុជម្ងឺរបស់ជនជាប់ឃុំចូលថ្មី ប្រសិនបើពិនិត្យឃើញថា បើជននោះមានជម្ងឺត្រូវដាក់ដាច់ដោយឡែកពីជនជាប់ឃុំដើម្បីងាយស្រួលក្នុងការថែទាំនិងព្យាបាលហើយបង្ការកុំឱ្យឆ្លងទៅអ្នកដទៃបាន។

មន្ត្រីពន្ធនាគារចុះទៅពន្យល់ណែនាំជនជាប់ឃុំពីបញ្ហាអនាម័យ និងការថែទាំសុខភាព បញ្ជូនចេញទៅក្រៅ ( **ទៅមន្ទីរពេទ្យដែលចុះ MOU ជាមួយ**) ក្នុងករណីមានជម្ងឺធ្ងន់ធ្ងរ ។

### ❖ ជនជាប់ឃុំជាស្ត្រី

ការអនុវត្តសិទ្ធិចំពោះជនជាប់ឃុំជាស្ត្រីត្រូវបានផ្តល់សេវាគាំពារយ៉ាងយកចិត្តទុកដាក់ ទៅលើមាតា

និងទារកនៅមុន និងក្រោយពេលសម្រាលកូន។ ជនជាប់ឃុំជាស្ត្រីដែលមានផ្ទៃពោះ ត្រូវបានអនុញ្ញាតឱ្យសម្រាលកូននៅមន្ទីពេទ្យខាងក្រៅ ។

### ៣. សិទ្ធិរក្សាទុក និងប្រើប្រាស់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន

ជនជាប់ឃុំអាចត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ថវិកាផ្ទាល់ខ្លួនដើម្បីទិញសម្ភារៈប្រើប្រាស់ឬទទួលសម្ភារៈប្រើប្រាស់ពីក្រុមគ្រួសារ ញាតិមិត្ត ឬពីប្រភពផ្សេងៗទៀតប្រសិនបើមានការយល់ព្រម និងការត្រួតពិនិត្យពីប្រធានពន្ធនាគារ។ ជនជាប់ឃុំ មិនត្រូវបានអនុញ្ញាតឱ្យទិញ ឬផ្តល់ ឬឱ្យខ្ចី ឬលក់សម្ភារៈទៅឱ្យជនជាប់ឃុំផ្សេងទៀតបានឡើយ។ ថវិកាទ្រព្យសម្បត្តិមានតម្លៃជាប់ខ្លួនរបស់ជនជាប់ឃុំ ត្រូវកត់ត្រាឱ្យបានត្រឹមត្រូវក្នុងសៀវភៅបញ្ជី និងរក្សាទុកក្នុងគណនីពន្ធនាគារ។ ក្រោយពេលដែលជនជាប់ឃុំត្រូវបានដោះលែងថវិកា ឬទ្រព្យសម្បត្តិមានតម្លៃទាំងនោះ ត្រូវប្រគល់ ឱ្យជននោះវិញ។ ហើយជនជាប់ឃុំក៏មានសិទ្ធិរក្សាទុកឱសថដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនបានដែរបើមានការយល់ព្រមពីមន្ត្រីពន្ធនាគារ។ ថវិកាទ្រព្យសម្បត្តិមានតម្លៃជាប់ខ្លួនរបស់ជនជាប់ឃុំត្រូវបានដកហូតកត់ត្រាត្រឹមត្រូវក្នុងសៀវភៅបញ្ជី និងរក្សាទុកក្នុងគណនីពន្ធនាគារ ឬត្រូវប្រគល់ជូនក្រុមគ្រួសារញាតិមិត្តរក្សាទុកប្រសិនបើមានការយល់ព្រមពីជនជាប់ឃុំដោយត្រូវមានហត្ថលេខាឬស្នាមម្រាមដៃរបស់ជនជាប់ឃុំ ក្នុងករណីចាំបាច់និងមានការយល់ព្រមពីប្រធានពន្ធនាគារជនជាប់ឃុំអាចប្រើប្រាស់ថវិកាបញ្ញើរបស់ខ្លួនបាន។

### ៤. សិទ្ធិចូលរួមកម្មវិធីសិក្សាអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ទណ្ឌិតត្រូវបានផ្តល់មធ្យោបាយដើម្បីចូលរួមកម្មវិធីសិក្សាចំណេះដឹងទូទៅ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ។ កម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ត្រូវបានធ្វើសមាហរណកម្ម ជាមួយប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ជាតិ ត្រូវសហការជាមួយក្រសួងមហាផ្ទៃរៀបចំកម្មវិធី និងដំណើរការអនុវត្តកម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិតនៅក្នុងពន្ធនាគារ ។

ទណ្ឌិតជាអនីតិជនត្រូវបានយកចិត្តទុកដាក់ដោយឡែកទាក់ទង និងតម្រូវការសិក្សាអប់រំការបណ្តុះបណ្តាលវិជ្ជាជីវៈ ការស្តារនីតិសម្បទា និងសមាហរណកម្មដោយសហការជាមួយក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា ។

កម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវបានរៀបចំឡើងនៅតាមពន្ធនាគារនីមួយៗដើម្បីផ្តល់ឱកាសឱ្យទណ្ឌិតមានសមត្ថភាពប្រកបមុខរបរចិញ្ចឹមជីវិត នៅពេលធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ[2]។

---

[2] មាត្រា៦៩ នៃច្បាប់ស្តីពីពន្ធនាគារដែលប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

គ្រប់ពន្ធនាគារទាំងអស់ដែលមានក្នុងព្រះរាជាណាចក្រកម្ពុជាសុទ្ធតែបង្កើតអោយមានមុខជំនាញសម្រាប់ផ្តល់ចំណេះដឹងដល់ទណ្ឌិតស្របពេលពួកគេកំពុងអនុវត្តទោស និងទទួលការអប់រំកែប្រែជាប្រចាំពីក្រុមអនុរក្សតាមរយៈអង្គការជាដៃគូជាច្រើនបានចូលរួមបង្ហាត់បង្រៀន។ មុខជំនាញដែលទទួលបានការបណ្តុះបណ្តាលក្នុងពន្ធនាគារ មានដូចជា ស្ត្រី ទទួលបានការបណ្តុះបណ្តាលផ្នែកសំអាង ដោយឡែកចំពោះប្រុសៗវិញ ទទួលបានការបណ្តុះបណ្តាលផ្នែកម៉ាស៊ីនត្រជាក់ តបណ្តាញចរន្តអគ្គីសនី ជំនាញជួសជុលម៉ូតូ វិធីដាំដុះផ្នែកកសិកម្ម ការចិញ្ចឹមសត្វ និងមុខជំនាញផ្សេងៗទៀតជាច្រើន។ ការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈក្នុងពេលកំពុងអនុវត្តទោសនេះក្នុងគោលបំណង ឱ្យទណ្ឌិតក្រោយពេលអនុវត្តទោសចប់មានជំនាញសម្រាប់ចិញ្ចឹមជីវិតតទៅថ្ងៃមុខ ។

ចំពោះអនីតិជនដែលមានអាយុលើសពីអាយុដែលត្រូវចូលរៀន ដែលប្រាថ្នាចង់បន្តការអប់រំរបស់គេគួរបានអនុញ្ញាត និងលើកទឹកចិត្តឱ្យបន្តការអប់រំ ហើយគួរប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីផ្តល់សិទ្ធិដល់ពួកគេបានទទួលកម្មវិធីអប់រំសមស្រប។ សញ្ញាប័ត្រឬវិញ្ញាបនប័ត្រអប់រំ ដែលផ្តល់អោយអនីតិជននៅពេលជាប់ឃុំឃាំងមិនត្រូវបញ្ជាក់អ្វីទាំងអស់ ដែលបង្ហាញថា អនីតិជននោះបានជាប់ក្នុងស្ថានភាពឃុំឃាំង។ ទីន្លែងឃុំឃាំងទាំងអស់ គួរផ្តល់ឱកាសដល់អនីតិជនបានចូលអានឯកសារក្នុងបណ្ណាល័យ ដែលមានសៀវភៅគ្រប់គ្រាន់ផ្នែកសិក្សា និងផ្នែកកំសាន្ត ព្រមទាំងមានទស្សនាវដ្តីសមស្របសំរាប់អនីតិជនដែលត្រូវបានលើកទឹកចិត្ត និងធ្វើឱ្យអនីតិជននោះប្រើប្រាស់បណ្ណាល័យនោះឱ្យបានជាប្រយោជន៍ដោយបរិបូណ៌។ អនីតិជនគ្រប់រូបមានសិទ្ធិទទួលការហ្វឹកហ្វឺនវិជ្ជាជីវៈនៅក្នុងមុខរបរទាំងឡាយ ដែលទំនងជារៀបចំខ្លួន អនីតិជននោះសំរាប់ការងារក្នុងពេលអនាគត់។ដោយមានការយកចិត្តទុកដាក់ខ្ពស់ដល់ការជ្រើសរើសត្រឹមត្រូវខាងវិជ្ជាជីវៈនិងដល់សេចក្តីតម្រូវរបស់រដ្ឋបាលស្ថាប័នឃុំឃាំងអនីតិជនត្រូវតែអាចជ្រើសរើសប្រភេទនៃការងារដែលគេចង់ធ្វើ។

### ៥. សិទ្ធិទទួលបានការប្រាស្រ័យទាក់ទង និងការទទួលព័ត៌មាន

ជនជាប់ឃុំមានសិទ្ធិទាក់ទង ឬទទួលនិងផ្ញើលិខិតឆ្លើយឆ្លងជាមួយក្រុមគ្រួសារ ឬ ញាតិមិត្តរបស់ខ្លួននិងមេធាវី ការទាក់ទងជាមួយមេធាវីត្រូវធ្វើឡើងដោយសម្ងាត់។ ជនជាប់ឃុំត្រូវបានអនុញ្ញាតឱ្យទទួលដំណឹងឬព័ត៌មានសំខាន់ៗ តាមរយៈកម្មវិធីផ្សព្វផ្សាយរបស់វិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន។ ជនជាប់ឃុំអាចអនុញ្ញាតឱ្យចូលសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យ ពន្ធនាគារ ឬអាចអនុញ្ញាតឱ្យខ្ចីសៀវភៅ យកទៅស្រាវជ្រាវ នៅក្នុងបន្ទប់ឃុំឃាំងដើម្បីបង្កើនចំណេះដឹង។ ពន្ធនាគារត្រូវជូនដំណឹងទាក់ទងនិងជម្ងឺ ឬមរណភាពរបស់ជនជាប់ឃុំ ឬរបស់គ្រួសារជនជាប់ឃុំ ឱ្យបានដឹងទៅវិញទៅមក។ ជនជាប់ឃុំមានសិទ្ធិជួបក្រុមគ្រួសារ ញាតិមិត្តិ និងមេធាវី របស់ខ្លួនដោយសម្ងាត់ ។

### ៦. សិទ្ធិទទួលបានការសួរសុខទុកពីក្រុមគ្រួសារ និងមិត្តភក្តិ

ការអនុញ្ញាត អោយក្រុមគ្រួសារមកសួរសុខទុក្ខជាសិទ្ធិមួយដែលអនុញ្ញាតដោយច្បាប់ ដោយការផ្តល់សិទ្ធិបែបនេះក្នុងគោលបំណងដើម្បីកុំអោយជនដែលជាប់ឃុំមានសម្ពាធ និងភាពឯកកា ដោយគិតថាត្រូវបានគេបោះបង់ចោល។ ជនជាប់ឃុំត្រូវបានអនុញ្ញាតឱ្យគ្រួសារ ឬញាតិមិត្តមកសួរសុខទុក្ខតាមការកំណត់ លើកលែងតែមានការហាមឃាត់ពីអាជ្ញាធរតុលាការ។ អ្នកដែលត្រូវបញ្ជូនចូលក្នុងពន្ធនាគារទោះបីជាបាត់បង់សិទ្ធិដើរទៅណាមកណាដោយសេរីក៏ពិតមែន។ ប៉ុន្តែសិទ្ធិមួយចំនួនក្នុងចំណោមសិទ្ធិសំខាន់ៗទាំងអស់នោះគឺសិទ្ធិទាក់ទងជាមួយនឹងក្រុមគ្រួសាររបស់ខ្លួននៅតែអាចអនុវត្តន៍បាន ហើយសមាជិកគ្រួសាររបស់ជនជាប់ឃុំក៏មានសិទ្ធិចូលជួបជាមួយជនជាប់ឃុំដែលជាប់ក្នុងពន្ធនាគារដែរ។ ពោលគឺសមាជិកគ្រួសារនិងមិត្តភក្តិមានសិទ្ធិចូលសួរសុខទុកជនជាប់ឃុំក្នុងពន្ធនាគារបាន។ ហើយការសួរសុខទុកទាំងនោះត្រូវបានធ្វើឡើងដោយលក្ខណៈធម្មតាបំផុត នៅពេលមានលក្ខខណ្ឌអំណោយផល។ ការសួរសុខទុកគួរធ្វើឡើងជាលក្ខណៈឯកជន តាមដែលអាចធ្វើបាន។ គ្រប់ពេលទាំងអស់ គេពុំគួរភ្លេចគិតថា ការសួរសុខទុកជាមួយគ្រួសារដែលជិតស្និទ្ធបំផុតមិនត្រូវចាត់ទុកជាបុព្វសិទ្ធិ ជាជាងសិទ្ធិមនុស្សជាមូលដ្ឋាននោះទេ។ ប្រធានពន្ធនាគារ ត្រូវបិទផ្សាយជាសាធារណៈ នូវពេលវេលា និងរយៈពេលសួរសុខទុក្ខ ដែលមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ។ លិខិតឆ្លើយឆ្លងរបស់ជនជាប់ឃុំ ត្រូវបានដកហូត ប្រសិន បើមានការពាក់ព័ន្ធដល់សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ទូទៅ ទាំងក្នុង និងក្រៅពន្ធនាគារ ។

## ៧. សិទ្ធិក្នុងការគោរពសាសនា

១.ប្រសិនបើនៅក្នុងពន្ធនាគារណាមួយ មានជនជាប់ឃុំដែលគោរពសាសនាដូចគ្នាច្រើនគ្រប់គ្រាន់ត្រូវតែងតាំងឬយល់ព្រមឱ្យមានតំណាងសាសនាដែលមានគុណសម្បត្តិគ្រប់គ្រាន់ម្នាក់សម្រាប់សេចក្តីត្រូវការរបស់ជនជាប់ឃុំទាំងនោះ។ ប្រសិនបើកាលៈទេសៈតម្រូវនិងអនុលោមតាមចំនួនជនជាប់ឃុំផងនោះ ការចាត់ចែងខាងលើត្រូវធ្វើឡើងក្នុងលក្ខណៈពេញម៉ោង ។

២.អ្នកតំណាងសាសនាដែលត្រូវបានតែងតាំងឬយល់ព្រមស្របតាមកថាខណ្ឌ១ ខាងលើត្រូវបានអនុញ្ញាតឱ្យធ្វើការបានទៀងទាត់ និងជួយប្រៀនប្រដៅជនជាប់ឃុំតាមមាគ៌ាសាសនារបស់ជនជាប់ឃុំទៅតាមពេលវេលាដ៏សមគួរ។

៣. មិនត្រូវហាមឃាត់ជនជាប់ឃុំមិនឱ្យជួបអ្នកតំណាងសាសនារបស់ពួកគេឡើយ។ ផ្ទុយទៅវិញ ប្រសិន បើជនជាប់ឃុំណាម្នាក់ពុំមានឆន្ទៈចង់ជួបអ្នកតំណាងសាសនាទេ នោះគេត្រូវគោរពតាមឆន្ទៈរបស់ជនជាប់ឃុំជានិច្ច។

បើអនុវត្តទៅបាន ជនជាប់ឃុំគ្រប់រូបត្រូវតែបានអនុញ្ញាតិ ដើម្បីបំពេញនូវសេចក្តីត្រូវការនៃជីវិត ខាងផ្លូវសាសនារបស់គេតាមរយៈការចូលរួមក្នុងពិធីផ្សេងៗ ដែលអនុញ្ញាតិឱ្យមាននៅក្នុងពន្ធនាគារ និងអនុញ្ញាតិ

ឱ្យរក្សាទុកនូវឯកសារ ឬសៀវភៅនានាដែលស្តីពីការប្រៀនប្រដៅ និងការគោរពបូជាតាមមាគ៌ានៃនិកាយសាសនារបស់គេ។ ការផ្តល់សិទ្ធិក្នុងការគោរពសាសនា ដល់ជនជាប់ឃុំក៏ជាផ្នែកមួយដែលក្នុងការអប់រំផ្លូវចិត្តរបស់ពួកគេ អាចធ្វើអោយវិន័យផ្លូវចិត្តកាន់តែល្អប្រសើ និងធ្វើអោយចិត្តគំនិតរបស់ពួកគេមានការកែប្រែមកជាល្អប្រសើរិញផងដែរ ព្រោះថាការអប់រំបែបសាសនាជាផ្នែកមួយដែលសំខាន់ដល់មនុស្សគ្រប់រូបឱ្យគិតល្អ និងប្រព្រឹត្តល្អ។

### ៨. សិទ្ធិរួចផុតពីទណ្ឌកម្ម

បន្ទាប់ពីបញ្ចប់សង្គ្រាមលោកលើកទី១ និងទី២ទើបពិភពលោកទាំងមូលបានងាកមករកការគោពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរ របស់មនុស្ស ហើយបានបង្កើតស្ថាប័នកំពូលមួយរបស់ពិភពលោកគឺអង្គការសហប្រជាជាតិ ដើម្បីការពារសិទ្ធិមនុស្ស និងផលប្រយោជន៍របស់ពិភពលោក។ ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣របស់កម្ពុជា បានចែកការពារអំពីសិទ្ធិរបស់ជនដែលត្រូវបានជាប់ឃុំដូចជា មិនឱ្យមានការរំលោភបំពានលើរូបកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនឱ្យធ្វើឡើយ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់។ ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ[3]។

ក្នុងឆ្នាំ១៩៤៥ស្ថាប័ននេះក៏បានចេញសេចក្តីប្រកាសជាសកលមួយស្តីពីសិទ្ធិមនុស្សត្រង់មាត្រា៥ចែងថា គ្មានជនណាម្នាក់ត្រូវបានទទួលរងទារុណកម្ម ឬទណ្ឌកម្ម ឬ ប្រព្រឹត្តិកម្មកាចសាហាវ ឥតមនុស្សធម៌ ឬថោកទាបបានឡើយ។ មួយវិញទៀតកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦ មាត្រា៧ ចែងថាគ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬការប្រព្រឹត្តទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឱ្យថោកទាបបានឡើយ។ យោងតាមមាត្រា៥ និងមាត្រា៧ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនិងកតិកាសញ្ញាអន្តរជាតិស្តីពិសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដូច្នេះមនុស្សជាតិទាំងអស់មិនថាជនជាប់សង្ស័យ ជនជាប់ចោទពិរុទ្ធជន ឬទណ្ឌិតឡើយសុទ្ធតែអាចជៀសផុតពីការធ្វើទារុណ កម្ម ឬទណ្ឌកម្ម ឬអំពើណាមួយដែលអាចនាំឱ្យប៉ះពាល់នូវសេចក្តីថ្លៃថ្នូរបស់ខ្លួនបានថែមទៀតផងដែរ។ ជាពិសេសក្នុងព្រះរាជក្រមលេខ នស រកម ១២១១ ០២១ ច្បាប់ស្តីពន្ធនាគារ ដែលប្រកាសឱ្យនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១១ មាត្រា៥៣ ចែងថា ការធ្វើទារុណកម្មមកលើរាងកាយគ្រប់រូបភាព ការឃុំខ្លួនក្នុងបន្ទប់ងងឹត ការកាត់បន្ថយម្ហូប

[3] មាត្រា៣៨ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

អាហារការដាក់ទណ្ឌកម្មជាសមូហភាពដល់ជនជាប់ឃុំ និងការប្រើប្រាស់ជនជាប់ឃុំឱ្យធ្វើទារុណកម្មជនជាប់ឃុំដូចគ្នាត្រូវហាមឃាត់។ ហើយថែមទាំងបានផ្តន្ទាទោសដោយមានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាទៅលើជនណាដែលបានធ្វើទារុណកម្មអំពើឃោរឃៅ និងរាល់ទម្រង់ផ្សេងៗទៀតនៃការរំលោភបំពានដែលប្រព្រឹត្តទៅលើជនជាប់ឃុំ[4] ។

លិខិតតុបករណ៍ស្តីពីសិទ្ធិមនុស្សអន្តរជាតិ មិនមានចែងដោយបន្សល់ទុកនូវភាពមន្ទិលសង្ស័យ ឬភាពមិនច្បាស់លាស់ណាមួយទាក់ទងនិងការធ្វើទារុណកម្ម និងការធ្វើបាបឡើយ។ លិខិតតុបរណ៍នេះចែងយ៉ាងច្បាស់ថា ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយមិនអាចទទួលយកហេតុផលណាមួយក្នុងការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតក្នុងរបៀបមួយដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។ ទារុណកម្មមានន័យថា ទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្តដែលបង្កឡើងដោយចេតនាលើជនណាម្នាក់ ក្រោយពីការឈឺចាប់ ឬរងទុក្ខដែលកើតមានក្នុងកន្លែងឃុំខ្លួនឬ ពន្ធនាគារ។ មិនអាចទទួលយល់ហេតុផលណាមួយសម្រាប់ការធ្វើទារុណកម្មឡើយទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។

ការហាមឃាត់ក្នុងការធ្វើទារុណកម្ម គឺជារឿងចាំបាច់ ជាពិសេសនៅទីកន្លែងសួរចម្លើយ ឬស៊ើបអង្កេតដោយហេតុថាអាចមានការប៉ុនប៉ងគំរាមគំហែងណាមួយដើម្បីទទួលបានព័តមានសំខាន់ៗសម្រាប់ដោះស្រាយសំណុំរឿងព្រហ្មទណ្ឌ។

### ៩. សិទ្ធិរួចផុតពីការដាក់ខ្នោះ

ការដាក់ខ្នោះដល់ជនជាប់ឃុំមិនត្រូវកើតមានឡើយ ព្រោះថាការដាក់ខ្នោះគឺបានធ្វើអោយប៉ះពាល់ដល់សិទ្ធិមនុស្សជាខ្លាំង។ ជាទូទៅការដាក់ខ្នោះគឺគេប្រើទៅជនដែលកំពុងចាប់ខ្លួន នៅក្នុងដំណាក់កាលនគរបាលយុត្តិធម៌ និងជនដែលត្រូវបានបញ្ជូនទៅតុលាការធ្វើការជំនុំជម្រះ នៅក្នុងនីតិវិធីជំនុំជម្រះប៉ុណ្ណោះ ។ ក៏ប៉ុន្តែក្នុងពេលឃុំឃាំង នៅក្នុងបន្ទប់ពន្ធនាគារមិនអនុញ្ញាតឱ្យប្រើប្រាស់ខ្នោះដៃសម្រាប់ធ្វើការដាក់ទណ្ឌកម្មចំពោះជនជាប់ឃុំបានឡើយ។ ការប្រើប្រាស់ខ្នោះដៃចំពោះជនជាប់ឃុំបានលើកលែងតែក្នុងករណីដូចខាងក្រោម ៖

- ពេលមានចលាចលក្នុងពន្ធនាគារ
- ពេលផ្ទេរ ឬបញ្ជូន ឬនាំខ្លួនចេញពីពន្ធនាគារ
- ពេលមានហេតុផលខាងពេទ្យ

[4] មាត្រា៨១ នៃច្បាប់ស្តីពីពន្ធនាគារដែលប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

- ដើម្បីការពារជនជាប់ឃុំកុំឱ្យបង្ករបួសស្នាមដោយខ្លួនឯង ឬបង្ករបួសស្នាមដល់អ្នកដទៃ ឬបង្កការខូចខាតទ្រព្យសម្បត្តិអ្នកដទៃ[5]។

## ១០. សិទ្ធិជនជាប់ឃុំជាអនីតិជន

នៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជាបានបញ្ញាត្តិអំពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺអាយុចាប់ពី ១៨ឆ្នាំឡើងទៅ។ តែក្នុងច្បាប់ព្រហ្មទណ្ឌដដែលក៏បានបញ្ញាតិអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលមានអាយុចាប់ពី១៤ឆ្នាំឡើងដល់ក្រោម១៨ឆ្នាំផងដែរតុលាការអាចប្រកាសជាប្រភេទវិធានការសម្រាប់អនីតិជនដូចដែលបានចែងក្នុងមាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ វិធានទាំងនោះមានដូចជា វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដែលវិធានការទាំងនោះមានផលប្រយោជន៍ទៅដល់អនីតិជន។ ក្នុងនោះដែលតុលាការក៏អាចប្រកាសទោសដាក់ពន្ធនាគារចំពោះអនីតិជនបានដែល ក្នុងកាលៈទេសៈដែលបទល្មើសរបស់អនីតិជនបានប្រព្រឹត្តនោះជាលក្ខណៈធ្ងន់ធ្ងរព្យសនកម្មនៃបទល្មើសមានទំហំ។ ទន្ទឹមនិងនេះដែរច្បាប់ក៏បានការពារចំពោះអនីតិជនដែលត្រូវបានឃុំខ្លួនផងដែរ ចំពោះការឃុំខ្លួនអនីតិជននេះផងដែលធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទាជាអាទិ៍ការបណ្តុះបណ្តាលការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឱ្យក្លាយទៅជាពលរដ្ឋសុចរិក និងមានប្រយោជន៍ដល់សង្គមជាតិ។ មន្ត្រីមណ្ឌលយុវនីតិសម្បទាដែលទទួលបន្ទុកគ្រប់គ្រងអនីតិជន ត្រូវទទួលបន្ទុកបណ្តុះបណ្តាលអំពីចិត្តសាស្ត្រ សុខុមាលភាព បទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនិងកុមារ និងវិធានការសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព។

### ១០.១ ការរក្សាអនីតិជន

**អនីតិជនត្រូវបានថែរក្សាក្នុងមណ្ឌលយុវនីតសម្បទាដូចជា ៖**

អនីតិជនជាប្រភេទជនដែលត្រូវបានការពារអំពីសិទ្ធិដែលច្បាប់បានកំណត់ឱ្យបានពេញលេញបំផុតដែលនិងត្រូវអនុវត្តចំពោះអនីតិជនដែលត្រូវបានជាប់ឃុំផងដែរ និងមានដូចជា៖

- អនីតិជនត្រូវដាក់ដោយឡែកពីនីតិជន
- នៅក្នុងអគារដាច់ដោយឡែកទៅតាមភេទផ្សេងគ្នាតាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិក សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន អនីតិជនភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា ។
- នៅក្នុងអាគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកសម្រាប់អនីតិជនដែលមានជំងឺឆ្លង ។

[5] មាត្រា៥០ នៃច្បាប់ស្តីពីពន្ធនាគារដែលប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨ឆ្នាំ ក្នុងពេលបាន និងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលឃុំនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមណ្ឌលឃុំនីតិសម្បទាបន្តរហូតដល់អាយុក្រោម ២៤ឆ្នាំ។ នៅពេលទណ្ឌិតឈានចូលអាយុ២៤ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជន។

បែបបទនិងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី ទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[6]។

## ១០.២ បញ្ជីឈ្មោះអនីតិជន

បញ្ជីឈ្មោះអនីតិជនត្រូវមានដាច់ដោយឡែកពីនីតិជន និងត្រូវបានយកចិត្តទុកដាក់ជាពិសេសដល់ការគ្រប់គ្រងទៅលើអនីតិជន។ ការចុះបញ្ជីឈ្មោះអនីតិជនគឺមានសារប្រយោជន៍មួយដែលងាយស្រួលក្នុងការគ្រប់ គ្រងអនីតិក្នុងពន្ធនាគារ ព្រោះការចុះបញ្ជីនេះអាចអោយដឹងពីព័ត៌មានលម្អិតរបស់អនីតិជនដូចជាអត្តសញ្ញាណរបស់អនីតិជនព័ត៌មានអំពីសុខភាពរាងកាយ និងសតិស្មារតីដែលបានដឹងរួមមានការប្រព្រឹត្តគ្រឿងញៀន ឬសុរា។ គ្រប់មណ្ឌលឃុំនីតិសម្បទា ត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជន ព្រមទាំងបំពេញព័ត៌មានទាំងអស់ និងរក្សាឱ្យមានសុវត្ថិភាព។ បញ្ជីនិងនីតិវិធីដោយឡែកនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុក វិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ១០.៣ សិទ្ធិជាមូលដ្ឋានរបស់អនីតិជនដែលជាប់ឃុំ

ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទាជាអាទិ៍ ការបណ្តុះបណ្តាលការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឱ្យក្លាយទៅជាពលរដ្ឋសុចរិក និងមានប្រយោជន៍ដល់សង្គមជាតិ។

មន្ត្រីមណ្ឌលឃុំនីតិសម្បទាដែលទទួលបន្ទុកគ្រប់គ្រងអនីតិជន ត្រូវទទួលបណ្តុះបណ្តាលអំពីចិត្តសាស្ត្រ សុខុមាលភាព បទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនិងកុមារ និងវិធានការសម្រាប់ការពារ អនីតិជនដែលត្រូវបានដកហូតសេរីភាព។

**អនីតិជនដែលជាប់ឃុំទាំងអស់ត្រូវទទួលបានសិទ្ធិជាមូលដ្ឋានដូចជា៖**

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោឃៅអមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឱ្យនៅឯកកា ការដាក់

[6] មាត្រា៨២ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

កំហិត ឬបដិសេធមិនឱ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ ។

- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្តីថ្លៃថ្នូររបស់អនីតិជន ។
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ញាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច
- សិទ្ធិផ្តល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី ។
- សិទ្ធិទទួលបានការអនុញ្ញាតឱ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬ មិត្តភក្តិ។
- សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធិភាព រក្សាការសម្ងាត់ទាក់ទងនិងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន។
- សិទ្ធិផ្សេងៗទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន[7]។

### ១០.៤ សិទ្ធិទទួលបានការបែងចែកការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា

ការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា ត្រូវបែងចែកជា ៣ផ្នែកដាច់ដោយឡែកពីគ្នា៖

- ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន
- ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា
- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម។

បែបបទនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា ដែលត្រូវជាប់ឃុំ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្រ្តីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ និងរដ្ឋមន្រ្តីក្រសួងយុត្តិធម៌។

### ១០.៥ សិទ្ធិទទួលបានសេវាសម្រាប់អនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា

អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលឃុំនីតិសម្បទាទាំងអស់ ត្រូវផ្តល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដូចជា៖

- ការការពារ ថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល

[7] មាត្រា ៨០ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

- សិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាក់ពីការងារ
- សុខភាពផ្លូវកាយនិងផ្លូវចិត្តសមស្រប
- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីពេទ្យត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងជនជាប់ឃុំជាអនីតិជនព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពីការភាពផ្ទៃកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត
- សេវាផ្សេងៗទៀតដែលលើកស្ទួយសុខភាពនិងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឱ្យមានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឱ្យមានអាកប្បកិរិយា និងជំនាញដែលនិងជួយអនីតិជនក្នុងការអភិវឌ្ឍសក្តានុពលរបស់ខ្លួនក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងជួយឱ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញបន្ទាប់ពីបានដោះលែង[8]។

## ១០.៦ សិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌចំពោះអនីតិជន អាចត្រូវផ្តល់ឱ្យដល់ទណ្ឌិតជាអនីតិជនដែលទទួលរងទោស ក្នុងមណ្ឌលឃុំនីតិសម្បទាៈ

- ចំនួនមួយភាគបីនៃទោស ប្រសិនបើទោសតិចជាង ឬស្មើ ១ឆ្នាំ
- ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីផ្សេងទៀត។

**+ បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងដោយមានលក្ខខណ្ឌ**

បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌរួមមានៈ

- ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់ជននោះ
- អ្នកតំណាងដែលច្បាប់បានកំណត់
- ប្រធានមណ្ឌលឃុំនីតិសម្បទា
- ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនិងរឿងក្តីអនីតិជននោះ
- បេសកកម្មការទូត ឬកុងស៊ុលបរទេស ក្នុងករណីអនីតិជនជាជនបរទេស[9] ។

## ១១. យន្តការក្នុងការលើកកម្ពស់ចំពោះសិទ្ធជនជាប់ឃុំ

- **គោលការណ៍ជាមូលដ្ឋាន**

**វិធានទី ១**

សេចក្តីថ្លៃថ្នូរ និងតម្លៃមនុស្សជាតិរបស់ជនជាប់ឃុំទាំងអស់គួរត្រូវបានគោរព។ គ្មានជនជាប់ឃុំណាម្នាក់ត្រូវបានបង្ខំឱ្យទទួលរងទារុណកម្ម ហើយជនជាប់ឃុំទាំងអស់ត្រូវបានការពារពីការធ្វើទារុណកម្ម និង

[8] មាត្រា៨១ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[9] មាត្រា៧៣ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

អំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្ម ផ្សេងទៀត ដែលគ្មានករណីណាមួយត្រូវសំអាងជាហេតុផលឡើយ។ សុវត្ថិភាព និងសន្តិសុខរបស់ជនជាប់ បុគ្គលិក អ្នកផ្តល់សេវា និងអ្នកសួរសុខទុក្ខត្រូវបានធានាគ្រប់ពេល។

**វិធានទី ២**

១.បញ្ញត្តិដូចតទៅនេះយកទៅអនុវត្តដោយមិនឱ្យមានលំអៀងឡើយ។ មិនត្រូវមានការ ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិដទៃៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ស្ថានភាពកំណើត ឬស្ថានភាពដទៃៗទៀតឡើយ។

២. ដើម្បីការអនុវត្តគោលការណ៍មិនរើសអើង រដ្ឋបាលពន្ធនាគារ ត្រូវគិតគូរពីសេចក្តីត្រូវការរបស់ ជនជាប់ឃុំម្នាក់ៗ ជាពិសេស ក្រុមដែលងាយរងគ្រោះបំផុតនៅក្នុងពន្ធនាគារ។ត្រូវចាត់វិធានការការពារ និង លើកកំពស់សិទ្ធិជនជាប់ឃុំដែលមានសេចក្តីត្រូវការពិសេសហើយមិនត្រូវបានចាត់ទុកថាជាការរើសអើងឡើយ។

**វិធានទី ៣**

ការដាក់ពន្ធនាគារ ហើយនិងវិធានការដទៃទៀត ដែលបណ្តាលឱ្យជនជាប់ឃុំត្រូវកាត់ផ្តាច់ពីការទាក់ទងជាមួយអ្នកដទៃគឺអាចធ្វើបានក្នុងគោលដៅមិនឱ្យមានការអនុវត្តសិទ្ធិស្វ័យសម្រេចតាមរយៈការដកហូតនូវសេរីភាព។ ដូច្នេះក្រៅអំពីការឃុំឃាំងដោយមានមូលហេតុត្រឹមត្រូវច្បាស់លាស់ ហើយនិងការរក្សាវិន័យក្នុងពន្ធនាគារ របបគ្រប់គ្រងនៅក្នុងពន្ធនាគារមិនត្រូវបង្កើនសេចក្តីទុក្ខសោកឈឺចាប់ទៅលើពួកជនជាប់ឃុំដែលកំពុងតែមានការឈឺចាប់នោះទៀតឡើយ។

**វិធានទី ៤**

១. គោលដៅ និងមូលហេតុនៃការកាត់ទោសដាក់ពន្ធនាគារ ឬតាមមធ្យោបាយឯទៀត ដើម្បីមិនឱ្យសាមីខ្លួនមានសេរីភាពវិសេសបំផុតដើម្បីការពារសង្គមមនុស្សកុំឱ្យមានអំពើឧក្រិដ្ឋ។ គោលដៅនេះនឹងសម្រេចទៅបាន លុះត្រាតែមានការអប់រំឱ្យបានខ្ពង់ខ្ពស់បំផុតដល់ជនជាប់ឃុំដែលកំពុងនៅក្នុងពន្ធនាគារ ហើយពេលចេញពីពន្ធនា គារវិញ បុគ្គលនេះមិនត្រឹមតែក្លាយជាមនុស្សដែលមានបំណងចង់គោរពច្បាប់តែប៉ុណ្ណោះទេ តែក្លាយទៅជាមនុស្សមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រតិបត្តិតាមច្បាប់ និងប្រកបរបរចិញ្ចឹមជីវិតដោយខ្លួនឯងទៀតផង។

២. ក្នុងទិសដៅនេះ រដ្ឋបាលពន្ធនាគារត្រូវប្រើគ្រប់មធ្យោបាយដែលសមរម្យ និងដែលអាចរកបាន ទាំងមធ្យោបាយអប់រំ មធ្យោបាយដោះស្រាយបញ្ហា មធ្យោបាយផ្នែកសីលធម៌ និងខាងគំនិតស្មារតី ហើយនិងមធ្យោបាយដទៃទៀត ព្រមទាំងជំនួយគ្រប់បែបយ៉ាងដែលអាចរកបាន ហើយត្រូវព្យាយាមប្រើវាតាមលំនាំនៃសេចក្តីត្រូវការក្នុងការគ្រប់គ្រងជនជាប់ឃុំមួយរូបៗ។

**វិធានទី ៥**

១. របបគ្រប់គ្រងនៅក្នុងពន្ធនាគារត្រូវធ្វើយ៉ាងណាកុំឱ្យការរស់នៅក្នុងពន្ធនាគារខុសគ្នាឆ្ងាយពេកអំពីជីវិត ដែលប្រកបដោយសេរីភាពនៅក្រៅពន្ធនាគារ គឺដើម្បីជួយសម្រាលបន្ទុកដល់ជនជាប់ឃុំហើយនិងបង្កើនការគោរពដល់សេចក្តីថ្លៃថ្នូររបស់គេក្នុងនាមជាមនុស្ស ។

២. រដ្ឋបាលពន្ធនាគារ ត្រូវផ្តល់កន្លែងសមស្របឱ្យជនជាប់ឃុំស្នាក់នៅ និងរៀបចំកែសម្រួលតាមការជាក់ស្តែង ដើម្បីធានាថាជនជាប់ឃុំដែលមានពិការភាពផ្លូវកាយ ផ្លូវចិត្ត ឬពិការភាពផ្សេងទៀត អាចរស់នៅក្នុងពន្ធនាគារយ៉ាងពេញលេញ និងមានប្រសិទ្ធភាព ផ្អែកលើគោលការណ៍សមធម៌។

- **ការគ្រប់គ្រងសំណុំរឿងជនជាប់ឃុំ**

**វិធានទី ៦**

គ្រប់ពន្ធនាគារ ត្រូវមានប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ជនជាប់ឃុំត្រឹមត្រូវ។ ប្រព័ន្ធសំណុំរឿងនេះអាចជារបាយការណ៍ទិន្នន័យមូលដ្ឋានអេឡិចត្រូនិច ឬសៀវភៅកត់ឈ្មោះដែលទំព័រមានបង់លេខ និងចុះហត្ថលេខា ត្រូវមាននីតិវិធីដើម្បីធានាសុវត្ថិភាពសៀវភៅសវនកម្ម និងទប់ស្កាត់ការចូល ឬការផ្លាស់ប្តូរព័ត៌មានក្នុងប្រព័ន្ធដោយគ្មានការអនុញ្ញាត។

**វិធានទី ៧**

គ្មានមនុស្សណាម្នាក់ត្រូវបានទទួលដាក់ពន្ធនាគារ ដោយមិនមានដីកាឃុំខ្លួនឡើយ។ បន្ទាប់ពីការទទួលជនជាប់ឃុំម្នាក់ៗ ត្រូវបញ្ចូលព័ត៌មានខាងក្រោមក្នុងប្រព័ន្ធគ្រប់គ្រងសំណុំរឿងជនជាប់ឃុំៈ

(ក) ព័ត៌មានជាក់លាក់ បង្កភាពងាយស្រួលក្នុងការកំណត់អត្តសញ្ញាណ ការគោរពយេនឌ័រ។

(ខ) មូលហេតុសម្រាប់ដីកាឃុំខ្លួន និងអាជ្ញាធរទទួលខុសត្រូវ និងកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងឃាត់ខ្លួន។

(គ) ថ្ងៃ និងម៉ោងចូលពន្ធនាគារ ដោះលែង និងផ្ទេរ

(ឃ) របួសជាក់ស្តែងណាមួយ និងបណ្តឹងពីការធ្វើបាបមុនពេលចូលពន្ធនាគារ

(ង) បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់ជនជាប់ឃុំ

(ច) ឈ្មោះសមាជិកគ្រួសារ និងកូន និងអាយុកូនៗ ប្រសិនមាន ទីកន្លែង និងពន្ធនាគារ ឬស្ថានភាពអាណាព្យាបាល ។

(ឆ) អាសយដ្ឋានទំនាក់ទំនងបន្ទាន់ និងព័ត៌មានរបស់សាច់ញាតិជិតស្និទ្ធរបស់ជនជាប់ឃុំ ។

**វិធានទី ៨**

ប្រសិនអាចធ្វើទៅបាននៅក្នុងអំឡុងពេលជាប់ពន្ធនាគារ ត្រូវដាក់បញ្ចូលព័ត៌មានខាងក្រោមទៅក្នុង

ប្រព័ន្ធគ្រប់គ្រងសំណុំរឿងជនជាប់ឃុំ៖

(ក) ព័ត៌មានទាក់ទងនឹងនីតិវិធីតុលាការ រួមទាំងកាលបរិច្ឆេទសវនាការតុលាការ និងបណ្ដឹងតវ៉ាផ្នែកផ្លូវច្បាប់

(ខ) របាយការណ៍វាយតម្លៃបឋម និងរបាយការណ៍ចំណាត់ថ្នាក់

(គ) របាយការណ៍ទាក់ទងនឹងការប្រព្រឹត្ត និងវិន័យ

(ឃ) សំណើ និងការតវ៉ា រួមទាំងការចោទប្រកាន់អំពីការធ្វើទារុណកម្ម ឬអំពើឃោរឃៅ អំពើអនុស្សធម៌

ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្ម លើកលែងតែវាជាព័ត៌មានដែលត្រូវរក្សាការសម្ងាត់។

(ង) ព័ត៌មានស្ដីពីការដាក់ទណ្ឌកម្មវិន័យ

(ច) ព័ត៌មានស្ដីពីស្ថានភាពនិងមូលហេតុនៃរបួសស្នាម ឬមរណភាពនិងក្នុងករណីក្រោយមកទៀតទីកន្លែងដែលត្រូវបញ្ជូនសាកសព។

**វិធានទី ៩**

រាល់របាយការណ៍ទាំងអស់ដែលបានរៀបរាប់នៅក្នុងវិធានទី៧ និងទី៨ ត្រូវរក្សាការសម្ងាត់ និងត្រូវ ផ្តល់ឱ្យតែចំពោះអ្នកទទួលខុសត្រូវ ដែលត្រូវការរបាយការណ៍ទាំងនេះប៉ុណ្ណោះ។ ជនជាប់ឃុំម្នាក់ៗ ត្រូវបាន ផ្តល់សិទ្ធិចូលមើលរបាយការណ៍ទាំងនេះដែលទាក់ទងចំពោះពួកគេ អាស្រ័យទៅលើវិធានមើលឯកសារ ដែលអនុញ្ញាតដោយច្បាប់ក្នុងស្រុក និងមានសិទ្ធិទទួលបានច្បាប់ចតចម្លងនៃរបាយការណ៍នេះ ពេលចេញពីពន្ធនាគារ។

**វិធានទី ១០**

ប្រព័ន្ធគ្រប់គ្រងសំណុំរឿងជនជាប់ឃុំ ក៏ត្រូវបានប្រើផងដែរដើម្បីបង្កើតទិន្នន័យដែលជឿទុកចិត្តបានអំពីនិន្នាការនានាទាក់ទងនឹងនឹងចរិតលក្ខណៈនៃមនុស្សក្នុងពន្ធនាគារ រួមមានអត្រានៃការប្រើប្រាស់បន្ទប់ពន្ធនាគារ ដើម្បីបង្កើតជាមូលដ្ឋានសម្រាប់ការធ្វើសេចក្ដីសម្រេចចិត្តផ្អែកលើភ័ស្ដុតាង។

- **ការបែងចែកជនជាប់ឃុំតាមប្រភេទ**

**វិធានទី ១១**

ប្រភេទជនជាប់ឃុំខុសៗគ្នា ត្រូវឃុំក្នុងពន្ធនាគារ ឬផ្នែកនៃពន្ធនាគារដាច់ដោយឡែកៗពីគ្នាដោយយោងទៅតាម ភេទ អាយុ ប្រវត្តិប្រព្រឹត្តបទឧក្រិដ្ឋ ហេតុផលខាងផ្លូវច្បាប់សម្រាប់ការឃុំខ្លួនរបស់គេ ព្រមទាំងសេចក្ដីចាំបាច់នានានៃការប្រព្រឹត្តចំពោះពួកគេ មានដូចជា៖

(ក) ជនជាប់ឃុំប្រុស និងជនជាប់ឃុំស្ត្រី ត្រូវដាក់ឃុំដាច់ដោយឡែក និងឱ្យបានឆ្ងាយពីគ្នាតាមលទ្ធ

ភាពដែលអាចធ្វើទៅបាន។ចំពោះពន្ធនាគារដែលទទួលយកទាំងជនជាប់ឃុំប្រុសនិងជនជាប់ឃុំស្រីនោះបរិវេណសម្រាប់ដាក់ជនជាប់ឃុំស្រីត្រូវតែនៅដាច់ដោយឡែកពីបរិវេណសម្រាប់ជនជាប់ឃុំប្រុសជាដាច់ខាត។

(ខ) ជនជាប់ឃុំដែលមិនទាន់ត្រូវបានជំនុំជម្រះទោសត្រូវតែដាក់ឱ្យនៅដាច់ដោយឡែកពីទណ្ឌិត

(គ) អ្នកជាប់ពន្ធនាគារដោយសារជំពាក់បំណុលគេ និងជាប់ដោយសាររឿងរដ្ឋប្បវេណី ត្រូវដាក់ឱ្យដាច់ឡែកពីជនជាប់ឃុំដែលត្រូវបានរកឃើញថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

(ឃ) ជនជាប់ឃុំអនីតិជន ត្រូវដាក់ឱ្យដាច់ឡែកពីជនជាប់ឃុំដែលជាមនុស្សពេញវ័យ។

- **ទីកន្លែងសម្រាប់ជនជាប់ឃុំស្នាក់នៅ**

**វិធានទី ១២**

១. ក្នុងករណីជនជាប់ឃុំអាចមានបន្ទប់ដេកម្នាក់មួយរៀងៗខ្លួន ជនជាប់ឃុំម្នាក់ៗមានសិទ្ធិដេកក្នុងបន្ទប់មួយតែម្នាក់ឯងគត់។ ប៉ុន្តែដោយមូលហេតុពិសេសខ្លះដូចជាក្នុងករណីបណ្តោះអាសន្នដែលមានភាពចង្អៀតណែនក្នុងពន្ធនាគាររដ្ឋបាលគ្រប់គ្រងពន្ធនាគារថ្នាក់កណ្តាលអាចចាំបាច់ធ្វើបដិប្បញ្ញត្តិទៅនឹងវិធាននេះបាន។ ប៉ុន្តែបើជៀសវាងបាន គួរកុំដាក់ជនជាប់ឃុំពីរនាក់ឱ្យនៅដេកក្នុងបន្ទប់ឃុំឃាំងជាមួយគ្នា។

២. ប្រសិនបើជនជាប់ឃុំដេកក្នុងបន្ទប់រួមគ្នា គេត្រូវជ្រើសយកតែជនជាប់ឃុំប្រភេទណាដែលអាចរស់នៅជាមួយគ្នាបានឱ្យនៅក្នុងបន្ទប់ជាមួយគ្នា ហើយត្រូវឱ្យមានការត្រួតពិនិត្យមើលឱ្យបានទៀងទាត់នៅវេលាយប់អាស្រ័យទៅតាមប្រភេទនៃពន្ធនាគារ។

**វិធានទី ១៣**

គ្រប់កន្លែងស្នាក់នៅដែលប្រើសម្រាប់ដាក់ជនជាប់ឃុំ និងជាពិសេសកន្លែងដេកទាំងអស់ត្រូវ ស្របទៅតាមតម្រូវការផ្នែកសុខភាព ពោលគឺយកចិត្តទុកដាក់ទៅលើលក្ខណៈធាតុអាកាស និងជាពិសេសគឺត្រូវមានខ្យល់ដកដង្ហើមគ្រប់គ្រាន់ មានទំហំផ្ទៃរាបសមរម្យ មានពន្លឺ កំដៅ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់។

**វិធានទី ១៤**

នៅគ្រប់ទីកន្លែងណាដែលគេតម្រូវឱ្យជនជាប់ឃុំនៅផង ហើយធ្វើការផងគេត្រូវធានាឱ្យមានលក្ខខណ្ឌដូចខាងក្រោមនេះ ៖

(ក) ត្រូវមានបង្អួចទូលំទូលាយ ដើម្បីឱ្យជនជាប់ឃុំអាចធ្វើការ ឬអានសៀវភៅបានដោយពន្លឺថ្ងៃហើយឱ្យមានច្រកចំហធំៗ ដើម្បីឱ្យខ្យល់បក់បានគ្រប់គ្រាន់ ទោះជាមានឬគ្មានកង្ហារបក់ខ្យល់ក៏ដោយ ។

(ខ) ភ្លើងអំពូល ឬភ្លើងអគ្គីសនី ត្រូវឱ្យមានគ្រប់គ្រាន់និងត្រឹមត្រូវ ដើម្បីការពារ ជនជាប់ឃុំនៅ ពេលអានសៀវភៅ ឬនៅពេលធ្វើការ។

**វិធានទី ១៥**

បង្គន់ត្រូវឱ្យមានគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការរបស់ជនជាប់ឃុំគ្រប់ពេលវេលា ហើយត្រូវឱ្យមានភាពស្អាត និងសមរម្យផងដែរ។

**វិធានទី ១៦**

ត្រូវមានបន្ទប់ទឹកគ្រប់គ្រាន់។ ប្រដាប់ប្រើប្រាស់ក្នុងបន្ទប់ទឹកក៏ត្រូវឱ្យមានគ្រប់គ្រាន់។ ត្រូវឱ្យមានទឹកដែលមានសីតុណ្ហភាពស្របទៅតាមធាតុអាកាសខាងក្រៅ និងត្រូវមានទឹកគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការចាំបាច់របស់ជនជាប់ឃុំ ដោយយោងទៅតាមលក្ខខណ្ឌអនាម័យទូទៅប្រចាំរដូវកាល និងទៅតាមលក្ខណ្ឌតំបន់ភូមិសាស្ត្រ។

**វិធានទី ១៧**

គ្រប់ផ្នែកនៃពន្ធនាគារ ដែលសម្រាប់ឱ្យជនជាប់ឃុំប្រើប្រាស់ជានិច្ចជាកាលត្រូវថែទាំសំអាតឱ្យបានត្រឹមត្រូវនិង យ៉ាងហ្មត់ចត់គ្រប់ពេលវេលា។

- **អនាម័យប្រចាំកាយ**

**វិធានទី ១៨**

១. ជនជាប់ឃុំត្រូវរក្សារាងកាយបានស្អាតបាតហេតុនេះ ពួកគេត្រូវតែបានផ្តល់ឱ្យនូវទឹកស្អាត ព្រមទាំងគ្រឿងបរិក្ខារ ប្រើប្រាស់ក្នុងបន្ទប់ទឹកផ្សេងៗ ដែលជាការចាំបាច់សម្រាប់សុខភាព និងភាពស្អាត ។

២. វិន័យចែងថា ជនជាប់ឃុំអាចថែរក្សាខ្លួនឱ្យមានសភាពសមរម្យជាមនុស្សដូចគេឯទៀត។ ក្នុងន័យនេះ ពន្ធនាគារត្រូវតែមានកន្លែងកាត់សក់និងកោរពុកមាត់សម្រាប់ជនជាប់ឃុំ។ ជនជាប់ឃុំប្រុសត្រូវមានលទ្ធភាពកោរពុកមាត់ឱ្យបានទៀងទាត់។

- **ការស្លៀកពាក់ និងការដេក**

**វិធានទី ១៩**

១.រាល់ជនជាប់ឃុំណា ដែលមិនអនុញ្ញាតិឱ្យស្លៀកពាក់សម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់គេទេនោះពួកគេត្រូវតែបានគេផ្តល់ឱ្យនូវសម្លៀកបំពាក់ណាមួយ ដែលសមស្របទៅនឹងធាតុអាកាស និងគ្រប់គ្រាន់ដើម្បីរក្សាគេឱ្យមានសុខភាពល្អ។ សម្លៀកបំពាក់នេះទៀត ក៏មិនត្រូវធ្វើឱ្យមានលក្ខណៈបន្ថោកបន្ទាប ឬអាប់ឱនដល់ជនជាប់ឃុំឡើយ។

២.សម្លៀកបំពាក់ទាំងអស់ ត្រូវតែឱ្យស្អាត ហើយឱ្យមានលក្ខណៈសមរម្យជានិច្ច។ សម្លៀកបំពាក់ក្នុងត្រូវផ្លាស់ប្តូរនិងបោកសំអាតឱ្យបានញឹកញាប់តាមការចាំបាច់ ដើម្បីរក្សាអនាម័យប្រចាំកាយ ។

៣.តាមកាលៈទេសៈពិសេសខ្លះនៅពេលណាគេយកជនជាប់ឃុំចេញទៅក្រៅពន្ធនាគារក្នុងគោលបំណងណាមួយដែលមានការអនុញ្ញាតិតាមច្បាប់ជនជាប់ឃុំត្រូវតែបានអនុញ្ញាតិឱ្យស្លៀកពាក់សម្លៀកបំពាក់

ផ្ទាល់ខ្លួនរបស់គេ ឬក៏សម្លៀកបំពាក់ផ្សេងៗដែលពុំមានលក្ខណៈលេចធ្លោខុសគេខុសឯងពេក។

**វិធានទី ២០**

ប្រសិនបើគេអនុញ្ញាតឱ្យជនជាប់ឃុំស្លៀកពាក់ខោអាវផ្ទាល់ខ្លួននៅក្នុងពន្ធនាគារ អាជ្ញាធរត្រូវធានាថាខោអាវទាំងនេះត្រូវរក្សាឱ្យស្អាតបាត ហើយមានគុណភាពល្អសមល្មមប្រើបានជានិច្ច។ ចំណាត់ការ នេះត្រូវផ្តើមធ្វើចាប់តាំងពីថ្ងៃដែលជនជាប់ឃុំចូលមកដល់ពន្ធនាគារ។

**វិធានទី ២១**

យោងទៅតាមកម្រិតរស់នៅប្រចាំតំបន់ ឬប្រចាំប្រទេសទាំងមូល ជនជាប់ឃុំគ្រប់ៗរូបត្រូវតែមាន គ្រែដេកម្នាក់មួយ និងសម្ភារៈដេកដោយឡែកពីជនជាប់ឃុំឯទៀត ហើយត្រូវឱ្យស្អាត និងត្រូវផ្លាស់ប្តូរឱ្យបាន ញឹកញាប់ដើម្បីរក្សាភាពស្អាតបាត។

- **ម្ហូបអាហារ**

**វិធានទី ២២**

១. ជនជាប់ឃុំគ្រប់រូបត្រូវតែបានទទួលម្ហូបអាហារដែលផ្តល់ឱ្យដោយរដ្ឋតាមពេលម៉ោងធម្មតា។ ម្ហូបអាហារនោះ ត្រូវមានគុណភាព និងជីវជាតិអាហារគ្រប់គ្រាន់ដើម្បីសុខភាព និងកម្លាំងពលំ រស់ជាតិទទួលយកបាន និងត្រូវបានចម្អិនបានល្អ។

២. ទឹកសម្រាប់ផឹកត្រូវឱ្យមានគ្រប់គ្រាន់សម្រាប់នៅពេលណាជនជាប់ឃុំម្នាក់ៗត្រូវការ។

- **ការហាត់ប្រាណនិងលេងកីឡា**

**វិធានទី ២៣**

១. ជនជាប់ឃុំគ្រប់រូប ដែលមិនបានចេញទៅធ្វើការនៅខាងក្រៅពន្ធនាគារទេនោះ ត្រូវមានឱកាសហាត់ប្រាណនៅក្នុងទីធ្លាស្រឡះយ៉ាងតិចមួយម៉ោងជារៀងរាល់ថ្ងៃ ប្រសិនបើធាតុអាកាសអនុញ្ញាត។

២.ជនជាប់ឃុំអនីតិជន និងជនជាប់ឃុំនីតិជនដែលមានអាយុ និងរាងកាយសមស្រប ត្រូវឲ្យមានការហ្វឹកហាត់ខាងកាយវប្បកម្ម និងការកំសាន្តផងនៅក្នុងពេលហាត់ប្រាណ។ ក្នុងន័យនេះដែរពន្ធនាគារគួរ ផ្តល់ទីកន្លែង និងសំភារៈកីឡាផ្សេងៗ។

- **សេវាថែទាំសុខភាព**

**វិធានទី២៤**

ការផ្តល់សេវាថែទាំសុខភាពដល់ជនជាប់ឃុំ គឺជាការទទួលខុសត្រូវរបស់រដ្ឋ។ ជនជាប់ឃុំត្រូវទទួលបានការថែទាំសុខភាពតាមស្តង់ដារដូចគ្នានឹងសេវាសុខភាពខាងក្រៅពន្ធនាគារដូច្នោះដែរ និងត្រូវមានលទ្ធភាពទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ និងមិនរើសអើងដោយសារស្ថានភាពផ្លូវច្បាប់របស់ពួក

គេ។សេវាថែទាំសុខភាព ត្រូវបានចាត់ចែងដោយសហការជិតស្និតជាមួយប្រព័ន្ធសុខាភិបាលសាធារណៈទូទៅ និង ធានាឱ្យមាននិរន្តរភាពនៃការព្យាបាល និងថែទាំ រួមទាំងមេរោគអេដស៍ របេង និងជំងឺឆ្លងផ្សេងៗទៀត ក៏ដូចជាចំពោះរោគញៀនផងដែរ។

**វិធានទី២៥**

១. ពន្ធនាគារនីមួយៗត្រូវមានសេវាថែទាំសុខភាព ដែលមានភារកិច្ចវាយតម្លៃ ផ្សព្វផ្សាយ ការពារ និងលើកកម្ពស់សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់ជនជាប់ឃុំ ដោយយកចិត្តទុកដាក់ពិសេសចំពោះជនជាប់ឃុំដែលត្រូវការការថែទាំសុខភាពពិសេសឬដែលមានបញ្ហាសុខភាពដែលរារាំងដល់ការស្តារនីតិសម្បទា

២. សេវាសុខភាពត្រូវមានសមាសភាពជាក្រុមចម្រុះ និងមានគុណវុឌ្ឍិគ្រប់គ្រាន់ ក្នុងការព្យាបាលដោយឯករាជ្យ និងត្រូវមានជំនាញផ្នែកចិត្តវិទ្យា និងវិកលវិទ្យា។ ពន្ធនាគារក៏ត្រូវមានទន្តពេទ្យដែលមានគុណវុឌ្ឍិសមស្របសម្រាប់ជនជាប់ឃុំម្នាក់ៗ។

**វិធានទី២៦**

១. ផ្នែកសេវាថែទាំសុខភាពត្រូវរៀបចំ និងថែទាឯកសារពេទ្យទៀងទាត់ថ្មីៗ និងមានការសម្ងាត់ របស់ជនជាប់ឃុំម្នាក់ៗ ហើយជនជាប់ឃុំទាំងអស់អាចអនុញ្ញាតចូលមើលឯកសាររបស់ពួកគេទៅតាមសំណើ។ ជនជាប់ឃុំអាចពឹងពាក់ឱ្យអ្នកទីបីចូលមើលឯកសាររបស់ខ្លួនបាន។

២. ឯកសារពេទ្យត្រូវបានផ្ទេរទៅផ្នែកសេវាថែទាំសុខភាពនៃស្ថាប័នទទួលនៅពេលមានការផ្ទេរជនជាប់ឃុំណាម្នាក់ ដោយត្រូវរក្សាការសម្ងាត់វេជ្ជសាស្ត្រ។

**វិធានទី២៧**

១. ពន្ធនាគារទាំងអស់ត្រូវធានាការទទួលការទទួលភ្លាមៗនូវការថែទាំវេជ្ជសាស្ត្រក្នុងករណីបន្ទាន់ ជនជាប់ឃុំដែលត្រូវការការព្យាបាលពិសេសឬការវះកាត់ ត្រូវបញ្ជូនទៅស្ថាប័នជំនាញ ឬទៅមន្ទីរពេទ្យទូទៅនៅខាងក្រៅ។ ទីណាពន្ធនាគារមានមន្ទីរពេទ្យខ្លួនឯង ត្រូវមានបុគ្គលិក និង បំពាក់បរិក្ខារគ្រប់គ្រាន់ ដើម្បីព្យាបាល និងថែទាំជនជាប់ឃុំដែលត្រូវទទួលសេវាសុខាភិបាល។

២.មានតែអ្នកជំនាញការផ្នែកថែទាំងសុខភាពប៉ុណ្ណោះដែលអាចធ្វើការសម្រេចចិត្តទាក់ទងនឹងការព្យាបាលដោយមិនត្រូវបានបំពានដោយ ឬមិនអើពើពីមន្ត្រីពន្ធនាគារដែលមិនមែនជាមន្ត្រីពេទ្យឡើយ។

## ១២.វិធានអង្គការសហប្រជាជាតិសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំជាស្ត្រី

### ១២.១ សេវាថែទាំសុខភាព

នៅក្នុងពន្ធនាគាររបស់ជនជាប់ឃុំស្រីត្រូវឱ្យមានការឧបត្ថម្ភពិសេសសម្រាប់ការថែរក្សា និង ព្យាបាលខ្លួននៅពេលមុន និងក្រោយការសម្រាលកូន។ បើអាចធ្វើបាន ត្រូវតែអនុញ្ញាតឱ្យជនជាប់ឃុំបាន ចេញទៅ

សម្រាលកូននៅក្រៅពន្ធនាគារ។ ប៉ុន្តែបើសិនណាកូនកើតនៅក្នុងពន្ធនាគារវិញ មិនត្រូវចុះនិទ្ទេសក្នុងសំបុត្រកំណើតថាទារកនោះកើតនៅក្នុងពន្ធនាគារឡើយ។

**១.ការសម្រេចចិត្តអនុញ្ញាតឱ្យក្មេងស្នាក់នៅជាមួយឪពុកម្តាយក្នុងពន្ធនាគារ គឺត្រូវផ្អែកទៅលើឧត្តមប្រយោជន៍របស់កុមារ ។ ពេលអនុញ្ញាអោយកុមារស្នាក់នៅក្នុងពន្ធនាគារជាមួយឪពុកម្តាយ ត្រូវផ្តល់សេវាដូចខាងក្រោមដល់កុមារៈ**

ក. ពេលកុមារមិនស្ថិតក្នុងការថែទាំងពីឪពុកម្តាយ ពួកគេទទួលសេវាថែទាំខាងក្រៅ ឬខាងក្នុងដោយបុគ្គលិកជំនាញ ។

ខ. សេវាថែទាំងកុមារ រួមមានការពិនិត្យសុខភាពនៅពេលចូលពេទ្យ និងការបន្តរតាមដានការអភិវឌ្ឍរបស់កុមារដោយមន្ត្រីជំនាញ។ កុមារនៅក្នុងពន្ធនាគារជាមួយឪពុកម្តាយមិនត្រូវបានចាត់ទុកជាជនជាប់ឃុំទេ។

គ្រូពេទ្យ ឬមន្ត្រីជំនាញផ្នែកថែទាំសុខភាព ទោះជាត្រូវ ឬមិនតម្រូវឱ្យរាយការណ៍ជូនគ្រូពេទ្យ ក៏ត្រូវតែមើលពិភាក្សានិងពិនិត្យជនជាប់ឃុំម្នាក់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបានបន្ទាប់ពីទទួលជនជាប់ឃុំចូលក្នុងពន្ធនាគារ និងពិនិត្យនាពេលក្រោយមកទៀតតាមតម្រូវការចាំបាច់។ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះ

ក.ការកំណត់តម្រូវការថែទាំសុខភាព និងការចាត់វិធានការចាំបាច់ទាំងអស់សម្រាប់ការព្យាបាល

ខ.ការពិនិត្យមើលលក្ខណៈដែលស្តែងចេញពីការធ្វើបាបផ្សេងៗមកលើជនជាប់ឃុំមុនពេលបញ្ជូនមកពន្ធនាគារ។

គ.ការកំណត់រោគសញ្ញាជំងឺផ្លូវចិត្ត ឬភាពតានតឹងផ្សេងដែលបណ្តាលមកពីការជាប់ពន្ធនាគារ រួមមានហានិភ័យនៃការធ្វើអត្តឃាត ឬការបង្កអន្តរាយដល់ខ្លួនឯង និងរោគសញ្ញាផ្សេងៗដែលបណ្តាលមកពីការសេពគ្រឿងញៀន ការប្រើឱសថ ឬគ្រឿងស្រវឹង និងបន្ទាប់មកត្រូវចាត់វាល់វិធានការ ឬការព្យាបាលជាក់ស្តែងទៅតាមស្ថានភាពជនជាប់ឃុំម្នាក់ៗ។

ឃ.ក្នុងករណីជនជាប់ឃុំសង្ស័យមានជំងឺឆ្លង ត្រូវរៀបចំដាក់ជនជាប់ឃុំដោយឡែក និងផ្តល់ការព្យាបាលត្រឹមត្រូវក្នុងអំឡុងពេលដែលមានជំងឺឆ្លង។

ង.ការកំណត់ពីកាយសម្បទាជនជាប់ឃុំសម្រាប់ធ្វើការងារលំហាត់ប្រាណ និងចូលរួមសកម្មភាពផ្សេងៗតាមលទ្ធភាពជាក់ស្តែង។

### ១២.២ ការត្រួតពិនិត្យសុខភាពពេលចូលពន្ធនាគារ

ការពិនិត្យសុខភាពរបស់ជនជាប់ឃុំជាស្ត្រី ត្រូវរួមបញ្ចូលនូវការត្រួតពិនិត្យយ៉ាងហ្មត់ចត់ដើម្បីកំណត់អំពីតម្រូវការថែទាំសុខភាពបឋម និងត្រូវកំណត់ផងដែរនូវៈ

- វត្តមាននៃជម្ងឺកាមរោគ ឬជំងឺឆ្លងតាមឈាម និងតាមកត្តានិភ័យនានា ជនជាប់ឃុំជាស្ត្រីក៏អាចទទួលបានការពិនិត្យមេរោគ HIV ផងដែរ ដោយមានការប្រឹក្សាទាំងមុន និងក្រោយពេលធ្វើការពិនិត្យ។
- តម្រូវការថែទាំសុខភាពផ្លូវចិត្ត រួមបញ្ចូលទាំង ជំងឺផ្លូវចិត្តក្រោយជួបវិបត្តិធ្ងន់ធ្ងរ និងហានិភ័យនៃការធ្វើអត្តឃាត និងការបង្ករគ្រោះថ្នាក់ដល់ខ្លួនឯង។
- ប្រវត្តិសុខភាបន្តពូជរបស់ជនជាប់ឃុំជាស្ត្រី រួមមាន ការមានផ្ទៃពោះ កាសំរាលកូន និងបញ្ហាដែលទាក់ទងនិងសុខភាពបន្តពូជ នាពេលបច្ចុប្បន្ន ឬថ្មីៗ។
- ការរំលោភបំពានខាងផ្លូវភេទ និងទម្រង់ផ្សេងៗទៀតអំពីហិង្សាដែលអាចកើតឡើងមុនពេលចូលពន្ធនាគារ។
- ប្រសិនបើអាត្តិភាពនៃការរំលោភបំពានខាងផ្លូវភេទ ឬទម្រង់ផ្សេងៗនៃអំពើហិង្សា មុនពេលឬអំឡុងពេលនៃការឃុំខ្លួនត្រូវបានត្រួតពិនិត្យ ជនជាប់ឃុំជាស្ត្រីត្រូវទទួលបានការជូនដំណឹងអំពីសិទ្ធិរបស់គាត់ក្នុងការស្វែងរកឧបាស្រ័យពីអាជ្ញាធរតុលាការ។ ជនជាប់ឃុំស្ត្រីគួរតែត្រូវបានផ្តល់ព័ត៌មានយ៉ាងពេញលេញអំពីនីតិវិធី និងដំណាក់កាលដែលពាក់ព័ន្ធ។ ប្រសិនបើជនជាប់ឃុំជាស្ត្រីយល់ព្រមអោយចាត់វិធានការច្បាប់ គេត្រូវជូនដំណឹងនេះដល់មន្ត្រីពាក់ព័ន្ធ ហើយភ្លាមៗបញ្ជូនករណីនោះទៅដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីបើកការស៊ើបអង្កេត។ អាជ្ញាធរពន្ធនាគារនានាត្រូវជួយស្ត្រីបែបទាំងនេះ ឱ្យទទួលបានជំនួយផ្នែកច្បាប់។
- ទោះបីជាស្ត្រីនោះជ្រើស ឬមិនជ្រើសក្នុងវិធានការច្បាប់ ឬអាជ្ញាធរពន្ធនគារត្រូវខិតខំដើម្បីធានាថាស្ត្រីនោះទទួលបានភ្លាមៗនូវការគាំទ្រ ឬការប្រឹក្សាខាងចិត្តសាស្ត្រតាមបែបវិជ្ជាជីវៈ។
- គេត្រូវបង្កើតវិធានការជាក់លាក់នានាឡើង ដើម្បីបញ្ចៀសទម្រង់ណាមួយនៃការសងសឹកប្រឆាំងនឹងក្រុមបុគ្គលនានា ដែលផ្តល់សេចក្តីរាយការណ៍បែបនោះ ឬចាត់វិធានការច្បាប់។
- គេត្រូវគោពពេលវេលាទាំងអស់នូវ សិទ្ធិរបស់ជនជាប់ឃុំជាស្ត្រីក្នុងការទទួលបានការសម្ងាត់ខាងវេជ្ជសាស្ត្រជាក់លាក់ រួមមានសិទ្ធិមិនឱ្យផ្សព្វផ្សាយព័ត៌មាន និងមិនឱ្យត្រួតពិនិត្យទាក់ទិននឹងប្រវត្តិសុខភាពបន្តពូជរបស់ពួកគេ ។
- ប្រសិនបើជនជាប់ឃុំជាស្ត្រីមានកូនរស់នៅជាមួយ កូននោះក៏ត្រូវទទួលការត្រួតពិនិត្យសុខភាពផងដែរ បើអាចធ្វើទៅបាននោះគឺត្រូវពិនិត្យដោយគ្រូពេទ្យជំនាញ ខាងសុខភាពកុមារ ដើម្បីកំណត់អំពីការព្យាបាល និងតម្រូវការខាងផ្នែកវិទ្យាសាស្ត្រនានា។ ត្រូវផ្តល់អោយសេវាសុខភាពសមស្រប យ៉ាងហោចណាស់សមាមាត្រទៅនឹងសេវាក្នុងសហគមន៍ ។

### ១២.៣ ការទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅ

ការទំនាក់ទំនងរបស់ជនជាប់ឃុំជាស្ត្រីជាមួយក្រុមគ្រួសាររាប់ទាំងកូនរបស់ពួកគាត់ អ្នកអាណាព្យាបាលរបស់កូនគាត់ និងអ្នកតំណាងស្របច្បាប់ត្រូវបានជំរុញលើកទឹកចិត្ត និងជួយសម្រួលតាមគ្រប់មធ្យោបាយសមហេតុផល។ប្រសិនជាអាចវិធានការផ្សេងៗត្រូវតែបានចាត់ឡើងដើម្បីរក្សាតុល្យភាពលើការខូចប្រយោជន៍ស្ត្រីដែលបានជាប់ឃុំនៅក្នុងស្ថាប័នទាំងឡាយដែលស្ថិតនៅឆ្ងាយពីលំនៅដ្ឋានរបស់ខ្លួន។

### ១២.៤ ជនជាប់ឃុំជាអនីតិជនស្ត្រី

- អាជ្ញាធរពន្ធនាគារត្រូវបង្កើតវិធានការផ្សេងៗ ដើម្បីបំពេញសេចក្តីត្រូវការខាងការពារ របស់ជនជាប់ឃុំជាស្ត្រីជាអនីតិជន។
- ជនជាប់ឃុំស្ត្រីជាអនីតិជន ត្រូវមានសិទ្ធិស្មើគ្នាក្នុងការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានសំរាប់ជនជាប់ឃុំអនីតិជនជាបុរស។
- ជនជាប់ឃុំស្ត្រីជាអនីតិជន ត្រូវមានសិទ្ធិទទួលបានសេវា និងកម្មវិធីជាក់លាក់តាមអាយុ និង យ៉េងឌ័រជាអាទិ៍ ការពិគ្រោះយោបល់ទាក់ទងនឹងអំពើហឹង្សា ឬការរំលោភផ្លូវភេទ។ ពួកគាត់ត្រូវទទួលការអប់រំអំពីការថែរក្សាសុខភាព និងពិនិត្យព្យាបាលជាទៀងទាត់ពីគ្រូពេទ្យរោគស្ត្រី ដូចគ្នាផងដែរទៅនឹងជនជាប់ឃុំជាអនីតិជន ។
- ជនជាប់ឃុំស្ត្រីជាអនីតិជនដែលមានផ្ទៃពោះត្រូវទទួលបានការគាំទ្រ និងកិច្ចគាំពារផ្នែកវេជ្ជសាស្ត្រដែលលក្ខណៈសមមូលទៅនិងសេវាទាំងឡាយដែលបានផ្តល់ឱ្យជនជាប់ឃុំស្ត្រីជាអនីតិជន។ សុខភាពរបស់ពួកគាត់ត្រូវបានពិនិត្យដោយអ្នកឯកទេសខាងវេជ្ជសាស្ត្រដោយគិតអំពីការដែលពួកគាត់អាចប្រឈមនឹងហានិភ័យច្រើនជាងនេះលើការលំបាកខាងសុខភាពនៅក្នុងអំឡុងពេលមានផ្ទៃពោះដោយសារតែអាយុរបស់ពួកគាត់

### ១២.៥ ស្ត្រីមានគភ៌ម្តាយបំបៅកូនដោយទឹកដោះ និងម្តាយរស់នៅជាមួយកូនក្នុងពន្ធនាគារ

- ជនជាប់ឃុំស្ត្រីមានគភ៌ និងជនជាប់ឃុំស្ត្រីមានកូននៅជាមួយ ត្រូវទទួលការណែនាំអំពី សុខភាពនិងរបបអាហាររបស់ពួកគាត់ ក្រោមកម្មវិធីមួយដែលនឹងត្រូវបានរៀបចំតាក់តែងឡើង និងឃ្លាំមើលដោយអ្នកនាញសុខាភិបាលមួយរូប។ អាហារគ្រប់គ្រាន់និងទៀតទាត់ពេលវេលា បរិស្ថានសុខភាព និងឱកាសធ្វើលំហាត់ប្រាណទៀតទាត់ និងត្រូវផ្តល់ជូនដោយឥតគិតថ្លៃដល់ស្ត្រី មានគភ៌ ទារក កុមារ និងម្តាយដែលបំបៅដោះកូនដោយទឹកដោះ។
- ជនជាប់ឃុំស្ត្រី មិនត្រូវបានគេធ្វើឱ្យរាគចិត្តក្នុងការបំបៅកូនដោយទឹកដោះឡើយ លុះត្រាតែពួកគាត់មានហេតុផលសុខភាពណាមួយ ដែលតម្រូវអោយគាត់មិនអាចបំបៅដោះបាន ។

- សេចក្តីត្រូវការខាងអាហារូបត្ថម្ភ និងខាងវេជ្ជាសាស្ត្ររបស់ជនជាប់ឃុំស្ត្រី ដែលទើបសំរាលកូនប៉ុន្តែកូនរបស់ពួកគាត់មិននៅជាមួយគាត់ក្នុងពន្ធនាគារ ត្រូវបានបញ្ចូលនៅក្នុងកម្មវិធីព្យាបាល ។
- ការសំរេចអនុញ្ញាតអោយកុមារស្នាក់នៅជាមួយម្តាយរបស់ខ្លួនក្នុងពន្ធនាគារ ត្រូវផ្អែកលើឧត្តមប្រយោជន៍របស់កុមារ។ កុមារនៅក្នុងពន្ធនាគារជាមួយម្តាយ មិនត្រូវបានគេប្រព្រឹត្តមកលើខ្លួនដូចជនជាប់ឃុំឡើយ។
- ជនជាប់ឃុំស្ត្រីដែលមានកូនរស់នៅជាមួយក្នុងពន្ធនាគារ ត្រូវបានផ្តល់ឱកាសច្រើនជាអតិបរមាតាមដែលអាចធ្វើបាន ដើម្បីឱ្យគាត់មានពេលវេលាសម្រាប់មើលថែទាំកូន។
- កុមារដែលកំពុងរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ ត្រូវបានផ្តល់នូវសេវាគាំពារ សុខភាពប្រចាំថ្ងៃ ហើយការរីកលូតលាស់របស់ពួកគេត្រូវបានតាមឃ្លាំមើលដោយអ្នកឯកទេសដោយសហការជាមួយសេវាសុខភាពសហគមន៍។
- បរិស្ថានដែលបានផ្តល់សម្រាប់ចិញ្ចឹមបីបាច់ អប់រំកូនដូចនេះ ត្រូវមានសភាពដូចតទៅកុមារដែលនៅខាងក្រៅពន្ធនាគារ តាមដែលអាចធ្វើទៅបាន។

### ១២.៦ ជនជាប់ឃុំបរទេស

ចំពោះជនជាប់ឃុំបរទេសប្រសិនបើមានកិច្ចព្រមព្រៀងពាក់ព័ន្ធទ្វេភាគី ឬពហុភាគី ការផ្ទេរជនជាប់ឃុំបទេសជាស្ត្រីពីប្រទេសមិនមែនដើមកំណើតទៅកាន់ប្រទេសខ្លួនវិញ គេត្រូវធ្វើការពិចារណាឱ្យបានឆាប់តាមដែលអាចធ្វើបាន នៅក្នុងអំឡុងពេលពួកគាត់កំពុងជាប់ពន្ធនាគារ ដោយមានការដាក់ពាក្យ ឬផ្តល់ពត៌មានយល់ព្រមពីជនជាប់ឃុំបទេសជាស្ត្រីដែលពាក់ព័ន្ធ។

ប្រសិនជាមានកុមាររស់នៅជាជនជាប់ឃុំបរទេសជាស្ត្រីដែលពន្ធនាគារនោះមិនមែនជាប្រទេសដើមកំណើតខ្លួនកុមារដែលត្រូវបាននាំចេញពីពន្ធនាគារនោះគេត្រូវពិចារណាអំពីការរៀបចំបញ្ជូនកុមារនោះទៅប្រទេសកំណើតរបស់ខ្លួនដោយគិតគូរអំពីឧត្តមប្រយោជន៍របស់កុមារនិងដោយមានការពីគ្រោះយោបល់ជាមួយស្ត្រីជាម្តាយ។

មន្ត្រីស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងដែលមានបំណងចូលជួបសួរសុខទុក្ខជន ជាប់ឃុំជាពលរដ្ឋរបស់ខ្លួន ឬពលរដ្ឋដែលខ្លួនធ្វើជាតំណាង ត្រូវជូនដំណឹងជាមុនទៅអគ្គនាយកដ្ឋានពន្ធនាគារ។ គ្រួសារ ឬញាតិមិត្តជាជនបរទេសដែលមានបំណងចូលជួបសួរសុខទុក្ខជនជាប់ឃុំត្រូវស្នើមកអគ្គនាយកដ្ឋានពន្ធនាគារ តាមរយៈស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន[10] ។

[10] មាត្រា៥៦ នៃច្បាប់ស្តីពីពន្ធនាគារដែលប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

## ១២.៧ ជនដែលត្រូវគេចាប់ខ្លួន ឬរងចាំសវនាការជំនុំជម្រះទោស

១.ជនដែលត្រូវគេចាប់ខ្លួនឬជាប់ពន្ធនាគារដោយការចោទប្រកាន់ពីបទឧក្រិដ្ឋ ទោះនៅក្នុងកន្លែងឃុំឃាំងរបស់នគរបាល ឬនៅក្នុងពន្ធនាគារក្តី ដែលចៅក្រមមិនទាន់កាត់សេចក្តីផ្តន្ទាទោសនៅឡើយនោះ ត្រូវចាត់ទុកថា " **អ្នកជាប់ឃុំដែលមិនទាន់កាត់ទោស** " ដូចដែលមានចែងនៅវិធានខាងក្រោមនេះ៖

២.ជនជាប់ឃុំទាំងឡាយដែលចៅក្រម ឬតុលាការបានសម្រេចថាមិនទាន់មានទោសនៅឡើយ ត្រូវចាត់ទុកជាមនុស្ស គ្មានកំហុស ហើយត្រូវបានទទួលការថែទាំដូចមនុស្សធម្មតា។

៣.ដោយពុំឱ្យមានទំនាស់ទៅនិងវិធានស្របច្បាប់ ដែលចែងអំពីកិច្ចការពារសេរីភាពរបស់មនុស្សម្នាក់ៗ ឬអំពីនីតិវិធីដែលត្រូវប្រតិបត្តិតាម ក្នុងករណីដែលជនជាប់ឃុំដែលមិនទាន់កាត់ទោស ពួកគេមានសិទ្ធិទទួលបានកិច្ចការពារតាមរបៀបពិសេសមួយ ដែលមានរៀបរាប់ក្នុងវិធានខាងក្រោមនេះ នៅក្នុងលក្ខខណ្ឌតម្រូវជាមូលដ្ឋានតែប៉ុណ្ណោះ ។

- អ្នកជាប់ឃុំឃាំងដែលគេមិនទាន់កាត់ទោស ត្រូវដាក់ឱ្យនៅដាច់ដោយឡែកអំពីជនជាប់ឃុំដែលបានទទួលការកាត់ទោស និងដាក់ទណ្ឌកម្មរួចហើយ ។
- ជនជាប់ឃុំក្មេងៗ ដែលពុំទាន់ទទួលការកាត់ទោស ត្រូវដាក់ឱ្យនៅដោយឡែកអំពីជនជាប់ឃុំពេញវ័យ ហើយបើតាមគោលការណ៍គួរដាក់ក្មេងៗទាំងនោះនៅក្នុងមន្ទីរដោយឡែក។
- ត្រូវឱ្យអ្នកជាប់ឃុំឃាំងដែលមិនទាន់បានកាត់ទោសត្រូវដេកតែម្នាក់ៗឯងនៅក្នុងបន្ទប់ដោយឡែកពីគ្នា ដោយត្រូវរៀបចំឱ្យមានធាតុអាកាសសមរម្យស្របទៅតាមទម្លាប់នៃតំបន់នីមួយៗរបស់ជនជាប់ឃុំម្នាក់ៗ
- ចំពោះជនជាប់ឃុំប្រភេទនេះ ប្រសិនបើគេចង់ ត្រូវអនុញ្ញាតឱ្យគេទិញម្ហូបអាហារពីខាងក្រៅមក បរិភោគ ទោះតាមរយៈរដ្ឋបាលពន្ធនាគារ ឬតាមរយៈបងប្អូនគ្រួសារ ឬមិត្តភក្តិក្តី។ ការធ្វើបែបនេះ ត្រូវឱ្យស្របទៅតាមក្របខ័ណ្ឌនៃរបៀបរៀបរយរបស់ពន្ធនាគារ។ ផ្ទុយពីករណីនេះ រដ្ឋបាលពន្ធនាគារត្រូវទទួលបន្ទុកផ្តល់ម្ហូបអាហារដល់ពួកគេ ។
- ត្រូវអនុញ្ញាតអោយជនជាប់ឃុំទាំងនោះប្រើសម្លៀកបំពាក់របស់គេ ប្រសិនបើមានភាពស្អាតបាតត្រឹមត្រូវល្អ។ ប្រសិនបើគេត្រូវប្រើសម្លៀកបំពាក់របស់ពន្ធនាគារ សម្លៀកបំពាក់ទាំងនោះមិនត្រូវឱ្យដូចគ្នាទៅនិងខោអាវ របស់ជនជាប់ឃុំដែលត្រូវបានតុលាការបានកាត់ទោសស្អាតរួចហើយនោះទេ។
- ជនជាប់ឃុំដែលមិនទាន់ត្រូវបានកាត់ទោសត្រូវមានឱកាសធ្វើការងារ ប៉ុន្តែមិនមែនជាកាតព្វកិច្ចដែលជនជាប់ឃុំប្រភេទនេះត្រូវតែធ្វើឡើយ។ ប្រសិនបើគេចង់ធ្វើការ គេត្រូវទទួលប្រាក់ឈ្នួលពីការងារនេះ។
- ជនជាប់ឃុំប្រភេទនេះ មានសិទ្ធិទិញ ឬអាចឱ្យបងប្អូនមិត្តភក្តិទិញឱ្យនូវវត្ថុផ្សេងៗដូចជា សៀវភៅ កាសែត គ្រឿងប្រដាប់សរសេរ និងរបស់របរផ្សេងទៀត សម្រាប់ប្រើប្រាស់ឱ្យតែស្របទៅនិងប្រយោជន៍រដ្ឋ

បាលយុត្តិធម៌ និងសន្តិសុខ និងរបៀបរៀបរយល្អរបស់ពន្ធនាគារ។

- ប្រសិនបើឈឺ ហើយជននោះមានលទ្ធភាពគ្រប់គ្រាន់សម្រាប់បង់ថ្លៃព្យាបាលនិងស្របទៅតាមមូលហេតុជាក់ស្តែង ជនជាប់ឃុំប្រភេទនេះមានសិទ្ធិជួលគ្រូពេទ្យ ពីខាងក្រៅមកព្យាបាលនៅក្នុងពន្ធនាគារបាន។
- ជនជាប់ឃុំដែលមិនទាន់បានជំនុំជម្រះក្តី មានសិទ្ធិទទួលបានព័ត៌មានភ្លាមៗអំពីមូលហេតុនៃការឃុំខ្លួន និងអំពីការចោទប្រកាន់របស់ពួកគេ។
- ប្រសិនជនជាប់ឃុំដែលមិនទាន់បានជំនុំជម្រះក្តី មិនមានទីប្រឹក្សាច្បាប់តាមជម្រើសរបស់ខ្លួន ពួកគេមានសិទ្ធិទទួលបានទីប្រឹក្សាច្បាប់ដែលបានជ្រើសតាំងសម្រាប់ពួកគេដោយតុលាការ ឬអាជ្ញាធរផ្សេងទៀត ក្នុងគ្រប់ករណីដែលត្រូវការបំផុតដល់ប្រយោជន៍យុត្តិធម៌ និងដោយគ្មានការបង់ថ្លៃដោយជនជាប់ឃុំ ប្រសិនបើពួកគេមិនមានមធ្យោបាយគ្រប់គ្រាន់ក្នុងការបង់ថ្លៃសេវា។ ការបដិសេធមិនអោយទទួលបានសេវាទីប្រឹក្សាច្បាប់ត្រូវមានការត្រួតពិនិត្យឡើងវិញដោយឯករាជ្យដោយគ្មានបង្អង់ ។
- ជនជាប់ឃុំដែលមិនទាន់ជំនុំជម្រះក្តីត្រូវទទួលបានឯកសារសម្រាប់ការរៀបចំឯកសារការការពារក្តី រួមទាំងសំណួមពរសម្ងាត់ដែលធ្វើឡើងទៅកាន់ទីប្រឹក្សាច្បាប់ ឬអ្នកផ្តល់ជំនួយផ្នែកច្បាប់របស់ពួកគេ។

## ផ្នែកទី២៖ ភាតព្វកិច្ចរបស់ជនជាប់ឃុំ

### ១.ការគោរពបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ

ជនជាប់ឃុំទាំងអស់ត្រូវតែគោរពបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ក្នុងករណីដែលជនជាប់ឃុំបានប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុងដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់ពន្ធនាគារជនជាប់ឃុំនោះមិនត្រូវបានលើកយកមកពិនិត្យលក្ខណវិនិច្ឆ័យសម្រាប់ការបន្ធូរបន្ថយទោស និងលើកលែងទោស ក្នុងរយៈពេលមួយឆ្នាំ។ ក្នុងករណីមិនរាងចាល ត្រូវឃុំខ្លួននៅក្នុងបន្ទប់ដោយឡែក។ ការឃុំខ្លួន ដោយឡែកអាចមានរយៈពេលចាប់ពី១៤ថ្ងៃ ដល់២០ថ្ងៃ។ រយៈពេលឃុំខ្លួននេះអាចនិងត្រូវបន្តបើជនជាប់ទាំងនោះមិនរាងចាលទៀត។

ក្នុងរយៈពេលនៃការទទួលរងទណ្ឌកម្មដោយត្រូវឃុំខ្លួនក្នុងបន្ទប់ដោយឡែកជនជាប់ឃុំមិនត្រូវបានអនុញ្ញាត៖

- ឱ្យជួបគ្រួសារសាច់ញាតិដែលមកសួរសុខទុក្ខ
- ចូលរួមសកម្មភាពផ្សេងៗក្នុងពន្ធនាគារ ។

### ២.ភាតព្វកិច្ចតាមវិធានការណ៍ត្រួតពិនិត្យ

- ទណ្ឌិតត្រូវតែគោរពតាមដីការព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។
- ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ
- ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬបុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យនូវគ្រប់ឯក

សារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ ។

- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន
- ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស ។

**៣.ភាតព្វកិច្ចដោយឡែក**

កាតព្វកិច្ចដោយឡែក ដែលអាចតម្រូវទៅលើទណ្ឌិតមានដូចតទៅះ

- បំពេញសកម្មភាពខាងវិជ្ជាជីវៈ
- ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ
- រស់នៅក្នុងកន្លែងណាមួយជាកំណត់
- ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល
- បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់ថែរក្សាគ្រួសារ
- ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើសតាមលទ្ធភាពនៃធនធានរបស់ខ្លួន
- បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោសតាមលទ្ធភាពធនធានរបស់ខ្លួន
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះតុលាការបញ្ជាក់ពីសកម្មភាពដែលហាមឃាត់ ។
- មិនត្រូវមានមុខនៅទៅកន្លែងខ្លះ ក្នុងករណីនេះតុលាការបញ្ជាក់ពីទីកន្លែងដែលហាមឃាត់
- មិនត្រូវសេពគប់បនល្បែង
- មិនត្រូវសេពគប់តៀមភេសជ្ជៈស្រវឹង
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេសចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះតុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ។
- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទ។

**៤.ភាតព្វកិច្ចមិនលួចរត់**

ជនដែលត្រូវបានតុលាការសម្រេចឃុំខ្លួនដែលហៅថា ជនជាប់ឃុំនោះមានកាតព្វកិច្ចមិនត្រូវគេចវេសឬលួចរត់ចេញពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឡើយ។ ពុំនោះសោតជនទាំងនោះនឹងត្រូវបានផ្តន្ទាទោសបន្ថែមតាមច្បាប់របស់កម្ពុជា។ យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថាការលួចរត់គេចជាអំពើរបស់ជនជាប់ឃុំដែលលួចរត់ចេញពីការឃុំខ្លួនតាមគ្រប់មធ្យោបាយ និងមានការផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី២លានរៀលទៅ៦លានរៀល ។

### ៥.ភាតព្វកិច្ចមិនរក្សាទុក និងមិនប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង

នៅក្នុងពន្ធនាគារ ការរក្សាទុក ការប្រើប្រាស់គ្រឿងញៀនគ្រប់ប្រភេទ និងការរក្សាទុក ការពិសារគ្រឿងស្រវឹងត្រូវបានហាមឃាត់ជាដាច់ខាតចំពោះជនជាប់ឃុំ ក្នុងករណីជនជាប់មួយណាប្រើប្រាស់ ឬលួចប្រើប្រាស់គ្រឿងញៀន និងពិសារគ្រឿងស្រវឹងជនទាំងនោះត្រូវទទួលការពិន័យស្របទៅតាមច្បាប់ស្តីពីពន្ធនាគារ និងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ។ តាមច្បាប់ស្តីពីការត្រួតពិនិត្យ និងប្រើប្រាស់គ្រឿងញៀននៅកម្ពុជាជនគ្រប់រូបដែលប្រើប្រាស់ ឬរក្សាទុកគ្រឿងញៀនគឺជាអំពើខុសច្បាប់ ដូចនេះឃើញថា ការប្រើប្រាស់គ្រឿងញៀនមិនត្រឹមតែត្រូវបានហាមឃាត់នៅខាងក្នុងពន្ធនាគារនោះទេ វាក៏ជាអំពើខុសច្បាប់មួយដែលមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យ និងប្រើប្រាស់គ្រឿងញៀន ។

ក្នុងនោះដែលការពិសារគ្រឿងស្រវឹង និងការរក្សាទុកគ្រឿងស្រវឹងក៏ជាអំពើខុសទៅនិងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារផងដែរ គ្រប់ជនណាដែលល្មើសទៅនិងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារគឺត្រូវទទួលពិន័យស្របទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារផងដែរ ។

ជនជាប់ឃុំទាំងអស់មិនត្រូវបានអនុញ្ញាតឱ្យរក្សាទុកវត្ថុទាំងឡាយណា ដែលអាចបង្ករបួសស្នាមដល់អ្នកដទៃ ឬខ្លួនឯង ឬបង្កឱ្យមានភាពចលាចល និងបាត់បង់សន្តិសុខ សុវត្ថិភាព នៅក្នុងពន្ធនាគារ ។ ជាងនេះទៅទៀតជនជាប់ឃុំមិនត្រូវប្រើប្រាស់ និងរក្សាទុកនូវគ្រឿងញៀន និងគ្រឿងស្រវឹងគ្រប់ប្រភេទ ។

# ជំពូកទី២
# សិទ្ធិទទួលបានការលើកលែងទោស
# និងបន្ធូបន្ថយទោស

# ជំពូកទី២

# សិទ្ធិទទួលបានការលើកលែងទោស និងបន្ធូបន្ថយទោស

## ១. សិទ្ធិទទួលបានការលើកលែងទោស និងបន្ធូបន្ថយទោស

ការលើកលែងទោស និងបន្ធូបន្ថយទោសគឺវិធានការមួយដើម្បីកាត់បន្ថយជនជាប់ឃុំដែលមានចំនួនច្រើនក្នុងពន្ធនាគារ និងជាការអនុគ្រោះចំពោះទណ្ឌិតណាដែលបានប្រព្រឹត្តល្អក្នុងពន្ធនាគារស្គាល់ពីទោសកំហុសរបស់ខ្លួនហើយចេះកែប្រែខ្លួនឡើងវិញ។ ហើយក៏ជាវិធានការមួយសំដៅជំរុញលើកទឹកចិត្តដល់ទណ្ឌិតម្នាក់ៗឱ្យខិតខំកសាងកែប្រែគំនិតមាយាទ ក្លាយជាពលរដ្ឋល្អដើម្បីធ្វើសមាហរណកម្មបញ្ចូលទៅក្នុងសង្គមជាតិវិញបាននៅពេលអនាគត។ យោងតាមច្បាប់ស្តីពីពន្ធនាគារដែលប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ មាត្រា៧៤ ចែងថាអភិបាលនៃគណៈអភិបាលខេត្តរាជធានីត្រូវបង្កើតគណៈកម្មការដើម្បីពិនិត្យនិងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិតក្នុងរយៈពេលជាប់ឃុំនៅក្នុងពន្ធនាគារដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន។ គណៈកម្មាធិការនេះត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណៈសម្បត្តិអាចស្នើសុំបន្ធូបន្ថយទោស និងលើកលែងទោសបញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ តាមរយៈអគ្គនាយនៃអគ្គនាយកដ្ឋានពន្ធនាគារយ៉ាងយឺតបំផុត ៣០ថ្ងៃ មុនថ្ងៃកំណត់នៃពីធីបុណ្យនីមួយៗ ។

➢ **គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម៖**

- អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ប្រធាន
- តំណាងអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត អនុប្រធាន
- ប្រធានក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគាររាជធានី-ខេត្ត អនុប្រធានអចិន្ត្រៃយ៍
- អនុប្រធានពន្ធនាគាររាជធានី-ខេត្ត ទទួលបន្ទុកអប់រំកែប្រែ ជាសមាជិក
- អនុប្រធានពន្ធនាគាររាជធានី-ខេត្តទទួលបន្ទុកប្រតិបត្តិ ជាសមាជិក

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយដីការរបស់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបង្កើតគណៈកម្មការដើម្បីពិនិត្យនិងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិតក្នុងរយៈពេលជាឃុំនៅតាមមណ្ឌលអប់រំកែប្រែដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន។ គណៈកម្មការនេះត្រូវធ្វើបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូបន្ថយទោស និងលើកលែងទោសបញ្ជូនទៅគណៈកម្មការថ្នាក់ជាតិយ៉ាងយឺតបំផុត ៣០ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

➢ **គណៈកម្មការមានសមាសភាពដូចខាងក្រោម៖**

- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកពន្ធនាគារ ជាប្រធាន
- តំណាងអង្គការអយ្យការសាលាដំបូងដែលមានសមត្ថកិច្ចលើមណ្ឌលអប់រំកែប្រែសាមី ជាអនុប្រធាន
- ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ជាអនុប្រធាន
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ជាអនុប្រធានអចិន្ត្រៃយ៍
- ប្រធាននាយដ្ឋានអប់រំកែប្រែ ជាសមាជិក
- ប្រធាននាយកដ្ឋានប្រតិបត្តិ ជាសមាជិក
- ប្រធានក្រុមការងារប្រឡងប្រណាំងនៃមណ្ឌលអប់រំកែប្រែនីមួយៗ ជាសមាជិក

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[11] ។

រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសដែលបានផ្ញើមកពិនិត្យ និងវាយតម្លៃ រួចហើយគណៈកម្មការនេះត្រូវធ្វើបែបបទជូនប្រមុខរដ្ឋាភិបាលពិនិត្យ និងសម្រេចដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រ។ សុំបន្ធូ បន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិតយ៉ាងយឺតបំផុត១០ ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ។

- **គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម៖**

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកពន្ធនាគារ ជាអនុប្រធានអចិន្ត្រៃយ៍
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាអនុប្រធាន
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់ចំនួន១រូប ជាសមាជិក
- ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ជាសមាជិក
- តំណាងក្រសួងយុត្តិធម៌១រូប ជាសមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ជាសមាជិក
- ប្រធាននាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានពន្ធនាគារចំនួន ០២រូប ជាសមាជិក

គណៈកម្មាការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការនេះត្រូវកំណត់ដោយអនុក្រឹត្យតាម សំណើរបស់ក្រសួង

[11] មាត្រា ៧៤ ជំពូកទី៨ នៃច្បាប់ស្តីពីពន្ធនាគារដែលប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

មហាផ្ទៃបន្ទាប់ពីមានការឯកភាពគ្នាពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ម្យ៉ាងវិញទៀតប្រមុខរាជរដ្ឋាភិបាល ក្នុងករណីចំបាច់ក៏មានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឱ្យទណ្ឌិតនៅពេលណាក៏បានដែរ ដោយមិនចាំបាច់មានសំណើពីគណៈកម្មការណាមួយឡើយ ។

## ២. លក្ខខណ្ឌសម្រាប់ធ្វើការលើកលែងទោស និងបន្ធូបន្ថយទោស

**១.ទណ្ឌិតដែលត្រូវបានលើកលែងទោសបំពេញលក្ខខណ្ឌដូចខាងក្រោម ៖**

- ភ្ញាក់រលឹកខិតខំកែប្រែគំនិតមារយាទឱ្យកែប្រែគំនិតមារយាទ ឱ្យក្លាយជាពលរដ្ឋសុចរិត ដើម្បីធ្វើសមាហរណកម្មចូលរួមរស់ក្នុងសង្គមវិញ។
- គោរពប្រតិប្រត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អដល់ទណ្ឌិតនិងជនជាប់ឃុំដទៃទៀត។
- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀងទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្ម ។
- គោពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមសេចក្ដីណែនាំផ្សេងទៀតរបស់ពន្ធនាគារ។

ប្រធានពន្ធនាគារត្រូវធ្វើការវាយតម្លៃ និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌខាងលើរបស់ទណ្ឌិតដែលត្រូវបញ្ចូលឈ្មោះក្នុងបញ្ជីទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី-ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត[12] ។

ការបន្ធូរបន្ថយ និងការលើកលែងទោស អាចអនុវត្តផងដែរក្នុងហេតុផលមនុស្សធម៌ ចំពោះទណ្ឌិតដែលមានវ័យចាស់ជរា ជាស្ត្រីមានគភ៌ ឬមានជំងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ វិបល្លាសស្មារតី ឬពិការភាព ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យដែលទទួលស្គាល់ដោយក្រសួងមានសមត្ថកិច្ច។

ប្រធានពន្ធនាគារត្រូវធ្វើការបញ្ជាក់អំពីការបំពេញលក្ខខណ្ឌតាមស្ថានភាពនីមួយៗរបស់ទណ្ឌិតដូចមានចែងក្នុងកថាខណ្ឌខាងលើ ដើម្បីរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី-ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ[13] ។

២.ទណ្ឌិតត្រូវអនុវត្តទោសរបស់ខ្លួននៅក្នុងពន្ធនាគារចំនួន ២ភាគ៣ ឬបានទទួលរងទោស១៥ឆ្នាំចំពោះទោសដាក់ពន្ធនាគារមួយជីវិតក្នុងករណីដែលខ្លួនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមចំណុចខាងលើសិនទើបមានសិទ្ធិស្នើសុំលើកលែងទោស ។

[12] មាត្រា៥ ជំពូកទី៣ នៃព្រះរាជក្រឹត្យស្ដីពីការបន្ធូរបន្ថយទោស និងលោកលែងទោស

[13] មាត្រា៦ ផ្នែកទី២ នៃព្រះរាជក្រឹត្យស្ដីពីការបន្ធូរបន្ថយទោស និងលោកលែងទោស

៣.ទណ្ឌិតទាំងឡាយណាដែលមានគ្រប់លក្ខណៈសម្បត្តិតាមលក្ខខណ្ឌនៅក្នុងចំណុចទី១អាចត្រូវបានបន្ថយទោស លុះត្រាតែទណ្ឌិតទាំងនោះបានទទួលរងទោស ១ភាគ៣ នៃទោសដាក់ពន្ធនាគារមានកំណត់ ឬបានទទួលរងទោស១០ឆ្នាំជាមុនសិន ចំពោះទោសដាក់ពន្ធគារ១ជីវិត[14]។

៤.ទណ្ឌិតម្នាក់អាចទទួលបានការបន្ថយទោសច្រើនដងក្នុងលក្ខខណ្ឌដែលទណ្ឌិតនោះបានទទួលរងទោសទាំងអស់បានពាក់កណ្តាល នៃទោសដែលតុលាការបានកំណត់។ ចំពោះទណ្ឌិតដែលត្រូវបានដាក់ពន្ធនាគាមួយជីវិត ក្រោយពីបន្ថយទោសមកត្រឹម៣០ឆ្នាំ អាចទទួលបានការបន្ថយទោសបានច្រើនដងក្នុងមួយឆ្នាំ ប៉ុន្តែទោះបីជាទណ្ឌិតនោះត្រូវបន្ថយទោសបានច្រើនដងក៏ដោយក៏រយៈពេលនៃការទទួលរងទោសទាំងអស់ត្រូវឱ្យបាន២០ឆ្នាំដែរ។

៥.មិនត្រូវបានលើកលែងចំពោះជនធ្លាប់ជាប់ទោស ឬជនដែលស្ថិតក្នុងភាពមិនរាងចាលឡើយ ។

## ៣. រយៈពេលនៃការបន្ថយទោស

១. ទោសកំណត់ពី១ឆ្នាំ ដល់ក្រោម៥ឆ្នាំ អាចបន្ថយទោសរយៈពេលជាប់ពន្ធនាគារចំនួន៣ខែ។

២.ទោសកំណត់ពី៥ឆ្នាំ ដល់ក្រោម១០ឆ្នាំអាចនិងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន៦ខែ ឬ៣ខែ។

៣. ទោសកំណត់ពី១០ឆ្នាំ ដល់ក្រោម២០ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន៩ខែ ឬ ៦ខែ ឬ៣ខែ។

៤.ទោសដាក់ពន្ធនាគារកំណត់ពី២០ឆ្នាំ ដល់៣០ឆ្នាំអាចនិងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ១២ខែ ឬ៩ខែ ឬ៦ខែ ឬ៣ខែ ។

៥. ទោសដាក់ពន្ធនាគារមួយជីវិត អាចនិងបន្ថយទោសលើកទី១មកនៅត្រឹម៣០ឆ្នាំ ។

## ៤. ថ្ងៃសម្រាប់ធ្វើការលើកលែងទោស និងបន្ធូបន្ថយទោស

ពិធីបុណ្យដែលអាស្នើសុំការបន្ធូបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ត្រូវកំណត់ ៥ ដងក្នុងមួយឆ្នាំ ដូចតទៅៈ

១- ទិវាជ័យជំម្នេះលើរបបប្រល័យពូជសាសន៍

២- ពិធីបុណ្យចុលឆ្នាំថ្មីប្រពៃណីជាតិ

៣- ពីធីបុណ្យវិសាខបូជា

៤- ពិធីបុណ្យឯករាជ្យជាតិ

[14] មាត្រា៧ ផ្នែកទី២ នៃព្រះរាជក្រឹត្យស្តីពីពីការបន្ធូរបន្ថយទោស និងលោកលែងទោស

៥- ព្រះរាជពិធីបុណ្យអុំទូកបណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក[15] ។

ការបន្ធូរបន្ថយទោសនិងការលើកលែងទោសក៏អាចធ្វើផងដែរក្នុងពិធីបុណ្យឬព្រឹត្តិការណ៍ធំៗរបស់ជាតិ។

ការបន្ធូរបន្ថយទោស និងលើកលែងទោស ក៏អាចធ្វើសម្រាប់ពីធីបុណ្យនីមួយៗខាងលើដាច់ដោយឡែកពីគ្នា ឬរួមគ្នា ។

ក្នុងករណីចាំបាច់ ប្រមុខរដ្ឋាភិបាលមានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឱ្យទណ្ឌិតនៅពេលណាក៏បាន។

## ៥.បែបបទ និងនីតិវិធីនៃការបន្ធូបន្ថយទោស និងការលើកលែងទោស

ប្រធានពន្ធនាគារត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនមកគណៈកម្មការរាជធានី-ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។

គណៈកម្មការរាជធានី-ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ត្រូវពិនិត្យ និងវាយតម្លៃអំពីលក្ខណៈសម្បត្តិរបស់ទណ្ឌិតម្នាក់ៗដែលបំពេញគ្រប់លក្ខខណ្ឌអាចស្នើសុំបន្ធូបន្ថយទោស និងលើកលែងទោស និងត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូបន្ថយទោស និងលើកលែងទោសរួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ ពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូបន្ថយទោស និងលើកលែងទោស យ៉ាងយឺតបំផុត ៣០ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យនេះ។

គំរូបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូបន្ថយទោស និងលើកលែងទោសរួមនិងសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវកំណត់ដោយគណៈកម្មការថ្នាក់ជាតិ។

[15] មាត្រា៣ ជំពូកទី២ នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងលោកលែងទោស

# ជំពូកទី៣
# ការអនុវត្តសិទ្ធិជនជាប់ឃុំក្នុង
# ដំណាក់កាលសវនាការ

# ជំពូកទី៣
# ការអនុវត្តសិទ្ធិជនជាប់ឃុំក្នុងដំណាក់កាលសវនាការ

## ផ្នែកទី១៖ សិទ្ធិរបស់ជនជាប់ឃុំមុនពេលសវនាការ

### ១. សិទ្ធិជនជាប់ចោទនៅមុនពេលចាប់ខ្លួន

ជនត្រូវចោទ ឬ ជនជាប់ចោទ មានសិទ្ធិការពារខ្លួននៅក្រោមច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ។ ដោយគ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឬ ឃុំខ្លួនតាមអំពើចិត្តបានឡើយ លើកលែងតែមានហេតុផល និងភស្តុតាងត្រឹមត្រូវដែលស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់[16]។

ចំពោះការឃុំខ្លួនមុនសវនាការ ជនជាប់ចោទអាចត្រូវបានចាប់ខ្លួន និងឃុំខ្លួនរហូតដល់រយៈ ពេល ២៤ម៉ោង មុននឹងអាចមានមេធាវី ប៉ុន្តែអ្នកជាប់ពន្ធនាគារ ជាធម្មតា ត្រូវជាប់ឃុំជាច្រើនថ្ងៃ មុននឹងអាចជួបមេធាវី ឬជួប សមាជិកគ្រួសារ។ យោងតាមមន្ត្រីរដ្ឋាភិបាល ការឃុំខ្លួនយូរបែបនេះ ភាគច្រើនបណ្តាលមកពីសមត្ថភាពមាន កម្រិតរបស់ប្រព័ន្ធតុលាការ។ ច្បាប់អនុញ្ញាតឱ្យមានការឃុំខ្លួនមុនសវនាការរហូតដល់រយៈពេល ៦ ខែ ចំពោះ បទល្មើសមជ្ឈិម និង ១៨ ខែ ចំពោះបទឧក្រិដ្ឋ។ តែអង្គការមិនមែនរដ្ឋាភិបាលបាននិយាយថា អាជ្ញាធរឃុំអ្នកដែលត្រូវបានចោទខ្លះ មុនសវនាការ លើសរយៈពេលអតិបរិមាដែលកំណត់ដោយច្បាប់។ ពេលខ្លះ អាជ្ញាធរឃុំមនុស្សមុនសវនាការដោយគ្មានតំណាងផ្នែកច្បាប់ត្រឹមត្រូវ។ម្យ៉ាងទៀត លទ្ធភាពរបស់អ្នកជាប់ឃុំក្នុងការចោទសួរពីភាពស្របច្បាប់នៃការឃុំខ្លួនមុនចូលតុលាការ សំណុំរឿងនៅគរមិនទាន់ចាត់ការ និងការពន្យារពេលយូរក្នុងការទទួលបានសាលដីការប៉ះពាល់ដល់សិទ្ធិក្នុងការធ្វើការតតាំងនៅក្នុងតុលាការប្រឆាំងនឹងមូលដ្ឋានច្បាប់ ឬលក្ខណៈធ្វើតែតាមទំនើងចិត្តនៃការឃុំខ្លួនមនុស្ស ជាហេតុបណ្តាលឱ្យបាត់បង់តម្លាភាព និងប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជនជាប់ឃុំយ៉ាងខ្លាំង ។

ដូចនេះហើយយើងគួរគម្បីយល់ដឹងពីសិទ្ធិសំខាន់ៗរបស់ជនជាប់ចោទមុនពេលសវនាការរួមមាន សិទ្ធិត្រូវបានគេសន្មតថាមិនមានកំហុសរហូតទាល់តែត្រូវបានតុលាការកាត់សេចក្តីថាមានទោស សិទ្ធិទទួលបានដំណឹងពីបទចោទ សិទ្ធិដឹងពីមូលហេតុនៃការចាប់ខ្លួន សិទ្ធិបង្ហាញខ្លួនចំពោះមុខចៅក្រម សិទ្ធិដឹងឮ នូវភស្តុតាង និងព័ត៌មាន សិទ្ធិជនជាប់ចោទក្នុងដំណាក់កាលឃុំខ្លួនបណ្តោះអាសន្ន សិទ្ធិទទួលបានដំណឹងពីថ្ងៃជំនុំជំរះ សិទ្ធិទទួលបានការជំនុំជំរះដោយមិនពន្យាពេលយូរ សិទ្ធិបង្ហាញភស្តុតាង សិទ្ធិមិនត្រូវបានគេបង្ខំឱ្យឆ្លើយ ឬ សារភាពដាក់បន្ទុកមកលើខ្លួន សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម និងសិទ្ធិផ្សេងៗជាច្រើនទៀតក្នុងដំណាក់កាលមុនពេលចាប់ខ្លួន។

[16] យោងមាត្រា៩ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

### ១.១ សិទ្ធិទទួលបានដំណឹងពីបទចោទ

គ្រប់ជនជាប់ចោទទាំងអស់មានសិទ្ធិឱ្យគេប្រាប់ភ្លាមៗ ពីបទដែលត្រូវគេចោទមកលើខ្លួន។ ហើយនគរបាលយុត្តិធម៌មានកាតព្វកិច្ចត្រូវតែប្រាប់បទចោទដែលនាំឱ្យមានការចាប់ខ្លួននោះ សូម្បីតែចៅក្រមស៊ើបអង្កេតនៅ ពេលដែលធ្វើការសាកសួរចម្លើយដល់ជនជាប់ចោទ ក៏មានកាតព្វកិច្ចប្រាប់អំពីបទដែលត្រូវចោទប្រកាន់ដែរ ព្រោះថាសិទ្ធិនេះត្រូវអនុវត្តគ្រប់ដំណើរការនៃនីតិវិធីព្រហ្មទណ្ឌ ជាពិសេសវាមានសារៈសំខាន់នៅក្នុងពេលសវនាការ។ ម្យ៉ាងទៀតការដែលធ្វើដូចនេះ ក្នុងគោលបំណងឱ្យជនជាប់ចោទមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំឯកសារ ឬ ភស្តុតាងក្នុងការការពារក្តីរបស់ខ្លួន ។

### ១.២ សិទ្ធិដឹងពីមូលហេតុនៃការចាប់ខ្លួន

នៅពេលដែលត្រូវបានចាប់ខ្លួន ជនជាប់ចោទចាំបាច់ត្រូវដឹងថា ការចាប់ខ្លួននេះបណ្តាលមកពីមូលហេតុអ្វី ហើយខ្លួនបានប្រព្រឹត្តអំពើល្មើសច្បាប់អ្វីខ្លះ និងមានសំណៅឯកសារ ភស្តុតាងគ្រប់គ្រាន់ដែរ ឬ ទេក្នុងការចាប់ខ្លួន។ ដូច្នេះ នគរបាលយុត្តិធម៌ត្រូវប្រាប់លំអិតដល់សាមីខ្លួន និង ភស្តុតាងនានាដែលបង្កឱ្យមានការចាប់ខ្លួននេះឡើង។ ចំណែកឯច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិមាត្រា៦៦ ចែងថា ក្នុងកំឡុងពេលមួយសមស្របមុនសវនាការ ជននោះត្រូវទទួលបាននូវរាល់សំណុំឯកសារស្តីពីការចោទប្រកាន់ ដែលតំណាងអយ្យការនឹងនាំយកមកក្នុងពេលជំនុំជំរះ[17]។ ដូច្នេះជនសង្ស័យ ឬជនជាប់ចោទមានសិទ្ធិគ្រប់បែបយ៉ាងក្នុងការទាមទារឱ្យគេប្រាប់ភ្លាមៗនូវមូលហេតុ និងប្រភេទបទល្មើសដែលបានចោទប្រកាន់មកលើខ្លួន។

### ១.៣ សិទ្ធិបង្ហាញខ្លួនចំពោះមុខចៅក្រម

បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ និងត្រូវបាននាំខ្លួនទៅចំពោះមុខតុលាការ ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលដ៏ខ្លីបំផុត និងត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ។ ប៉ុន្តែការឱ្យនៅក្រៅឃុំ ត្រូវតែមានការធានា ការចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬដំណាក់កាលដទៃទៀតនៃនីតិវិធី និងត្រូវមានមុខក្នុងការអនុវត្តន៍សាលក្រម[18]។ ពីព្រោះរាល់ជនសង្ស័យ ឬជនជាប់ចោទត្រូវបាននគបាលយុត្តិធម៌ឃុំខ្លួនត្រឹមតែ៤៨ម៉ោងប៉ុណ្ណោះដើម្បីរៀបចំកសាងសំណុំរឿង ប៉ុន្តែថេរវេលានឹងត្រូវបានបន្តប្រសិនបើស្ថានភាពក្នុងការដឹកជញ្ជូនឆ្ងាយដែលប្រឈមនិងការជួបប្រទះ

[17] មាត្រា ៦៦ ច្បាប់លក្ខន្តិកៈទីក្រុងរូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

[18] យោងមាត្រា៩ ចំណុច(៣) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

នឹងបញ្ហាផ្សេងក្នុងពេលអនុវត្តន៍។ បន្ទាប់ពីការចាប់ខ្លួនជនជាប់ចោទមានសិទ្ធិក្នុងការទៅបង្ហាញខ្លួនឱ្យបានឆាប់រហ័សដើម្បីឱ្យតុលាការធ្វើការសម្រេចសេចក្ដីនេះ ពោលគឺជនជាប់ចោទអាចស្នើទៅចៅក្រមដើម្បីសុំឱ្យនៅក្រៅឃុំបណ្ដោះអាសន្នថែមទៀតផង ។

### ២. សិទ្ធិការពារខ្លួននៅពេលចាប់ខ្លួន

សិទ្ធិនេះ ត្រូវបានការពារដោយច្បាប់ច្បាប់រដ្ឋធម្មនុញ្ញជាតិ និងលិខិតតូបករណ៍អន្តរជាតិដូចជា កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ សេចក្ដីថ្លែងការណ៍ជាសកលស្ដីពី សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានចែងថា ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ តាមសិទ្ធិជនជាប់ចោទអាចលើកយកភស្ដុតាង សាក្សីទាំងឡាយណាដែលមានប្រយោជន៍ក្នុងការដោះបន្ទុក ដើម្បីឱ្យរួចផុតពីការចោទប្រកាន់របស់ព្រះរាជអាជ្ញា មិនតែប៉ុណ្ណោះ ជនជាប់ចោទក៏មានសិទ្ធិក្នុងការស្វែងរកមេធាវី ឬ ទីប្រឹក្សាដើម្បីធ្វើជាជំនួយការខាងផ្លូវច្បាប់[19]ក្នុងការដោះបន្ទុក ។

ស្របគ្នានេះដែរជនជាប់ចោទក៏មានសិទ្ធិបង្ហាញជូននូវភស្ដុតាង និង ការបកស្រាយច្បាប់ដល់តុលាការក្នុងកិច្ចការពារខ្លួន ដោយខ្លួនឯង ឬ តាមរយៈជំនួយផ្នែកច្បាប់ តាមរយៈការជ្រើសរើសរបស់ជនជាប់ចោទនោះ។ ដូច្នេះសិទ្ធិការពារខ្លួនជាសិទ្ធិមួយដែលមានប្រយោជន៍ និងមានសារៈសំខាន់បំផុតពីព្រោះវាអាចជួយជនជាប់ចោទមានឱកាសកាន់តែច្រើនដើម្បីឱ្យខ្លួនរួចពីការចោទប្រកាន់។ ជាពិសេសការដោះស្រាយតាមប្រព័ន្ធផ្លូវច្បាប់ និង ទទួលបានជំនួយពីមេធាវី បន្ថែមទៀត ។

### ៣. សិទ្ធិដឹងឮ នូវភស្តុតាង និងព័ត៌មាន

ក្នុងរឿងព្រហ្មទណ្ឌច្បាប់កម្ពុជាបានការពារដល់ជនជាប់ចោទដែលស្ថិតក្នុងដំណាក់កាលនានារាប់ចាប់តាំងពីដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌រហូតដល់ដំណាក់កាលជំនុំជម្រះ ។ ក្នុងដំណាក់កាលជំនុំជម្រះនេះ ជនដែលត្រូវបានទទួលការឃុំខ្លួនបណ្ដោះអាសន្ន ហើយស្ថិតក្នុងការរងចាំសវនាការក៏មានសិទ្ធិដឹងលឺនូវភស្ដុតាងដែលគេបានរកឃើញនានា ដោយមិនត្រូវការបិទបាំងអ្វីឡើយ ។ ម៉្យាងទៀតសិទ្ធិក្នុងការដឹងលឺអំពីភស្ដុងតាងនេះពិតជាមានសារៈសំខាន់ណាស់ ព្រោះដើម្បីឱ្យជនជាប់ឃុំទទួលបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទនៃបទចោទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ[20]។ ដើម្បីឱ្យជនជាប់ចោទទាំងនោះមានពេលវេលាគ្រប់គ្រាន់សម្រាប់រកភស្ដុតាង សាក្សី ការពារខ្លួន ក្នុងដំណាក់កាលជំនុំជម្រះរបស់ចៅក្រម ។

[19] មាត្រា ៣៨ (៨) រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[20] យោងមាត្រា១៤ ចំណុច៣ (ក) កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

### ៤.សិទ្ធិជនជាប់ចោទក្នុងដំណាក់កាលឃុំខ្លួនបណ្ដោះអាសន្ន

នៅក្នុងដំណាក់កាលនៃកាលឃុំខ្លួននេះ ជនជាប់ចោទគឺមានសិទ្ធិដូចពលរដ្ឋធម្មតាដែរ (តាមគោលការណ៍សន្មតថាគ្មានទោស) ប៉ុន្តែត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងពន្ធនាគារ ដែលត្រូវបានផ្ដល់ឱ្យនៅពេលដែលពួកគេចូលមកដល់ ។ ករណីនេះក៏ត្រូវបានផ្ដល់ឱកាស ដើម្បីឱ្យជនជាប់ចោទធ្វើការប្ដឹងតវ៉ាតាមផ្លូវច្បាប់លើបុគ្គលណាមួយបានផងដែរ[21]។ ប៉ុន្តែសម្រាប់ជនជាប់ចោទដែលត្រូវបានឃុំឃាំងវិញ គឺមានសិទ្ធិពិសេសខុសពីទណ្ឌិត ព្រោះថាជនជាប់ចោទត្រូវបានគេចាត់ទុកថាគ្មានទោស រហូតដល់ពិរុទ្ធរបស់ខ្លួន ត្រូវបានកំណត់ដោយច្បាប់[22] ហើយត្រូវទទួលបានការមើលថែដ៏យកចិត្តទុកដាក់ផងដែរ។ ចំពោះការឃុំឃាំងនៅមុនពេលសវនាការ ក៏ត្រូវបានដាក់ឱ្យនៅដាច់ដោយឡែកពីទណ្ឌិតដែរ។ ពន្ធនាគារត្រូវមានទំហំសមស្របមានភ្លើង បង្គន់អនាម័យ និងឧបករណ៍សម្រាប់ងូតទឹកលាងសំអាតខ្លួន[23]ត្រឹមត្រូវ។ អ្នកជាប់ពន្ធនាគារត្រូវមានគ្រែដាច់ដោយឡែក កន្លែងដេក និងសំលៀកបំពាក់ប្រកបដោយអនាម័យ ម្ហូបអាហារដែលមានជីវជាតិ គ្រប់គ្រាន់សម្រាប់សុខភាព និងកម្លាំងកាយ ទឹកបរិភោគស្អាត និងពេលមួយម៉ោងជារៀងរាល់ថ្ងៃដើម្បីហាត់ប្រាណ[24] ក្នុងអំឡុងពេលឃុំខ្លួន ។

### ៥. សិទ្ធិទទួលបានការជំនុំជំរះដោយមិនពន្យាពេលយូរ

សិទ្ធិនេះគឺជាគោលការណ៍មួយនៃនីតិវិធីព្រហ្មទណ្ឌ ដែលចេញពីការសន្មត់ទុកជាមុនថាគ្មានទោស រហូតដល់មានសាលក្រមចូលជាស្ថាពរ និងជាសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជំរះនៅក្នុងរយៈពេលដ៏សមរម្យមួយដែលមិនពន្យាពេលយូរ[25]។ ហើយការជំនុំជំរះជនជាប់ចោទក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាយើងនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ៦ខែ ចាប់តាំងពីថ្ងៃចាប់ខ្លួន ។

ដូចនេះ ប្រសិនបើមានការពន្យាពេលក្នុងការការស៊ើបអង្កេត ឬការឃុំខ្លួនហួសកំណត់ដោយមិនបានបើកសវនាការ គឺជាការរំលោភបំពានមួយដែលមិនសមហេតុផលក៏ដូចជាការរំលោភសិទ្ធិរបស់បុគ្គលផងដែរ ដោយសារការពន្យាពេលយូរក្នុងការនាំខ្លួនជនជាប់ចោទមកសវនាការ ជាការរំលោភសិទ្ធិជាមូលដ្ឋានរបស់បុគ្គលដល់ដំណើរការសវនាការដោយយុត្តិធម៌ពីព្រោះវាអាចមានបុរេវិនិច្ឆ័យចំពោះសមត្ថភាពជនជាប់ចោទក្នុងការបង្ហាញនូវការការពារឱ្យមានប្រសិទ្ធិភាព។ ព្រោះថាសាក្សីសំខាន់ៗអាចនិងត្រូវ បាត់ខ្លួន ឬស្លាប់

---

[21] មាត្រា ៣៥ នៃបទប្បញ្ញាតិជាបទដ្ឋានអប្បរមាសម្រាប់គ្រប់គ្រងអ្នកទោស

[22] មាត្រា១៤ ចំណុច៣(ខ)នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[23] មាត្រា១០ ដល់មាត្រា១៣ នៃបទប្បញ្ញាតិជាបទដ្ឋានអប្បរមាសំរាប់គ្រប់គ្រងអ្នកទោស

[24] មាត្រា១៧ ដល់មាត្រា២១ នៃបទប្បញ្ញាតិជាបទដ្ឋានអប្បរមាសំរាបើគ្រប់គ្រងអ្នកទោស

[25] មាត្រា១៤ ចំណុច៣ (គ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ចំណែកឯភស្តុតាងសំខាន់ៗក៏អាចប្រឈមនិងការបាត់បង់បានដែរ។ ដោយសារការពន្យាពេលយូរ អាចធ្វើឱ្យការជំនុំជំរះមិនអាចប្រកបដោយភាពយុត្តិធម៌បាន។

ក្នុងនោះដែរ ជនជាប់ចោទក៏មានសិទ្ធិទទួលបានដំណឹងពីថ្ងៃជំនុំជំរះ ដែលតុលាការមានសមត្ថកិច្ចត្រូវជូនដំណឹងពីថ្ងៃជំនុំជំរះនេះឱ្យបានមុនរយៈពេល១៥ថ្ងៃមុន។ការជូនដំណឹងនេះគឺដើម្បីឱ្យជនជាប់ចោទមានពេលវេលាគ្រប់គ្រាន់សម្រាប់ជួបទីប្រឹក្សា ឬមេធាវីរបស់ខ្លួនដើម្បីឱ្យពួកគេអាចធ្វើការរៀបចំពិនិត្យឯកសារផ្សេងៗ ជាពិសេសពិនិត្យរកភស្តុតាងនិងសាក្សីដឹងលឺនានាសម្រាប់ការពារខ្លួនចំពោះមុខព្រះរាជអាជ្ញានៅពេលសវនាការ។ដោយសារសាក្សីខ្លះអាចនិងនៅឆ្ងាយពិបាកក្នុងការធ្វើដំណើរឬត្រូវប្រើរយៈពេលយូរសម្រាប់មកសវនាការ។

### ៦. សិទ្ធិបង្ហាញភស្តុតាង

នៅក្នុងដំណាក់កាលនេះគឺជាដំណាក់កាលមួយដែលជនជាប់ចោទត្រូវលើកយកភស្តុតាងណាដែលមានប្រយោជន៍ក្នុងការជួយដោះបន្ទុកឱ្យខ្លួន ដើម្បីប្រឆាំងទៅនឹងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា ការបង្ហាញនេះជនជាប់ចោទអាចលើកយកមកបង្ហាញដោយខ្លួនឯងក៏បាន ឬតាមរយៈទីប្រឹក្សា ឬតាមរយៈមេធាវីក៏បាន។ តែបើយើងគិតពីគោលការណ៍នៃការសន្មត់ជាមុនថាគ្មានទោសនោះ ជនជាប់ចោទត្រូវបានចាត់ទុកថាជាមនុស្សគ្មានទោសរហូតដល់តុលាការបានរកឃើញ ទោសកំហុស មានន័យថា បន្ទុកនៅក្នុងការបង្ហាញភស្តុតាងគឺជាការទទួលខុសត្រូវរបស់តំណាងអយ្យការក្នុងការបង្ហាញនូវរាល់ធាតុផ្សំនីមួយៗពីបទចោទលើសពីវិមតិសង្ស័យ។

### ៧. សិទ្ធិមិនត្រូវបានគេបង្ខំឱ្យឆ្លើយ ឬ សារភាពដាក់បន្ទុកមកលើខ្លួន

ចម្លើយសារភាពទាំងឡាយណាដែលបានមកពីការបង្ខិតបង្ខំ ឬ ប្រើនូវ ទារុណកម្មណាមួយ មិនត្រូវបានយកជាការនោះទេ។ ដោយសារជនគ្រប់រូបទាំងអស់ត្រូវបានសន្មត់ជាមុនថាគ្មានទោសរហូតដល់តុលាការរកឃើញថាមានទោស ដូចនេះគ្មានជនណាម្នាក់ត្រូវបានបង្ខំឱ្យផ្តល់ភស្តុតាងដែល ផ្ទុយនឹងអ្វីដែលគេមិនបានប្រព្រឹត្តនោះឡើយ[26]។ **ឧទាហរណ៍** នៅក្នុងពេលបច្ចុប្បន្ន ប៉ូលីសតែងតែប្រើនូវទារុណកម្មយ៉ាងកាចសាហាវដូចមានករណីមួយនៅក្នុងពេលដែលប៉ូលិសចាប់ចោរបានម្តងៗ គឺតែងតែប្រើអំពើហិង្សាដោយរួមមានឆក់ខ្សែភ្លើង វៃដោយប្រើស្នាប់ដៃ ទាត់និងស្បែកជើងជាដើម។

ការប្រើប្រាស់មធ្យោបាយបង្ខិតបង្ខំលើ រាងកាយក្តី ឬ ផ្លូវចិត្តក្តី ពេលខ្លះយើងគិតថា ជាមធ្យោយឆាប់បំផុតក្នុងការស្វែងរកការពិត។ ក៏ប៉ុន្តែមនុស្សភាគច្រើននៅពេលដែលទទួលរងនូវការឈឺចាប់ក្នុងអំឡុងពេល

---

[26] មាត្រា១៤ (៣) ចំណុច ឆ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ធ្វើទារុណកម្មប្រាកដណាស់ថាមិននិយាយអ្វីទាំងអស់។ បើទោះជាបានឆ្លើយ មិនថាចម្លើយស្រប ឬ ចម្លើយបដិសេធនោះទេ ពោលគឺធ្វើយ៉ាងណាដើម្បី បញ្ចប់ការធ្វើទារុណកម្មមកលើខ្លួនតែប៉ុណ្ណោះ។ ចំពោះវិធីសាស្ត្រដែលមានប្រសិទ្ធិភាពបំផុតក្នុងការរកការពិត គឺត្រូវបង្ហាញនូវភស្តុតាងដោយគ្មានការបំខិតបង្ខំ ពោលគឺឱ្យជនទាំងនោះទទួលស្គាល់នូវអ្វីដែលខ្លួនបានប្រព្រឹត្ត ឬទទួលស្គាល់នូវទង្វើដែលខ្លួនបានធ្វើ។ ដូច្នេះហើយទើបមានបណ្តាលប្រទេសជាច្រើននៅលើសកលលោកបានធ្វើការហាមប្រាមមិនឱ្យប្រើប្រាស់ចម្លើយសារភាពអំឡុងពេលធ្វើទារុណកម្មដែលជនជាប់ចោទ ទបានរៀបរាប់ប្រាប់ដល់នគរបាលយុត្តិធម៌ធ្វើជាភស្តុតាងទាំងស្រុងនោះទេ។ ប៉ុន្តែមានតែក្នុងករណីដូចខាងក្រោមទេទើបជនជាប់ចោទអាចទទួលការកាត់ទោសដោយផ្អែកលើភស្តុតាងទាំងស្រុងបាន ។

**ឧទាហរណ៍** : ជនជាប់ចោទបានសារភាពប្រាប់នគរបាលថា គាត់បានប្លន់អ្នកលក់មាសដោយភ្ជង់កាំភ្លើង ហើយគាត់បានក្រវែងកាំភ្លើងនោះចោលទៅក្នុងត្រពាំងមួយនៅតំបន់ដែលគ្មានម្ចាស់កាន់កាប់ ហើយគាត់បាន ចង្អុលមាសដែលគាត់ប្លន់បាននៅកន្លែងមួយផ្សេងទៀត។ ជនរងគ្រោះស្គាល់អត្តសញ្ញាណរបស់ជនជាប់ចោទនៅពេល រៀបមនុស្សឱ្យឈរជាជួរ ហើយបានចង្អុលចំអ្នកដែលជាចោរប្លន់មាសរបស់គាត់ បន្ទាប់មកនគរបាលបាន ឆែកឆេរត្រពាំងហើយក៏ប្រទះឃើញកាំភ្លើងនោះ។ នគរបាលទៅកន្លែងមួយផ្សេងទៀតក៏ឃើញមាសដែលចោរលួចបាន។ ឥឡូវនេះនគរបាលមានភស្តុតាង៣យ៉ាងដែលស្របទៅនឹងការសារភាពរបស់ជនជាប់ចោទ។ ចំណែកឯជនជាប់ចោទ និងប្រឈមមុខនិងការទទួលទោសនូវទង្វើដែលគេបានប្រព្រឹត្តដែរ។

### ៨. សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម

សិទ្ធិនេះមានការទាក់ទងដោយផ្ទាល់ទៅដល់សេចក្តីសុខផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ពីព្រោះនគរបាលយុត្តិធម៌មួយចំនួន មិនបានយល់ច្បាស់អំពីច្បាប់ ពោលគឺតែងចាត់ទុកជនជាប់ចោទថាមានទោសដោយចូលចិត្តប្រើនូវទារុណកម្ម ដ៏កាចសាហាវក្នុងកំឡុងពេលឃុំខ្លួន។ ការធ្វើឱ្យមានការឈឺចាប់ ទាំងផ្លូវកាយ និង ផ្លូវចិត្ត ដែលបង្កឡើងដោយអាជ្ញាធរសាធារណៈ ដើម្បីបង្ខំយកចម្លើយសារភាព ឬហេតុផលផ្សេងៗដែលឈរលើមូលដ្ឋាននៃការរើសអើងនោះ ត្រូវបានចាត់ទុកថាជាការធ្វើទារុណកម្ម ពោលគឺគ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬ ទណ្ឌកម្មដែលឃោរឃៅអមនុស្សធម៌ ឬ ធ្វើឱ្យថោកទាបឡើយ[27]។

ដូច្នេះរាល់ទណ្ឌកម្មលើរូបរាងកាយ ទណ្ឌកម្មដោយដាក់គុកងងឹត និងទណ្ឌកម្មទាំងឡាយណាដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប នាំឱ្យបាត់បង់តម្លៃជាមនុស្ស ត្រូវបានហាមឃាត់ជាដាច់

[27] មាត្រា៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ខាត។ ហើយសិទ្ធិនេះក៏ត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣មាត្រា៣៥ បានចែងថា ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តអំពើណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនឱ្យធ្វើឡើយ។ ចំពោះអ្នកចូលរួមប្រព្រឹត្ត និងអ្នកសមគំនិត ក៏ត្រូវទទួលទោសដូចគ្នាដែរ[28]។ លើសពីនេះទៅទៀតរាល់ជនជាប់ចោទនីមួយៗក៏មានសិទ្ធិស្នើរសុំដល់នគរបាលយុត្តិធម៌ឃុំឃាំង ព្រោះដើម្បីការពារនូវរាល់បទល្មើសផ្សេងៗដែលអាចនិងកើតមានឡើង ដូចជាការលួចសម្លាប់ជនជាប់ចោទក្នុងមន្ទីរឃុំឃាំងជាដើម។

### ៩. សិទ្ធិមានមេធាវី

សិទ្ធិមានមេធាវីគឺជាសិទ្ធិមួយដែលសំខាន់របស់ជនជាប់ចោទនៅគ្រប់ដំណាក់កាលនៃរឿងក្តី ជនជាប់ចោទក៏មានសិទ្ធិជ្រើសរើសមេធាវីដែលលមានបទពិសោធន៍ ដើម្បីការពារដល់ខ្លួនបានដែរ ជាពិសេសចំពោះបុគ្គលដែលត្រូវបានគេចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ។ បុគ្គលនោះមានសិទ្ធិស្វែងរកមេធាវីដែលខ្លួនពេញប្រកប ដោយសមត្ថភាព និងបទពិសោធន៍ច្បាស់លាស់។ ដើម្បីទទួលខុសត្រូវ ក្នុងការការពាររឿងក្តីរបស់ខ្លួន ។

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការក្រៅរដ្ឋាភិបាល ដែលមានជំនាញពិសេសក្នុងការការពារក្តី ចំពោះកិច្ចការដ៏សំខាន់នេះមិនត្រូវទុករហូតដល់ ក្រោយពេលចាប់ខ្លួននោះទេ។ ក្រោយពេលជនសង្ស័យដឹងថាខ្លួនកំពុងស្ថិតនៅក្រោមការតាមដាន ឬស៊ើបអង្កេតគួរតែពិគ្រោះជាមួយមេធាវីឱ្យបានឆាប់រហ័ស ។ នៅពេលជនជាប់ចោទត្រូវបានគេនាំយកមកនៅមុខចៅក្រមស៊ើបអង្កេត ក្នុងកាលៈទេសៈមិនមានមេធាវី ជនជាប់ចោទនោះមានសិទ្ធិជ្រើសរើសមេធាវីណាម្នាក់សម្រាប់ការពារខ្លួនបាន ដោយហេតុថាជនជាប់ចោទស្ថិតនៅក្រោមការឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេត ដូចនេះចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចជួយដល់ជនជាប់ចោទក្នុងការផ្តល់ពត៌មានទាក់ទង និងការជ្រើសរើសមេធាវី។ ដោយឱ្យចៅក្រម ស៊ើបអង្កេត ធ្វើការទាក់ទងមេធាវីណាម្នាក់ ឬ ស្នើសុំទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចាត់តាំង មេធាវីម្នាក់ឱ្យមកការពារក្តីដល់ជនជាប់ចោទ។ បន្ទាប់មកទៀត ចៅក្រមស៊ើបអង្កេតត្រូវពន្យាការសួរចម្លើយដល់ជនជាប់ចោទរហូតដល់មេធាវីបានមកដល់។ គ្រប់សំណុំរឿងទាំងអស់ដែលពាក់ព័ន្ធនិងបទឧក្រិដ្ឋ ឬ នីតិជនក្តី អនីតិជនក្តី សុទ្ធតែមានសិទ្ធិរកមេធាវីទាំងអស់[29]។

នៅពេលដែលទទួលបានការចាត់តាំងមក មេធាវីមានសិទ្ធិពេញលេញក្នុងការទំនាក់ទំនងជាមួយ

[28] មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[29] មាត្រា៣០១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

កូនក្តីដោយសេរី និង ទទួលបានពត៌មានពីតុលាការ ដើម្បីធ្វើការទាក់ទងក្នុងសំណុំរឿងរបស់កូនក្តីខ្លួន រួមទាំងសិទ្ធិក្នុងការថតចម្លងរាល់ឯកសារទាំងឡាយណាដោយផ្អែកលើច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧៨១ បានចែងថា សំណុំរឿងត្រូវទុកឱ្យមេធាវី ឬ អ្នកការពារសិទ្ធិពិនិត្យមើលបានគ្រប់ពេលវេលា ការជូនសំណុំរឿងឱ្យមើលនេះត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជី ឬធ្វើនៅក្នុងបន្ទប់ចៅក្រមស៊ើបអង្កេត ប្រសិនបើទីកន្លែងនោះអាចទទួលឱ្យធ្វើបាន[30]។

ចំពោះមេធាវី ឬ អ្នកការពារសិទ្ធិដល់កូនក្តី អាចត្រូវបានអនុញ្ញាតឱ្យ ថតចម្លងរាល់ឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងក្រោមការទទួលខុសត្រូវរបស់ខ្លួនទាំងស្រុង។ ហើយមាត្រា ១៧ ច្បាប់ព្រហ្មទណ្ឌអន្តរកាលបានបន្ថែមទៀតថាប្រសិនបើចៅក្រមសម្រេចថា និងត្រូវធ្វើស៊ើបអង្កេតទៀតតាមលំដាប់លំដោយនៃការស៊ើបអង្កេត នោះទីប្រឹក្សារបស់ជនជាប់ចោទ ត្រូវតែបានទទួលដំណឹងជាបន្ទាន់អំពីភស្តុតាងថ្មីមួយទៀតដែលប្រឆាំងនឹងកូនក្តី របស់ខ្លួន[31]។ ចំណែកឯទីប្រឹក្សាមានសិទ្ធិទទួលសំណុំរឿងជាអ្នកបំពេញដោយគ្រាន់តែស្នើរសុំជាលាយលក្ខណ៍អក្សរទៅគ្រប់ដំណាក់កាលនៃនីតិវិធីហើយអាចទទួលបានពីចៅក្រមនៅគ្រប់លទ្ធផលដែលបានមកពីការស៊ើបអង្កេតអំពីសេចក្តីរាយការណ៍របស់អ្នកជំនាញដែលខ្លួនយល់ថាមានប្រយោជន៍ក្នុងការការពារកូនក្តីរបស់ខ្លួន ។

## ១០. សិទ្ធិប្រាស្រ័យជាមួយសាច់ញាតិ

ជាធម្មតាសិទ្ធិសេរីភាពក្នុងការជួបប្រាស្រ័យទាក់ទងគ្នា ជាសិទ្ធិមួយដែលត្រូវបានទទួលស្គាល់ដោយប្រទេសជាច្រើននៅលើសកលលោកបើទោះបីជាប្រទេសនោះប្រកាន់យករបបនយោបាយបែបណាក៏ដោយ។ ប៉ុន្តែសម្រាប់ជនជាប់ចោទ ទោះជាជនមួយដែលត្រូវបានគេដកហូតនូវសិទ្ធិសំខាន់ៗមួយចំនួនចេញក៏ដោយ តែសិទ្ធិក្នុងការប្រាស្រ័យទាក់ទងគ្នាជាមួយ ឪពុកម្តាយ បងប្អូន មិត្តភក្តិ មិនត្រូវបានបាត់បង់នោះទេ។ ពោលគឺពួកគេនៅតែមានសិទ្ធិជួបជាមួយសាច់ញាតិ តែត្រូវជួបតាមថេរវេលាដែលមន្ទីរឃុំឃាំងជាអ្នកកំណត់។ជួនកាលនៅពេលដែលសាច់ញាតិជនជាប់ចោទមកសួរសុខទុក្ខគាត់អាចនាំមកនូវដំណឹងសំខាន់ៗ ឬភស្តុតាងនានាដែលមានប្រយោជន៍ ពោលគឺអាចជួយជនជាប់ចោទឱ្យយកមកធ្វើជាសំអាងក្នុងពេលពេលបើកសវនាការបាន។

ដូច្នេះជនជាប់សង្ស័យទាំងអស់ត្រូវបាន អនុញ្ញាតឱ្យទាក់ទងជាមួយក្រុមគ្រួសារ សាច់ញាតិ និងមិត្តភក្តិ តាមរយៈសំបុត្រឆ្លើយឆ្លងក្តី ឬតាមរយៈការមកសួរសុខទុក្ខដោយផ្ទាល់ក្តី។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ

[30] មាត្រា៧៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[31] មាត្រា១៧ ច្បាប់ព្រហ្មទណ្ឌអន្តរកាល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការទាក់ទងជាមួយគ្រួសារ សាច់ញាតិ និង មិត្តភក្តិនេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យជាចាំបាច់។ លើសពីនេះទៅទៀតជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យជូនព័ត៌មានដល់គ្រួសាររបស់ខ្លួនអំពីការជាប់ឃុំឃាំងហើយត្រូវផ្តល់មធ្យោបាយសមរម្យសម្រាប់ទាក់ទងជាមួយក្រុមគ្រួសារនិងមិត្តភក្តិរបស់គេ។

## ផ្នែកទី២៖ សិទ្ធិជនជាប់ឃុំក្នុងពេលសវនាការ

### ១. សិទ្ធិការពារខ្លួនក្នុងពេលសវនាការ

ការធ្វើសវនាការជំនុំជំរះដល់ជនជាប់ចោទ គឺជាផ្នែកមួយដែលសំខាន់បំផុតនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ព្រោះថា មានតែពេលនេះទេ ដែលជនជាប់ចោទត្រូវបានគេរកឃើញថាមានទោស ឬគ្មានទោសលើបទចោទដែលបានចោទប្រកាន់មកលើខ្លួន។ ការជំនុំជំរះគឺជាឱកាសតែមួយ ដែលជនជាប់ចោទត្រូវតវ៉ាអំពីការចោទប្រកាន់មកលើខ្លួន តាមរយៈការសាកសួរសាក្សីដាក់បន្ទុក ពិនិត្យភស្តុតាងដាក់បន្ទុក កោះហៅសាក្សីដែលអាចបង្ហាញពីវិមតិសង្ស័យទៅលើភស្តុតាងដាក់បន្ទុក របស់តំណាងអយ្យការ និង បង្ហាញជូនទៅតុលាការនូវការបកស្រាយផ្ទាល់ខ្លួនទៅលើអង្គហេតុ និងអង្គច្បាប់។ យើងអាចនិយាយបានថា សវនាការជំនុំជំរះ គឺជាឱកាសមួយរបស់ជនជាប់ចោទដើម្បីដាក់ជូននូវសណ្ឋានការពាររបស់ខ្លួន ដើម្បីឆ្លើយតបទៅនិងការចោទប្រកាន់របស់ព្រះរាជអាជ្ញា។

ចំពោះអនីតិជន នៅក្នុងពេលសវនាការ តុលាការត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី។ ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឱ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ[32]។ ទន្ទឹមនិងនេះដែលការមានវត្តមានរបស់មេធាវីក៏ជាផ្នែកមួយដ៏សំខាន់ក្នុងពេលជម្រះក្តីទៅលើអនីតិជនដែរ។ ហើយជំនួយរបស់មេធាវីត្រូវតែមានជាដាច់ខាតនៅក្នុងពេលសវនាការ។ បើគ្មានការជ្រើសរើសដោយអនីតិជនទេ មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃតាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ចំណែកសោហ៊ុយសម្រាប់ធ្វើការចម្លងសំណុំរឿងជាបន្ទុករបស់រដ្ឋ។ តុលាការត្រូវផ្តល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿង ទៅឱ្យមេធាវីសម្រាប់រៀបចំការពារ។ សោហ៊ុយសម្រាប់ធ្វើការចម្លងសំណុំរឿងជាបន្ទុករបស់មេធាវីដែលត្រូវជ្រើសរើសដោយអនីតិជន[33]។

### ២. សិទ្ធិទទួលបានការជំនុំជំរះដោយយុត្តិធម៌

បញ្ហាដែលសំខាន់បំផុតក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គឺសមត្ថកិច្ចតុលាការក្នុងការធានាថាជនជាប់

[32] មាត្រាមាត្រា ៤៨ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[33] មាត្រា៥០ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

ចោទទទួលនូវសវនាការមួយប្រកបដោយ ភាពយុត្តិធម៌ ។ ចំណុចមួយដែលច្បាស់បំផុតក្នុងបញ្ញត្តិនៃសវនាការយុត្តិធម៌គឺគោលការណ៍សមភាពរវាង ការការពារនិងការចោទប្រកាន់ ត្រូវមានឋានៈស្មើគ្នា សិទ្ធិស្មើគ្នា និងឱកាសស្មើគ្នានៅក្នុងការបង្ហាញរឿងក្តីរបស់ខ្លួន។ សវនាការប្រកបដោយភាពយុត្តិធម៌ អាចធ្វើឡើងដោយចៅក្រមដែលមានសមត្ថភាព ឯករាជ្យ និងមិនលំអៀង។ ជារួមយើងអាចនិយាយបានថា ចៅក្រមជំនុំជំរះ មានសមត្ថភាពប្រសិនបើចៅក្រមរូបនោះបានទទួលនូវការហ្វឹកហ្វឺនយ៉ាងត្រឹមត្រូវ មានចំណេះដឹងល្អផ្នែកច្បាប់ និងមានការប៉ិនប្រសព្វ និងជំនាញក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួន។

ចៅក្រមឯករាជ្យ គឺជាអ្នកដែលមិនស្ថិតក្រោមឥទ្ធិពល ការដាក់កម្រិត ឬការគាបសង្កត់ពីបុគ្គល ឬ ពីអង្គការណាមួយឡើយ។ ពោលគឺមានសេរីភាពគ្រប់គ្រាន់ ក្នុងការចេញសេចក្តីសម្រេចដោយមិនមានការភ័យខ្លាចពីផលវិបាក ឬសេចក្តីរំពឹងទុកថាមានភាពលំអៀង។ ចៅក្រម មិនលំអៀង គឺជាអ្នកដែលមិនកាន់ជើងតំណាងអយ្យការ ឬមេធាវីការពារណាមួយឡើង ប៉ុន្តែត្រូវប្រកាន់យកភាពជាកណ្តាល អព្យាក្រឹត្យ ហើយប្រកាន់យកតែភាពយុត្តិធម៌ និងភាពត្រឹមត្រូវ ។

រដ្ឋធម្មនុញ និងច្បាប់របស់កម្ពុជាដទៃទៀត ក៏ដូចជាច្បាប់អន្តរជាតិផងដែរ ចែងពីគោលការណ៍ទូទៅស្តីពីសវនាការមួយប្រកបដោយលក្ខណៈយុត្តិធម៌។

មានតែចៅក្រមទេទើបមានសិទ្ធិកាត់សេចក្តី ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់ដោយត្រឹមត្រូវ និងប្រកបដោយសតិសម្បជញ្ញៈ របស់ខ្លួន[34]។

គោលការណ៍ឯករាជ្យ នៃអំណាចតុលាការតម្រូវឱ្យចៅក្រមធានាឱ្យដំណើរការតុលាការប្រព្រឹត្តទៅដោយភាពយុត្តិធម៌ និងគោរពសិទ្ធិទាំងឡាយរបស់ភាគី។

ជនគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ ជនគ្រប់រូបមានសិទ្ធិទទួលបាននូវសវនាការប្រកប ដោយយុត្តិធម៌ និងមានសមត្ថភាព ឯករាជ្យ មិនលំអៀង ដែលបង្កើតឡើងដោយច្បាប់។

អំណាចតុលាការត្រូវធានា និងប្រកាន់ភ្ជាប់នូវភាពមិនលំអៀង ចំពោះការការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ។

ចៅក្រមត្រូវសម្រេចឱ្យបាននូវភាពមិនលំអៀងទាំងស្រុងដោយផ្អែកលើមូលដ្ឋានអង្គហេតុ ដែលលើកឡើងក្នុងសវនាការ។ហើយស្របតាមច្បាប់ដោយបដិសេធនូវសម្ពាធទាំងឡាយដែលមានការគំរាមកំ ហែង ឬការបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដោយភាគីទាំងឡាយក្នុងដំណើរការ ឬជនដទៃទៀត។

[34] មាត្រា ១២៩ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

តុលាការព្រហ្មទណ្ឌដើម្បីពង្រឹងជំនឿរបស់ខ្លួនអាចពិនិត្យទៅលើគ្រប់ឯកសារទាំងអស់ដែលបានដាក់ដើម្បីឱ្យសួរដេញដោលនៅក្នុងពេលសវនាការ និងដាក់ឱ្យសួរតទល់រវាងគូរភាគី និងមេធាវីដើម្បីចេញសាលក្រម។ ចៅក្រមមិនត្រូវផ្អែកលើជំនឿរបស់ខ្លួន ទៅលើការដឹងលឺផ្ទាល់ខ្លួន ដែលខ្លួនបានទទួលព័ត៌មានក្រៅពីសវនាការក្នុងតុលាការឡើយ។

## ៣. សិទ្ធិទទួលបានការជំនុំជំរះដោយសាធារណៈ

សិទ្ធិទទួលបានការជំនុំជំរះដោយសាធារណៈ មិនត្រឹមតែកើតចេញពីគោលការណ៍ដែលរកយុត្តិធម៌បានដោយសន្តិវិធីនោះទេ ថែមទាំងមានការទាមទារឱ្យមើលឃើញនូវការរកយុត្តិធម៌ទៀតផង។ តាមការយល់ដឹងជារួមពីការរំលោភសិទ្ធិមនុស្ស និងរំលោភលើនីតិវិធី អាចកើតឡើងភាគច្រើននៅក្នុងសវនាការដែលធ្វើឡើងជាសម្ងាត់ជាជាងសវនាការដែលធ្វើឡើងជាសាធារណៈ ដែលដំណើរការរួមរបស់វាត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីមហាជន។ អាចនិយាយបានថា សវនាការជាសាធារណៈមានផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ដោយសារបានដឹងលឺច្រើនក្នុងចំណោមមហាជន នូវឥទ្ធិពលនៃការធ្វើឱ្យរាងចាល ទាំងក្នុងសវនាការ និងក្នុងពេលកាត់ទោសជនល្មើស។ ផ្នែកមួយសំខាន់ ក្នុងការកាត់ទោសពិរុទ្ធជនជាសាធារណៈ គឺធ្វើឱ្យគេទទួលរងនូវភាពអាម៉ាស់ពីមហាជនក្នុងពេលបើកសវនាការជាសាធារណៈ។

គោលការណ៍ជំនុំជំរះជាសារធារណៈ គឺធ្វើនៅក្នុងបន្ទប់សវនាការដែលបើក គឺមិនបិទទេ ដោយអនុញ្ញាតឱ្យអ្នកដែលមិនជាប់ពាក់ព័ន្ធ ឬប្រជាពលរដ្ឋទាំងអស់ អាចចូលរួមស្តាប់បានដើម្បី៖

- ឱ្យតុលាការយកចិត្តទុកដាក់ នូវការជំនុំជំរះរបស់ខ្លួនឱ្យកាន់តែត្រឹមត្រូវ មិនលំអៀង
- ធ្វើការផ្សព្វផ្សាយទៅអ្នកចូលរួមឱ្យមានការយល់ដឹង រួមទាំងផ្សព្វផ្សាយច្បាប់ និងការអនុវត្តន៍ច្បាប់

+ យល់ដឹងឱ្យបានកាន់តែស៊ីជម្រៅ ពីការកាត់ទោស

+បើដំណើរការកាត់ក្តីបានត្រឹមត្រូវប្រកបដោយតម្លាភាពនាំឱ្យមានការយកចិត្តទុកដាក់ពីស្ថាប័នតុលាការ

+ អ្នកដែលមានបំណងចង់បំពាននាំឱ្យគេខ្លាចមិនហ៊ានធ្វើដោយសារច្បាប់

សិទ្ធិក្នុងការបើកសវនាការជាសាធារណៈ មានចែងយ៉ាងច្បាស់នៅក្នុងច្បាប់កម្ពុជា ហើយក៏មានករណីលើកលែងតែមួយចំនួនប៉ុណ្ណោះ។ ព្រោះច្បាប់រដ្ឋកម្ពុជាតម្រូវឱ្យបើកសវនាការជាសម្ងាត់ប្រសិនបើការបើកសវនាការជាសារធារណៈនៅក្នុងតុលាការ អាចមានគ្រោះថ្នាក់ដល់របៀបរៀបរយសាធារណៈ និងប្រពៃណី[35]។ ទាក់ទងទៅនិងប្រពៃណីល្អនេះ ច្បាប់ព្រហ្មទណ្ឌអន្តរកាលអាចបើកសវនាការជាការសម្ងាត់បានប្រសិនបើជន

[35] មាត្រា ១២៩ នៃច្បាប់ស្តីពីនីតិវីធីព្រហ្មទណ្ឌ១៩៩៣

រងគ្រោះ ឬតំណាងរបស់ខ្លួនស្នើរដែលមានការឯកភាពពីចៅក្រម[36]។ ហេតុដែលបើកសវនាការជាសម្ងាត់រួមមាន៖

- ពេលមានកាខឹងសម្បាក្នុងចំណោមមហាជន ដែលអាចបង្កចលាចល ឬអំពើហឹង្សា
- ការពារអត្តសញ្ញាណ និងសុវត្ថិភាពសាក្សី
- ពេលជនរងគ្រោះស្នើឱ្យមានសវនាការជាសម្ងាត់ ហើយតុលាការយល់ព្រម។

### ៤. សិទ្ធិមានវត្តមាននៅពេលជំនុំជំរះ

ការជំនុំជំរះដែលដំណើរការដោយគ្មានវត្តមានរបស់ជនជាប់ចោទ គឺជាការរំលោភទៅលើគោលការណ៍សវនាការ ប្រកបដោយយុត្តិធម៌ដូចដែលបានរៀបរាប់ខាងលើរួចមកហើយ។ អវត្តមានរបស់ជនជាប់ចោទ បណ្តាលឱ្យមិនអាចមានការទទួលដំណឹងពីបទចោទប្រកាន់ មិនអាចមានសិទ្ធិជូនសំអាងការពារថាមាន ឬគ្មានជំនួយ ពីមេធាវី និងមិនអាចហៅសាក្សីមកសួរដេញដោល និងឆ្លើយបំភ្លឺបានទេ។ ព្រោះអាចបណ្តាលឱ្យបាត់បង់នូវសមភាព រវាងការចោទប្រកាន់ និងការការពារក្តី ដោយសារគ្មានវត្តមានជនជាប់ឃុំ ហើយការការពារក៏មិនអាចធ្វើទៅបានដែរ។

មាត្រា ១១១ ដល់មាត្រា ១២៤ នៃច្បាប់ស្តីពីនីតិវិធីឆ្នាំ១៩៩៣ បានចែងអំពីនីតិវិធីជំនុំជំរះនៃជនជាប់ចោទអវត្តមានដែលហៅថា ការជំនុំជំរះកំបាំងមុខ។ ជនជាប់ចោទអាចជំទាស់និងសេចក្តីសម្រេច របស់តុលាការ ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីទទួលបានដំណឹងពីសាលក្រមកំបាំងមុខ ឬអាចជំទាស់ទៅលើសេចក្តីសម្រេចនោះនៅពេលណាមួយក៏បានក្នុងអំឡុងពេលអាជ្ញាយុកាលនៃទោស នៅមានសុពលភាព ប្រសិនបើជនជាប់ចោទមិនបានទទួល ឬមិនបានគេប្រាប់ដំណឹងអំពីសាលក្រមនោះ[37] ។

សិទ្ធិរបស់ជនជាប់ចោទ ក្នុងការមានវត្តមាននៅសវនាការមានចែងយ៉ាងច្បាស់នៅក្នុងបទដ្ឋានជាអប្បបរមារបស់អន្តរជាតិ។ នីតិវិធីជំនុំជំរះកំបាំងមុខទាំងនេះ មានលក្ខណៈផ្ទុយទៅនិងរដ្ឋធម្មនុញ្ញ និងកតិកាសសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលមានចែងដូចខាងក្រោម៖

- ប្រជាពលរដ្ឋគ្រប់រូប ត្រូវបានទទួលនូវសិទ្ធិទទួលការការពារពីតុលាការ[38]។
- ការជំនុំជំរះ ការកាត់ទោសត្រូវធ្វើចំពោះមុខសាមីជន។ សាមីជនអាចឆ្លើយដោះសារដើម្បីការពារខ្លួនដោយខ្លួនឯង ឬដោយជំនួយផ្នែកច្បាប់ដែលគាត់ជាអ្នកជ្រើសរើស[39]។ ប៉ុន្តែយើងអាចលើកឡើង

[36] មាត្រា២៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

[37] មាត្រា ១១១ ដល់មាត្រា ១២៤ នៃច្បាប់ស្តីពីនីតិវិធីឆ្នាំ១៩៩៣

[38] មាត្រា៣៨ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[39] មាត្រា ១៤ នៃកតិកាសសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ

បានថា ការការពារនេះមិនអាចការពារមាត្រា ១១១ ដល់មាត្រា១២៤ ដូចដែលគេបានលើកឡើងក្នុងនីតិវីធីសាលក្រមកំបាំងមុខនោះបានទេ ព្រោះវាផ្ទុយនិងស្មារតីនៃរដ្ឋធម្មនុញ្ញ ហើយមាត្រាទាំងនោះក៏មិនអាចមានអំណាចអនុវត្តជាច្បាប់តទៅទៀតបានឡើយ ។

## ៥. សិទ្ធិមានអ្នកបកប្រែ

នៅក្នុងសវនាការ ជនជាប់ចោទត្រូវទទួលបានអ្នកបកប្រែដោយឥតគិតថ្លៃឈ្នួល ប្រសិនបើជនជាប់ចោទមិនយល់ ឬមិនចេះភាសាផ្លូវការដែលប្រើប្រាស់នៅក្នុងសវនាការ។ ពោលគឺ ភាគីត្រូវមានជំនួយការដោយឥតគិតថ្លៃ នូវអ្នកបកប្រែផ្ទាល់មាត់ដែលមានសមត្ថភាព ហើយការបកប្រែនោះចាំបាច់ដើម្បីបំពេញបានតាមលក្ខខ័ណ្ឌ តម្រូវការនៃភាពយុត្តិធម៌។ សិទ្ធិមានអ្នកបកប្រែនេះ ភាគច្រើនសំដៅលើជនបរទេស ឬ ជាជនដែលមិនចេះអក្សរ ។ ហេតុនេះហើយទើបតម្រូវឱ្យមានអ្នកបកប្រែភាសា សម្រាប់ជួយដោយឥតគិតថ្លៃឈ្នួល ប្រសិនបើសាម៉ីជននោះមិនចេះស្តាប់ភាសាដែល ប្រើក្នុងការកាត់ក្តីនោះ[40]។ ដូចនេះនៅក្នុងសវនាការ ត្រូវតែរកអ្នកបកប្រែជូនភាគីនៅក្នុងរឿងក្តី ដែលមិនចេះភាសា ឬជាជន គ ថ្លង់។ តាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ មាត្រា ១៣៦បានចែងថា បើជនជាប់ចោទ ឬសាក្សីជាមនុស្ស គ ថ្លង់ ប៉ុន្តែចេះសរសេរអក្សរនោះក្រឡាបញ្ជីត្រូវសរសេរ សំណួរ និងការកត់ សម្គាល់ផ្សេងៗ ទៅឱ្យជនជាប់ចោទ ឬសាក្សី គ ថ្លង់ នោះដើម្បីធ្វើការឆ្លើយ មកវិញដោយ លាយ លក្ខណ៍ អក្សរ។ បើជនគថ្លង់មិន ចេះសរសេរអក្សរចៅក្រមត្រូវតែងតាំងដោយឯកឯងនូវជនណាម្នាក់ ដែលចេះភាសាកាយវិកាសម្រាប់ធ្វើការឆ្លើយឆ្លងជាមួយមនុស្ស គ ថ្លង់ ដោយកាយវិការ[41]។

ដូច្នេះយើងឃើញថានៅប្រទេសកម្ពុជាយើង ក៏មានការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ផងដែរ នូវសិទ្ធិមានអ្នកបកប្រែភាសា សម្រាប់ផ្តល់ជូនភាគី ឬក៏សម្រាប់ជនជាប់ចោទ ដូចជាតាមរយៈលិខិតតូបករណ៍ សិទ្ធិមនុស្សអន្តរជាតិ ដែលបានរៀបរាប់ខាងលើ និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣។ ព្រោះថារដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣បានប្រកាសយ៉ាងទូលំទូលាយ ក្នុងការស្គាល់នូវលិខិតតូបករណ៍សិទ្ធិមនុស្សអន្តរជាតិទាំងអស់នេះ។

## ៦. សិទ្ធិសុំផ្លាស់ប្តូរមេធាវី

មេធាវីគឺជាបុគ្គលម្នាក់ដែលត្រូវបានគេដឹងថាមានទេពកោសល្យក្នុងការការពារក្តី ទោះបីជារឿងនោះជារឿងព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណីក៏ដោយ។ ជាទូទៅ នៅពេលដែលជនណាម្នាក់ត្រូវបានជាប់ចោទថាបាន

[40] មាត្រា១៤ (២) នៃកតិកាសសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ

[41] មាត្រា ១៣៦ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣

ប្រព្រឹត្តបទល្មើសអ្វីមួយ (ខ្លួនរមែងតែងតែចង់ទទួលបាននូវទីប្រឹក្សា ឬមេធាវីដែលមានបទពិសោធន៍ច្រើនក្នុងការការពារក្តី ដើម្បីជួយឱ្យខ្លួនរួចផុតពីការចោទប្រកាន់។ ប៉ុន្តែកាលបើទីប្រឹក្សា ឃើញថាមេធាវីនោះគ្មានសមត្ថភាព គ្រប់គ្រាន់ ពោលគឺពុំសូវ មានជំនាញក្នុងការការពារក្តី វាជាហេតុធ្វើឱ្យជនជាប់ចោទដែលជាកូនក្តីរបស់ខ្លួនប្រាកដជាប្រឈមមុខនិងការទទួលទោស ។ ដូច្នេះ ជនជាប់ចោទមានសិទ្ធិ សុំធ្វើការផ្លាស់ប្តូរមេធាវីបានចំពោះមេធាវីថ្មីដែលខ្លួនបានជ្រើសរើសសម្រាប់ការពារនេះ ត្រូវធ្វើការទំនាក់ទំនង ជាមួយមេធាវីចាស់ ក្នុងគោលដៅដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីសំណុំរឿងទាំងឡាយដែលជាប់ពាក់ព័ន្ធទៅនឹងកូនក្តីខ្លួន ដើម្បីចាប់ផ្តើមនីតិវិធីការពារ ជាថ្មីម្តងទៀត។

## ៧. សិទ្ធិឆ្លើយសំណួររបស់ចៅក្រមដោយគ្មានវត្តមានពីមេធាវី

នៅមុនពេលសួរចម្លើយដល់ជនជាប់ចោទណាម្នាក់ អំពីបទឧក្រិដ្ឋណាមួយ ចៅក្រមស៊ើបអង្កេតត្រូវប្រាប់អំពីសិទ្ធិក្នុងការរកជំនួយមេធាវីមកជួយការពារខ្លួនបាន[42]។ បន្ថែមពីនេះទៅទៀត ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិននិយាយអ្វីទាំងអស់ ទោះជាមាន ឬ មិនមានវត្តមានមេធាវីក៏ដោយ។ ហើយជនជាប់ចោទក៏គ្មានកាតព្វកិច្ចតាមផ្លូវណាមួយដើម្បីឆ្លើយរាល់សំណួរទាំងនោះដែរ ដូច្នេះជនជាប់ចោទអាចនៅស្ងៀម ដោយមិនឆ្លើយនូវរាល់សំណួរអ្វីទាំងអស់រហូតដល់មេធាវីខ្លួនបានមកដល់។ ប្រសិនបើជនសង្ស័យ ឬ ជនជាប់ចោទណាម្នាក់ ត្រូវបានគេចាប់បង្ខំទាំងផ្លូវកាយ និង ផ្លូវចិត្តឱ្យឆ្លើយសារភាពដាក់កំហុសលើខ្លួនឯង ឬ បង្ខំឱ្យឆ្លើយសារភាពទទួលកំហុសទាំងដែលខ្លួនមិនបានធ្វើចំពោះចម្លើយនោះគឺមិនអាចយកជាការបានឡើយ។

ចៅក្រមស៊ើបអង្កេតអាចសួរចម្លើយជនជាប់ចោទដោយគ្មានវត្តពីមេធាវីបាន ប្រសិនបើរកឃើញថាជនជាប់ចោទមានសមត្ថភាពការពារដោយខ្លួនឯងបាន និងអាចយល់សំណួរទាំងឡាយណារបស់ចៅក្រមស៊ើបអង្កេតដែលបានដាក់បន្ទុកមកលើខ្លួន តែទង្វើទាំងអស់នេះវាអាចនាំឱ្យមានកង្វះខាត ឬជះឥទ្ធិពលមិនល្អចំពោះជនជាប់ចោទព្រោះជនជាប់ចោទភាគច្រើនគ្មានជំនាញយល់ដឹងពីផ្នែកច្បាប់បានជ្រៅជ្រះនោះទេជាហេតុបណ្តាលឱ្យការឆ្លើយនូវរាល់សំណួរទាំងអស់នោះជះឥទ្ធិពលមិនល្អមកលើខ្លួនដោយប្រការណាមួយ។

ក្នុងករណីមេធាវីមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទនិងពេលវេលាដែលបានកំណត់នោះទេ ចៅក្រមនិងចាប់ផ្តើមធ្វើការសួរចម្លើយជនជាប់ចោទដោយមិនចាំបាច់មានវត្តមានមេធាវី ប៉ុន្តែត្រូវកត់ត្រាអំពីហេតុការណ៍នោះក្នុងរបាយការណ៍ទុកជាភស្តុតាង។ ដូច្នេះការណែនាំជនជាប់ចោទដោយ អ្នកជំនាញផ្នែកច្បាប់ មានផលប្រយោជន៍សំខាន់ណាស់ដល់ជនជាប់ចោទ ព្រោះវាអាចជាវិធានការមួយ ដែលមានផលជាវិជ្ជមាន ជាពិសេសចំពោះជនជាប់ចោទណាដែលមិនមាន ជំនាញ ឬ មិនដឹងពីភាពស្មុកស្មាញអំពីដំណើរការ

---

[42] មាត្រា៣០០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ក្តីព្រហ្មទណ្ឌ។ សម្គាល់ជំនួយមេធាវីត្រូវតែមានជាចំាបាច់ក្នុងលក្ខណ្ឌពីរគឺបទឧក្រិដ្ឋ និងជនជាប់ចោទជាអនីតិជន[43]។

### ៨. ជនជាប់ចោទជាអនីតិជនក្នុងពេលសវនាការ

ជនជាប់ចោទជាអនីតិជន បើទោះបីបានប្រព្រឹត្តិបទល្មើសក្តី ប៉ុន្តែពួកគេត្រូវបានការការពារផ្នែកច្បាប់ច្រើនជាងនីតិជន។ ជនជាប់ចោទជាអនីតិជន ពួកគេត្រូវទទួលបានកិច្ចគាំពារបន្ថែមដោយសារវ័យនៅក្មេង មិនទាន់ដឹងក្តី ហើយពួកគេត្រូវវិវត្តន៍ចម្រើនវ័យនិងប្រាជ្ញាស្មារតីថែមទៀត។

ក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិសុទ្ធតែបានចែងអំពីការប្រព្រឹត្តិជាពិសេសលើអនីតិជន។ អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា៣(១)ចែងថា នៅក្នុងវិធានការទាំងអស់ដែលពាក់ព័ន្ធកុមារ ទោះធ្វើឡើងដោយស្ថាប័នឯកជន ឬសាធារណៈ ត្រូវទទួលភារៈខាងសុខុមាលភាពសង្គមដោយតុលាការ ឬដោយអាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិដោយផលប្រយោជន៍ល្អបំផុតរបស់កុមារត្រូវតែយកចិត្តទុកដាក់ជាចម្បង[44]។ ដោយឡែកប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជន នៅឆ្នាំ២០១៦ ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារដែលបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ។ ជាក់ស្តែងមាត្រា ៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចែងថា គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍ដូចជាត្រូវយកចិត្តទុកដាក់និងពិចារណារាល់សកម្មភាពពាក់ព័ន្ធឧត្តមប្រយោ ជន៍របស់អនីតិជន ជាពិសេសធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិប្បរមា[45]។

តួយ៉ាង ជនជាប់ចោទជាអនីតិជនមានវត្តមានក្នុងពេលសវនាការជាសាធារណៈ គ្មានវិធានការណាមួយត្រូវបានតុលាការប្រើប្រាស់ដើម្បីការពារសិទ្ធិឯកជនរបស់ពួកគេនោះទេ។ នេះវាផ្ទុយនឹងមាត្រា៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលចែងថា ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមលើអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ[46]។ មានន័យថាពេលជំនុំជម្រះក្តីមិនត្រូវឱ្យមានវត្តមានជនជាប់ចោទជាអនីតិជនក្នុងបន្ទប់សវនាការឡើយ។ ត្រង់ចំណុចនេះ ដើម្បីអាចការពារឯកជនភាពរបស់អនីតិជន អំឡុងពេលសវនាការតុលាការត្រូវប្រើរបាំងការពារ ឬធ្វើតាមរយៈវីដេអូឆ្លើយឆ្លងជាមធ្យោបាយក្នុងការផ្តល់សក្ខីកម្ម។ មួយទៀតដែរគឺការឃុំខ្លួនបណ្តុះអាសន្នជាជម្រើសចុងក្រោយក៏ត្រូវបានរកឃើញថាមានភាគរយខ្ពស់ផងដែរ។

ចំពោះការឃុំខ្លួនជាបណ្តុះអាសន្នក្នុងពន្ធធនាគារ។ ករណីនេះបានផ្ទុយ នឹងបញ្ញត្តិច្បាប់មាត្រា ៣៧

[43] មាត្រា៣០១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[44]មាត្រា៣(១) អនុសញ្ញាស្តីពីសិទ្ធិកុមារ

[45] មាត្រា ៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[46] មាត្រា ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលចែងថា គ្មានកុមារណាម្នាក់ ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬ តាមអំពើចិត្តឡើយ[47]។ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារត្រូវធ្វើស្របតាមច្បាប់ និងត្រូវប្រើសម្រាប់តែវិធានការចុងក្រោយ និងសម្រាប់រយៈពេលខ្លីបំផុត។

ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាពិសេសមាត្រា ៤៧ ដែលតម្រូវឱ្យដំណើរការសវនាការ និងការប្រកាសសេចក្តីត្រូវធ្វើឡើងជាអសាធារណៈ។ ការអនុញ្ញាតឱ្យជនជាប់ចោទជាអនីតិជនបង្ហាញខ្លួនចំពោះមុខតុលាការក្នុងសម្លៀកបំពាក់ផ្ទាល់ខ្លួនជាជម្រើសល្អបំផុត។ ចៅក្រមគប្បីពិនិត្យជម្រើសផ្សេងៗក្រៅពីការដាក់ពន្ធនាគារសម្រាប់ការផ្តន្ទាទោសលើជនជាប់ចោទជាកុមារ។ ហើយការបណ្តុះបណ្តាលបន្ថែមសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា និងការពិនិត្យឱ្យបានល្អិតល្អន់នូវច្បាប់ដែលបានចូលជាធរមាន ជាផ្នែកមួយធានាឱ្យការអនុវត្តកាន់តែប្រសើរស្របតាមបទដ្ឋានជាអប្បបរមាសម្រាប់ការអនុវត្តដោយយុត្តិធម៌លើអនីតិជនជាជនជាប់ចោទ។

## ផ្នែកទី៣៖ សិទ្ធិជនជាប់ចោទក្រោយពេលសវនាការ

### ១. សិទ្ធិធ្វើបណ្តឹងទាស់

ជាគោលការណ៍តាមផ្លូវច្បាប់ នៅពេលដែលតុលាការបើកសវនាការជំនុំជំរះ លើពិរុទ្ធជន ឬ ជនជាប់ចោទណាម្នាក់ដោយកំបាំងមុខគឺ គាត់អាចប្តឹងទៅតុលាការ ដើម្បីធ្វើការជំនុំជំរះឡើងវិញបាន។ ចំពោះការប្តឹងសុំឱ្យជំនុំជំរះឡើងវិញនេះ នៅក្នុងច្បាប់គេមិនហៅថាបណ្តឹងតវ៉ានោះទេ ព្រោះវាគ្រាន់តែជាពាក្យសាមញ្ញធម្មតាសម្រាប់ប្រើទូទៅតែប៉ុណ្ណោះ តែបើតាមភាសាច្បាប់គេហៅថា បណ្តឹងទាស់។

បណ្តឹងទាស់ ឬ បណ្តឹងជំទាស់គឺជាពាក្យសុំបដិសេធសេចក្តីសម្រេចឬសាលក្រម ដែលត្រូវបើកឱ្យគូក្តីដែលបានអវត្តមាននៅពេលជំនុំជម្រះ ដោយសម្រេចឱ្យមានការជំនុំជម្រះឡើងវិញ ចំពោះមុខខ្លួន។ ពាក្យបណ្តឹងទាស់ប្រើសម្រាប់ប្តឹងអំពីសេចក្តីសម្រេចកំបាំងមុខរបស់សាលាជម្រះក្តី។

បណ្តឹងទាស់ អាចធ្វើឡើងបានក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីបាន ទទួលសាលក្រម សាលដីកា ឬ បានដឹងយ៉ាងពិតប្រាកដ[48]។បណ្តឹងទាស់អាចធ្វើឡើងបានដោយដាក់ពាក្យបណ្តឹងសរសេរជាលាយ លក្ខណ៍អក្សរ ដាក់នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ឬ សាលដីកា នៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាលឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួន[49]។

---

[47] មាត្រា ៣៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

[48] មាត្រា ៣៦៥ ៣៦៨ ៤០៩ ៤១២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[49] មាត្រា ៣៦៦ ៤១០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ជនជាប់ចោទមានសិទ្ធិប្តឹងជំទាស់ទៅនឹងសាលក្រមកំបាំងមុខព្រោះថាសវនាការមួយដែលបានប្រព្រឹត្តទៅដោយអវត្តមានជនជាប់ចោទ វាមិនមែនជាសវនាការមួយដែលប្រកបដោយភាពយុត្តិធម៌នោះឡើយ។ ផ្ទុយមកវិញវាគឺជាការរំលោភបំពានលើ សិទ្ធិជនជាប់ចោទ ព្រោះមិនបានទទួលនូវការជូនដំណឹងពីបទចោទ។

ជនជាប់ចោទអាចប្តឹងទាស់ និងសាលក្រមកំបាំងមុខនេះបានក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃ ។ រីឯការជំទាស់ស្របច្បាប់រយៈពេល ១៥ថ្ងៃនេះគឺជាការផ្អាកការអនុវត្តសាលក្រម។ យោងមាត្រា៣៦៩ ចែងថា បណ្តឹងទាស់ត្រូវធ្វើនៅក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ផ្តើមគិតពីថ្ងៃជូនដំណឹងអំពី សាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រមកាលណាសាលក្រម។

ប្រសិនបើជនជាប់ចោទប្តឹងទាស់ហើយតុលាការទទួលបណ្តឹងនោះសំណុំរឿងរបស់ជនជាប់ចោទនិងត្រូវបានយកទៅជំនុំជំរះនៅចំពោះមុខតុលាការ ដោយចាត់ការដូចជាការជំនុំជំរះលើកទីមួយដែរ។ មានន័យថា កម្រិតនៃស្ថានទម្ងន់ទោសអាចត្រូវបានកែលើកយកមកម្តងទៀត បើមិនមានលើកឡើងនៅក្នុងសាលក្រមកំបាំងមុខទេនោះ ជនជាប់ចោទដែលបានកាត់ទោសរួចក៏អាចឲ្យរួចខ្លួនវិញបានដែរ។ មាត្រា ៣៧១ ចែងថាសំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះនៅមុខតុលាការដដែរ[50]។

ប្រសិនបើមិនអាចជូនដំណឹងដោយផ្ទាល់មាត់អំពីសេចក្តីប្រកាសនៃសាលក្រមនេះទេ សាលក្រមនេះអាចយកទៅបិទនៅនឹងលំនៅដ្ឋានដែលគេស្គាល់ចុងក្រោយបង្អស់របស់ជនល្មើស ឬបិទផ្លូវឃុំសង្កាត់ ឬផ្សាយតាមវិទ្យុជាតិ ឬបោះពុម្ព ផ្សាយតាមសារព័ត៌មានផ្លូវការ ប្រសិនបើជនជាប់ចោទ ដឹងអំពីសាលក្រមគាត់អាចប្តឹងទាស់នៅពេលណាក៏បាន ឱ្យតែស្ថិតក្នុងកំឡុងពេលអាជ្ញាយុកាលនៃទោស។

### ២. សិទ្ធិប្តឹងឧទ្ធរណ៍

សិទ្ធិប្តឹងឧទ្ធរណ៍ គឺជាពាក្យតវ៉ារបស់ភាគីណាមួយ ដែលសុំឱ្យកែប្រែសេចក្តីសម្រេច ឬសាលក្រមរបស់ តុលាការខេត្ត-ក្រុង ឬតុលាការយោធា។ សេចក្តីសម្រេចទាំងឡាយរបស់អយ្យការអមតុលាការទាំងនេះត្រូវបើកសវនាការនៅតុលាការជាន់ខ្ពស់ដែលហៅថា សាលាឧទ្ធរណ៍ដែលមានទីតាំងនៅភ្នំពេញ និងមានសមត្ថកិច្ច ទូទាំងព្រះរាជាណាចក្រកម្ពុជា។

សាលាឧទ្ធរណ៍និងពិនិត្យឡើងវិញទៅលើអង្គហេតុ និងអង្គច្បាប់។ ដូច្នេះបើសិនជាភាគីណាមួយមិនពេញចិត្តនិងសាលក្រម ឬសេចក្តីសម្រេចរបស់តុលាការជាន់ទាបនោះទេ ភាគីនោះអាចរៀបចំសំណុំរឿង

[50] មាត្រា ៣៧១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដើម្បីប្ដឹងទៅសាលាឧទ្ធរណ៍បាន។ ចំពោះបណ្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងរយៈពេល២ខែ ចាប់ពីថ្ងៃដែលប្រកាសសាលក្រមរបស់សាលាដំបូងរាជធានី ខេត្ត និងប្ដឹងឡើងដោយព្រះរាជអាជ្ញានៃសាលាដំបូង ហើយបណ្ដឹងនិងធ្វើឡើងដោយអគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍លើសេចក្ដីសម្រេចដែលមានរយៈពេល៣ខែ[51]។

សាលាឧទ្ធរណ៍អាចប្រើប្រាស់នីតិវិធីសវនាការដូចគ្នានិងនីតិវិធីដែលប្រើនៅក្នុងតុលាការខេត្ត-ក្រុងដែរ តែចំណុចដែលខុសគ្នានោះ គឺរឿងក្ដីត្រូវជំនុំជំរះដោយចៅក្រម ៣រូបហៅថាក្រុមប្រឹក្សាជំនុំជំរះ និងធ្វើការស៊ើបអង្កេតបន្ថែមដើម្បីជួយរកដំណោះស្រាយអំពីការខ្វះចន្លោះលើអង្គហេតុ ដែលរកឃើញដោយតុលាការជាន់ទាប។ ប៉ុន្តែសាលាឧទ្ធរណ៍មិនអាចបើកសវនាការលើបញ្ហា និងបទចោទដែលមិនបានប្ដឹងឧទ្ធរណ៍បានទេ។ សាលាឧទ្ធរណ៍ក៏មានមានអំណាចក្នុងការបើកសវនាការលើបណ្ដឹងឧទ្ធរណ៍ដែលអយ្យការតុលាការខេត្ត-ក្រុងឬតុលាការយោធាជាអ្នកប្ដឹងឧទ្ធរណ៍ និងសេចក្ដីសម្រេចទាំងឡាយរបស់ចៅក្រមនៅតុលាការទាំងនោះ ទាក់ទងទៅនឹងការឃុំខ្លួន ឬការឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន លើកលែងការចោទប្រកាន់ ដោយគ្មានមូលហេតុត្រឹមត្រូវសម្រាប់ធ្វើការចោទប្រកាន់។ ក្នុងរឿងក្ដីព្រហ្មទណ្ឌ ការប្ដឹងឧទ្ធរណ៍លើសេចក្ដីសម្រេច ឬសាលក្រមណាមួយដែលចេញដោយតុលាការ ត្រូវធ្វើឡើងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ។

## ៣. បណ្ដឹងសារទុក

បណ្ដឹងសាទុកគឺជាការធ្វើបណ្ដឹងតវ៉ា ឬបដិសេធសេចក្ដីសម្រេច សាលដីការបស់សាលាឧទ្ធរណ៍ពោលគឺនៅពេលដែលភាគីកើតទុក្ខមិនសុខចិត្តនិងសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ ភាគីនោះមានសិទ្ធិប្ដឹងទៅតុលាការកំពូលដែលមានទីតាំងស្ថិតនៅទីក្រុងភ្នំពេញ និងជាតុលាការធំជាងគេនៅទូទាំងប្រទេស ហើយមាន សមត្ថកិច្ចអនុវត្តន៍ទូទាំងប្រទេសផងដែរ [52] រីឯការធ្វើបណ្ដឹងសារទុក្ខគឺមានរយៈពេលមួយខែ[53] ។

តុលាការកំពូលគឺជាតុលាការដែលដោះស្រាយចុងក្រោយបំផុតចំពោះការអនុវត្ត សាលដីការបស់សាលាឧទ្ធរណ៍រហូតដល់មានប្រកាសសាលដីការបស់តុលាការកំពូល ក្រោយពីទទួលបានពាក្យបណ្ដឹងសារទុក្ខ ដែលមិនសុខចិត្តនិងសាលដីការបស់សាលាឧទ្ធរណ៍។ ការប្ដឹងសារទុក្ខទៅតុលាការកំពូល អាចចេញជាលទ្ធផលក្នុងការផ្ទេរសមត្ថកិច្ច ដើម្បីពិនិត្យឡើងវិញអំពីអង្គច្បាប់ទាំងអស់នៅក្នុងសាលដីកាសាលាឧទ្ធរណ៍ ប្រសិនបើភាគីប្ដឹងសារទុក្ខ បានបង្ហាញនូវភស្តុតាងត្រឹមត្រូវ។ ក្នុងករណីដែលភាគីប្ដឹងសារទុក្ខបានបង្ហាញបញ្ហាណាមួយនៅក្នុងបណ្ដឹងសារទុក្ខនោះ តុលាការកំពូលត្រូវជំនុំជំរះទៅលើបញ្ហាដែលបានប្ដឹងតែប៉ុណ្ណោះ។

[51] មាត្រា ៣៨១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[52] មាត្រា ៤១៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[53] មាត្រា ៤២០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

តុលាការកំពូលត្រូវសម្រេចចេញសាលដីការបស់ខ្លួនទាំងបញ្ហាអង្គហេតុ និងអង្គច្បាប់តាមរយៈការបង្កើតឡើងនូវក្រុមប្រឹក្សាជំនុំជំរះរួម។ ហើយក្រុមប្រឹក្សានេះរួមមានចៅក្រម៩ រូប មកពីរដ្ឋប្បវេណី និងព្រហ្មទណ្ឌរបស់តុលាការកំពូលផង ។

ចំពោះបណ្តឹងសាទុក្ខគឺធ្វើក្នុងរយៈពេលគិតចាប់ពីថ្ងៃប្រកាសសាលដីកា។ ហើយពាក្យបណ្តឹងសារទុក្ខត្រូវចុះហត្ថលេខា ឬផ្តិតមេដៃព្រមទាំងចុះហត្ថលេខាដោយក្រឡាបញ្ជីរបស់សាលាឧទ្ធរណ៍ និងចុះកាលបរិច្ឆេទ ឱ្យបានត្រឹមត្រូវ ( ដោយផ្អែកលើការទទួល ពាក្យបណ្តឹងសារទុក្ខ )។ ដើមបណ្តឹងសារទុក្ខត្រូវដាក់សារណាដល់តុលាការក្នុងអំឡុងពេល ២០ថ្ងៃ។ រយៈពេលនេះអាចបន្តបានពី ១០ថ្ងៃបន្ថែមទៀតប្រសិនបើដើមបណ្តឹងសារទុក្ខជាអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍គាត់ត្រូវភ្ជាប់ជូននូវសេចក្តីសន្និដ្ឋាន ដែលបង្ហាញអំពីបញ្ហាអង្គច្បាប់ក្នុងរឿងក្តីទៅឱ្យតុលាការកំពូល។ នៅពេលសារណារបស់ដើមបណ្តឹងសារទុក្ខដាក់ជូនទៅតុលាការកំពូល ក្រឡាបញ្ជីត្រូវបញ្ជូសារណានេះមួយច្បាប់ទៅឱ្យគូភាគី (ឬតំណាងរបស់គេ ដើម្បីរៀបចំឆ្លើយតបមកវិញ។ អ្នកដែលត្រូវឆ្លើយតបមានពេល ២០ថ្ងៃ ដើម្បីដាក់សារណាតបរបស់ខ្លួនទៅតុលាការ ស្របគ្នានេះក៏អាចបន្តបន្ថែមបានរយៈពេល១០ថ្ងៃទៀតតាមសំណើរ។ ប្រសិនបើពុំគោរពតាមទម្រង់ខាងលើនោះទេ ដំណើការបណ្តឹងឧទ្ធរណ៍និងត្រូវចាត់ទុកជាមោឃៈ។ ចំពោះភាគីដែលខូចប្រយោជន៍ ដោយសារពុំបានគោរពតាមទម្រង់នៃការស្នើរបស់តុលាការទេនោះ ការចាប់ផ្តើមសវនាការសារជាថ្មីនិងត្រូវបានរារាំង ដោយសារមានភាពមិនប្រក្រតីកើតឡើង។ ទោះបីជាភាគីទាំងពីរមិនបានដាក់សារណារបស់ខ្លួនតាមពេលកំណត់ ក៏ប្រធានតុលាការកំពូលនៅតែត្រូវបញ្ជូនសំណុំរឿងទៅចៅក្រម ដែលរៀបចំរបាយការណ៍ដោយមិនចាំបាច់មានសារណា បានដែរ។ តាមច្បាប់សវនាការត្រូវធ្វើឡើងក្នុងរយៈពេល ៣ខែបន្ទាប់ពីបានទទួលសំណុំរឿងពេញលេញ យោងមាត្រា ២១៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ១៩៩៣[54]។

ដំណើរការសវនាការរបស់តុលាការកំពូល និងបទវិន័យបន្ទប់សវនាការគឺដូចគ្នានឹងតុលាការថ្នាក់ក្រោមដែរ ហើយមានចែងដោយសង្ខេបទៅមាត្រា២១៦ នៃច្បាប់ស្តីពីអំពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣[55]។ ក្រុមប្រឹក្សាជំនុំជំរះនិងបើកសវនាការដោយមានសមាសភាពចៅក្រម ៥ រូប ក្នុងនោះមានប្រធានតុលាការកំពូលដែលត្រូវធ្វើជាប្រធាន។ តែតុលាការកំពូលគឺត្រូវធ្វើជាសាធារណៈ ហើយសាលដីកាក៏ត្រូវប្រកាសជាសាធារណៈដែរ។ តុលាការកំពូលមិនអាចពិចារណា ឬចេញសាលដីកាលើបណ្តឹងសារទុក្ខណាមួយដែលមិនបានបើកសវនាការជាសាធារណៈ បានឡើយ ។

[54] យោងមាត្រា ២១៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ១៩៩៣

[55] យោងមាត្រា ២១៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ១៩៩៣

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបមកបន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវយើងឃើញថាតាមគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាច្បាប់អន្តរជាតិ បានចែងយ៉ាងយកចិត្តទុកដាក់អំពីសិទ្ធិជនជាប់ឃុំ។ ជនជាប់ឃុំត្រូវបានច្បាប់គាំពារឱ្យទទួលបាននូវសិទ្ធិមួយចំនួនដើម្បីការពារខ្លួនទៅតាមផ្លូវច្បាប់ និង ការពារការពីររំលោភបំពានសិទ្ធិរបស់ពួកគេ ដោយប្រការណាមួយដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពក្នុងរយៈពេលនៃការឃុំខ្លួន។ ជនជាប់ឃុំក៏ដូចជាបុគ្គលទូទៅដែរ សុទ្ធតែត្រូវទទួលបានការការពារដោយច្បាប់ និងមានសិទ្ធិនៅក្នុងការរស់រានមានជីវិត ប៉ុន្តែគ្មានសិទ្ធិសេរីភាពនៅក្នុងការដើរហើរទេ។ ពោលគឺសិទ្ធិមួយចំនួនធំត្រូវបានហាមឃាត់ ដូចជា សិទ្ធិនៅក្នុងការធ្វើអាជីវកម្ម សិទ្ធិក្នុងការបញ្ចេញមតិជាដើម ។

ជនជាប់ឃុំត្រូវទទួលរ៉ាប់រងនូវទង្វើរដែលខ្លួនបានប្រព្រឹត្តហើយល្មើសនិងច្បាប់ និងត្រូវអនុវត្តទោសរបស់ខ្លួនស្របទៅតាមការសម្រេចរបស់តុលាការដែលបានកំណត់។ ទោះបីជាសិទ្ធិរបស់ជនជាប់ឃុំមួយចំនួនត្រូវបានច្បាប់ដកហូតជាបណ្តោះអាសន្នមែន ប៉ុន្តែក្នុងអំឡុងពេលដែលជនជាប់ឃុំស្ថិតនៅក្នុងពន្ធនាគារ ក៏ត្រូវបានទទួលការការពារផ្នែកច្បាប់អំពីសិទ្ធិរបស់ខ្លួនដែរ។ ជាពិសេសស្ត្រីទន់ខ្សោយ ស្ត្រីដែលមានទារកនៅក្នុងផ្ទៃ ជនជាប់ឃុំដែលមានអាយុច្រើន ឬមានសុខភាពទន់ខ្សោយ ឬមានជម្ងឺប្រចាំកាយជាដើម សុទ្ធតែទ្រូវទទួលបានការយកចិត្តទុកដាក់។ ក្នុងនេះបើច្បាប់មិនបានការពារសិទ្ធិទៅលើជនជាប់ឃុំទាំងនោះទេបុគ្គលទាំងនោះអាចងាយប្រឈមនិងការរំលោភបំពានសិទ្ធិ និងការរើសអើងសិទ្ធិយ៉ាងធ្ងន់ធ្ងរក្នុងអំឡុងពេលជាប់ឃុំ។ សម្រាប់យន្តការក្នុងការលើកកម្ពស់ចំពោះសិទ្ធជនជាប់ឃុំរួមមាន ការគ្រប់គ្រងសំណុំរឿងជនជាប់ឃុំ ការបែងចែកជនជាប់ឃុំតាមប្រភេទ ទីកកន្លែងសម្រាប់ជនជាប់ឃុំស្នាក់នៅ អនាម័យប្រចាំកាយ ការស្លៀកពាក់ និងការដេក ម្ហូបអាហារ ការហាត់ប្រាណ និងលេងកីឡា និងសេវាថែទាំសុខភាព។

សរុបជារួមមកចំពោះសិទ្ធិរបស់ជនជាប់ឃុំ ជាផ្នែកមួយដែលសំខាន់ របស់ជនដែលត្រូវបានតុលាការចេញសេចក្តីសម្រេចផ្តន្ទាទោសជាប់ពន្ធនាគារជាស្ថាពរ និងជនដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ជនជាប់ឃុំទាំងអស់គឺមានសិទ្ធិទទួលបានការការពារសិទ្ធិមនុស្សគ្រប់កាលៈទេស និង គ្រប់ពេលវេលាដោយមិនប្រកាន់ភេទ ពណ៌សម្បុល សាសនា ភាសា ជាតិសាសន៍ និងនិន្នាការនយោបាយអ្វីឡើង បើសិនពុំមានច្បាប់ការពារទៅលើជនទាំងនោះទេ ពួកគេទាំងនោះអាចនិងត្រូវប្រឈមមុខខ្លាំងនិងការរំលោភបំពានសិទ្ធិមនុស្សខ្លាំងដូចនៅសម័យកម្ពុជាប្រជាធិបតេយ្យនោះជាដើម ដែលមានការរំលោភបំពានសិទ្ធិមនុស្ស និងសិទ្ធិជនជាប់ឃុំយ៉ាងធ្ងន់ធ្ងរ ដោយមិនមានច្បាប់ ឬអង្គការណាមួយអាចជួយការពារបានឡើយ ក្រោយពីបានដួលរលំនូវរបបនោះ ច្បាប់កម្ពុជានាសម័យក្រោយៗបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះសិទ្ធិមនុស្ស សិទ្ធិមនុស្សនេះផងដែលត្រូវបានទទួលការគាំពារទាំងមជ្ឈដ្ឋានជាតិ និងអន្តរជាតិ។ យើងក្រឡេកមកមើលជន

ជាប់ឃុំវិញ មិនថាជនដែលត្រូវបានតុលាការសម្រេចឃុំខ្លួនស្ថាពរ ឬជនដែលជាប់ឃុំខ្លួនបណ្ដោះអាសន្ននោះទេ គឺសុទ្ធតែទទួលបានការការពារសិទ្ធិមនុស្សគ្រប់ៗគ្នា។ ចំពោះជនជាប់ឃុំជាស្ត្រី និងអនីតិជនវិញច្បាប់ក៏បានចែកដោយយកចិត្តទុកដាក់ផងដែរ ដើម្បីការពារ និងលើកកំពស់ដល់ជនជាប់ឃុំជាស្ត្រី និងជនជាប់ឃុំជាអនីតិជន។ បើក្នុងករណីដែលមានការរំលោភបំពានទៅលើជនជាប់ឃុំណាមួយ ជននោះមានសិទ្ធិប្ដឹងទៅប្រធានពន្ធនាគារបាន ដើម្បីការពារសិទ្ធិរបស់ពួកគេ។ យ៉ាងណាមិញដើម្បីអោយការការពារសិទ្ធិរបស់ជនជាប់ឃុំអោយកាន់តែមានប្រសិទ្ធិភាពល្អ ត្រូវតែមានការចូលរួមពីសំណាក់អង្គភាពដែលពាក់ព័ន្ធ ដូចជាក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងអង្គការសិទ្ធិមនុស្ស ជាដើម ដើម្បីការពារសិទ្ធិជនជាប់ឃុំ និងទទួលបានការលើកកម្ពស់ដល់សិទ្ធិរបស់ពួកគេ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានសិក្សា ស្រាវជ្រាវទៅលើប្រធានបទសិទ្ធិជនជាប់ឃុំនៅកម្ពុជា ទោះបីជាមានការលំបាកបន្តិចក៏ដោយតែវាក៏បានធ្វើអោយយើងខ្ញុំដែលជាអ្នកស្រាវជ្រាវ បានយល់ដឹងកាន់តែច្បាស់ពីសិទ្ធិទាំងឡាយដែលនិងត្រូវយកមកអនុវត្តចំពោះជនជាប់ឃុំ និងបានផ្តល់នូវចំណេះដឹងជាច្រើនអំពីផ្នែកមួយនេះ ព្រោះជាផ្នែកមួយដែលបានផ្សារភ្ជាប់ពីការអនុវត្តក្នុងសង្គម ស្របទៅនិងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ទៅលើសិទ្ធជនដែលត្រូវបានជាប់ឃុំ។ និងជាផ្នែកមួយយ៉ាងសំខាន់ ដល់ក្រុមនិស្សិតដែលកំពុងសិក្សាផ្នែកនិតិសាស្ត្រ ក៏ដូចជាអ្នកប្រកបវិជ្ជាជីវៈច្បាប់ ពីព្រោះប្រធានបទនេះបានផ្តោតសំខាន់ទៅលើ ជនដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួន តាមដីការរបស់តុលាការ និងសិទ្ធិរបស់ពួកគេនៅពេលដែលជននោះត្រូវបានជាប់ឃុំក្នុងករណីណាមួយដែលខុសនិងច្បាប់។ ហើយផ្នែកទាំងនោះមានដូចជាការការពារសិទ្ធិជនជាប់ឃុំក្នុងច្បាប់ជាតិ សិទ្ធិទទួលបានការថែទាំសុខភាព សិទ្ធិរួចផុតពីការធ្វើទារុណកម្ម និងជាពិសេសនៅពេលដែលទទួលបាននូវភាពអយុត្តិធម៌ ជនជាប់ឃុំទាំងនោះមានសិទ្ធិប្តឹងឧទ្ធរណ៍ ដោយស្របទៅតាមបញ្ញត្តិនៃច្បាប់ ដែលបានចែងទុកក្នុងគោលបំណង់ការពារការបំពានសិទ្ធណាមួយ ទៅលើជនទាំងនោះ។

ប៉ុន្តែបន្ទាប់ពីការសិក្សាស្រាវជ្រាវទាក់ទងក្នុងប្រធានបទនេះយើងឃើញថា ការអនុវត្តសិទ្ធិរបស់ជនជាប់ឃុំជាក់ស្តែងនៅកម្ពុជាមិនទាន់បានពេញលេញនោះទេ ពោលការអនុវត្តគឺមានការខ្វះចន្លោះដូចជា ការអនុវត្តផ្តល់សិទ្ធិដល់ទណ្ឌិចំពោះការជួបក្រុមគ្រួសារ ឬមិត្តភក្ក ការទទួលបានការព្យាបាលនៅពេលមានជម្ងឺ ការប្រើប្រាស់ថ្នាំសង្កូវដែលក្រុមគ្រួសារបានផ្ញើអោយក្នុងពេលជាប់ឃុំ ជាដើម ដែលការអនុវត្តមិនទាន់បានពេញលេញនៅឡើយទេ ដែលធ្វើអោយប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់។

ដូច្នេះដើម្បីទប់ស្កាត់ការរលំលោភបំពានសិទ្ធិរបស់ជនជាប់ឃុំ យើងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវយល់ថា កម្ពុជាគួរតែមានវិធានការលើកតម្កើនសិទ្ធិជនជាប់ឃុំអោយបានល្អជាងនោះ ព្រោះដើម្បីធានាថាកម្ពុជាបានអនុវត្ត និងធានាដល់សិទ្ធិមនុស្ស គ្រប់ទីកន្លែង និងត្រូវបានការពារដោយច្បាប់របស់ជាតិ និងអន្តរជាតិផងដែរ។ និងជួយពង្រឹងការគោពសិទ្ធិមនុស្សអោយបានរឹងមាំ ។

# ឯកសារយោង

# ឯកសារយោង

- **ឯកសារគតិយុត្ត**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីពន្ធនាគារ
- ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០/០៨/២០០៧
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន
- ច្បាប់លក្ខន្តិកៈទីក្រុងរួមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល

- **ឯកសារផ្សេងៗ និងសៀវភៅច្បាប់**

- សៀវភៅក្បួននីតិវិធីព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌
- អនុសញ្ញាស្តីពីសិទ្ធិកុមារ
- យុទ្ធសាស្រ្តគ្រប់គ្រងពន្ធនាគារតាមគោលការណ៍សិទ្ធមនុស្ស
- វិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននៃលសាន់ម៉ានិដឺឡា) ចុះនៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៥ (លេខA /RES / ៧០ / ១៧៥)
- បទប្បញ្ញាតិជាបទដ្ឋានអប្បរមាសម្រាប់គ្រប់គ្រងអ្នកទោស

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា



## ជំពូកទី ៣
## អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១.-**

*ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។*

*ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។*

**មាត្រា ៣២.-**

*ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។*

*ទោសប្រហារជីវិត មិនត្រូវឲ្យមានឡើយ ។*

**មាត្រា ៣៣.-**

*ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឲ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។*

*ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេស ត្រូវបានរដ្ឋគាំពារ ។*

*ការទទួលសញ្ជាតិខ្មែរ ត្រូវកំណត់ក្នុងច្បាប់ ។*

**មាត្រា ៣៤.- ថ្មី**

*ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឲ្យគេបោះឆ្នោត ។*

*ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។*

*ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។*

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៣៥.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

**មាត្រា ៣៦.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃ ដែលបាន មកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការ ធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែល មានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព នឹងមាន កំណត់ក្នុងច្បាប់ ។

**មាត្រា ៣៧.-**

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវ យកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨.-**

ច្បាប់ការពារមិនឲ្យមានការរំលោភបំពានលើរូបរាង កាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ ។ អ្នកដែលដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្ដឹងបរិហារ ប្ដឹងតវ៉ា ឬប្ដឹងទារសំណងជួសជុលការខូចខាត ដែលបណ្ដាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្ដឹងតវ៉ា និងសំណងជួសជុលការខូចខាត ជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០.-**

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋ ត្រូវបានគោរព ។ ប្រជាពលរដ្ឋខ្មែរ អាចចេញទៅតាំងទីលំនៅនៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនឲ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទ ត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារ វត្ថុ និងលើរូបបុគ្គល ត្រូវធ្វើឲ្យស្របនឹងបញ្ញត្តិច្បាប់ ។

**មាត្រា ៤១.-**

ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤២.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្ដាប់ធ្នាប់សង្គម ។

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌ ដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤.-**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ស្ថិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិ អំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី ត្រូវហាមឃាត់ ។

បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ។

**មាត្រា ៤៦.-**

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឲ្យមានការបញ្ឈប់នារីពីការងារដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូនដោយទទួលប្រាក់បៀវត្ស និងដោយមាន

ការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឲ្យនារី ជាពិសេសនារីនៅជនបទ ដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឲ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

**មាត្រា ៤៧.-**

មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ ។

**មាត្រា ៤៨.-**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេស សិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឲ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឲ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

**មាត្រា ៤៩**.-

ប្រជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានភាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

ភាតព្វកិច្ចការពារមាតុភូមិ ត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៥០**.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិស្របច្បាប់របស់ឯកជន ។

# ឧបសម្ព័ន្ធទី២

# ច្បាប់
# ស្តីពី
# ពន្ធនាគារ

YAUME DU CAMBODGE

## ជំពូកទី ៧
## ការអប់រំ កែប្រែ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការស្តារនីតិសម្បទាទណ្ឌិត

**មាត្រា ៦៦.-**

ទណ្ឌិតត្រូវបានចាត់តាំងឲ្យចូលរួមក្នុងកម្មវិធីអប់រំច្បាប់និងសីលធម៌សង្គម ដែលបានរៀបចំឡើងនៅតាមពន្ធនាគារ ។

**មាត្រា ៦៧.-**

ទណ្ឌិតត្រូវបានផ្តល់មធ្យោបាយដើម្បីចូលរួមកម្មវិធីសិក្សាចំណេះទូទៅ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ។

កម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ត្រូវបានធ្វើសមាហរណកម្មជាមួយប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ជាតិ ។

ទណ្ឌិតជាអនីតិជនត្រូវបានយកចិត្តទុកដាក់ដោយឡែក ទាក់ទងនឹងតម្រូវការសិក្សាអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការស្តារនីតិសម្បទា និងសមាហរណកម្មដោយសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវសហការជាមួយក្រសួងមហាផ្ទៃរៀបចំកម្មវិធី និងដំណើរការអនុវត្តកម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិតនៅក្នុងពន្ធនាគារ ។

**មាត្រា ៦៨.-**

ទណ្ឌិតដែលមានកម្រិតសន្តិសុខទាប ហើយត្រូវបានវាយតម្លៃថា មានសមត្ថភាពកាយសម្បទា ត្រូវបានចាត់តាំងឲ្យធ្វើការងារពលកម្មប្រចាំថ្ងៃនៅក្នុងពន្ធនាគារ ឬការងារជាអត្ថប្រយោជន៍សម្រាប់សហគមន៍ និងផលប្រយោជន៍សាធារណៈ ឬចាត់តាំងឲ្យចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ។

**មាត្រា ៦៩.-**

កម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវបានរៀបចំឡើងនៅតាមពន្ធនាគារនីមួយៗ ដើម្បីផ្តល់ឱកាសឲ្យទណ្ឌិតមានសមត្ថភាពប្រកបមុខរបរចិញ្ចឹមជីវិត នៅពេលធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ ។

**មាត្រា ៧០.-**

ទណ្ឌិតដែលចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវបានបំពាក់សម្ភារៈ និងឧបករណ៍ការពារសុវត្ថិភាពការងារ ក្នុងពេលបំពេញការងារ ។

**មាត្រា ៧១.-**

បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ មានសិទ្ធិចុះកិច្ចសន្យាជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គល ឬអង្គការជាតិ អន្តរជាតិដើម្បីបង្កើតការងារ

សម្រាប់កម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ និងមានសិទ្ធិចុះកិច្ចសន្យាលក់ផលិតផល ឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ។

**មាត្រា ៧២.-**

ការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នីតិវិធីគ្រប់គ្រងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧៣.-**

មុនផុតរយៈពេលទទួលរងទោស ៦ (ប្រាំមួយ) ខែ ទណ្ឌិតត្រូវបានទទួលកម្មវិធីសមាហរណកម្មដែលរៀបចំដោយពន្ធនាគារ ដើម្បីឲ្យគេក្លាយជាពលរដ្ឋអាចរស់នៅក្នុងសង្គមជាតិនិងសហគមន៍មូលដ្ឋានបានល្អ ។

## ជំពូកទី ៨
## ការបន្ធូរបន្ថយទោស ការលើកលែងទោស និង ការដោះលែងទណ្ឌិត

**មាត្រា ៧៤.-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការមួយដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅក្នុងពន្ធនាគារដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការនេះ ត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ តាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ យ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម ៖

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាប្រធាន
- តំណាងអង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត ជាអនុប្រធាន
- ប្រធានក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគាររាជធានី ខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍
- អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកអប់រំកែប្រែ ជាសមាជិក
- អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកប្រតិបត្តិ ជាសមាជិក



គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបង្កើតគណៈកម្មការមួយ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅតាមមណ្ឌលអប់រំកែប្រែដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការនេះត្រូវធ្វើបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ យ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកពន្ធនាគារ | ជាប្រធាន |
| - តំណាងអង្គការអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ចលើមណ្ឌលអប់រំ កែប្រែសាមី | ជាអនុប្រធាន |
| - ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - ប្រធាននាយកដ្ឋានអប់រំកែប្រែ | ជាសមាជិក |
| - ប្រធាននាយកដ្ឋានប្រតិបត្តិ | ជាសមាជិក |
| - ប្រធានក្រុមការងារប្រឡងប្រណាំងនៃមណ្ឌលអប់រំកែប្រែនីមួយៗ | ជាសមាជិក |

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧៥.-**

រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ដែលបានផ្ញើមកពីគណៈកម្មការរាជធានី ខេត្ត និងពីគណៈកម្មការក្រសួងមហាផ្ទៃ ។ ក្រោយពីបានពិនិត្យវាយតម្លៃរួចហើយ គណៈកម្មការនេះត្រូវធ្វើបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឲ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកពន្ធនាគារ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | ជាអនុប្រធាន |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ចំនួន ០១ រូប | ជាសមាជិក |
| - ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| - តំណាងក្រសួងយុត្តិធម៌ ចំនួន០១ រូប | ជាសមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ | ជាសមាជិក |
| - ប្រធាននាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានពន្ធនាគារ ចំនួន ០២ រូប | ជាសមាជិក |

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៧៦.-

លក្ខណសម្បត្តិ និងចំណាត់ថ្នាក់ប្រឡងប្រណាំង សំដៅជំរុញលើកទឹកចិត្តដល់ទណ្ឌិតម្នាក់ៗឲ្យខិតខំកសាងកែប្រែគំនិតមារយាទ ក្លាយជាពលរដ្ឋល្អដើម្បីធ្វើសមាហរណកម្មបញ្ចូលទៅក្នុងសង្គមជាតិវិញបាននៅពេលអនាគត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែមិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួន សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅ គណៈកម្មការថ្នាក់ជាតិ ដូចមានចែងក្នុងមាត្រា ៧៥ នៃច្បាប់នេះ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ ។

## មាត្រា ៧៧.-

ក្នុងករណីចាំបាច់ ប្រមុខរាជរដ្ឋាភិបាលមានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឲ្យទណ្ឌិតនៅពេលណាក៏បាន ។

## មាត្រា ៧៨.-

ពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោសនិងការលើកលែងទោសត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ROYAUME DU CAMBODGE

**មាត្រា ៧៩.-**

គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬ ច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន ។

លក្ខខណ្ឌ និងបែបបទនៃការអនុវត្តការដោះលែងដោយមានលក្ខខណ្ឌក្នុងច្បាប់នេះ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨០.-**

ប្រធានពន្ធនាគារត្រូវធ្វើការដោះលែងជនជាប់ឃុំ ក្រោយពីបានទទួលលិខិតសម្រេចពីអាជ្ញាធរតុលាការ ។ ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឲ្យមានសេរីភាពវិញ នៅមុនថ្ងៃឈប់សម្រាកនោះ ស្របតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

# ឧបសម្ព័ន្ធទី៣

រដ្ឋសភា
ចូល
លេខ
ថ្ងៃទី ឆ្នាំ ម៉ោង
បញ្ជូនទៅ

# ច្បាប់

# ស្តីពី

# យុត្តិធម៌អនីតិជន

ROYAUME DU CAMBODGE

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ជំពូកទី ១៣
## ការបង្កើត និងសមត្ថកិច្ចគ្រប់គ្រងមណ្ឌលយុវនីតិសម្បទា

### មាត្រា ៧៦.- ការបង្កើតមណ្ឌលយុវនីតិសម្បទា

ត្រូវបង្កើតឲ្យមានមណ្ឌលយុវនីតិសម្បទានៅតាមរាជធានី ខេត្ត សម្រាប់គ្រប់គ្រងអនីតិជន ។ មណ្ឌលនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ៧៧.- ការបែងចែកការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

ការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបែងចែកជា ៣ (បី) ផ្នែកដាច់ដោយឡែកពីគ្នា ៖

- ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន
- ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា
- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម ។

របៀបនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាដែលត្រូវជាប់ឃុំ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### មាត្រា ៧៨.- បញ្ជីឈ្មោះអនីតិជន

គ្រប់មណ្ឌលយុវនីតិសម្បទា ត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជន ព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាឲ្យមានសុវត្ថិភាព ។

បញ្ជី និងនីតិវិធីដោយឡែកនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## ជំពូកទី ១៤
## វិធានការទាក់ទងនឹងការឃុំខ្លួនអនីតិជន

### មាត្រា ៧៩.- គោលបំណងនៃការឃុំខ្លួន

ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្ដារនីតិសម្បទា ជាអាទិ៍ ការបណ្ដុះបណ្ដាលការពាពាល ការថែទាំ ការការពារ ការអប់រំ និងផ្ដល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយទៅជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ ។

មន្ត្រីមណ្ឌលយុវនីតិសម្បទាដែលទទួលបន្ទុកគ្រប់គ្រងអនីតិជន ត្រូវទទួលការបណ្ដុះបណ្ដាលអំពីចិត្តសាស្ត្រ សុខុមាលភាព បទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងកុមារ និងវិធានការសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

### មាត្រា ៨០.- សិទ្ធិជាមូលដ្ឋានរបស់អនីតិជនដែលជាប់ឃុំ

អនីតិជនដែលជាប់ឃុំទាំងអស់ត្រូវទទួលបានសិទ្ធិជាមូលដ្ឋានដូចតទៅ ៖

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឲ្យនៅឯកា ការដាក់កំហិត ឬបដិសេធមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយកំណើអាហារ និងពលកម្មដោយបង្ខំ
- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្ដីថ្លៃថ្នូររបស់អនីតិជន
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច
- សិទ្ធិផ្ដល់ដំណឹងអំពីកាឃុំខ្លួន ការផ្ទេរ ការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជំងឺ ឬរបួស និងផ្ដល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្ដិ
- សិទ្ធិទទួលបានយន្តការបណ្ដឹងប្រកបដោយប្រសិទ្ធភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន
- សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន ។

### មាត្រា ៨១.- សេវាសម្រាប់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលយុវនីតិសម្បទាទាំងអស់ ត្រូវផ្ដល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដូចខាងក្រោមនេះ ៖

- ការពារ ថែទាំ និងផ្ដល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល
- សិក្សាអប់រំ បណ្ដុះបណ្ដាលវិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាកពីការងារ

- សុខភាពផ្លូវកាយនិងផ្លូវចិត្តសមស្រប
- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យ ។ ត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងអនីតិជន ជាប់ឃុំនៃព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត
- សេវាផ្សេងទៀតដែលលើកស្ទួយសុខភាពនិងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឲ្យមានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឲ្យមានអាកប្បកិរិយា និងជំនាញដែលនឹងជួយអនីតិជនក្នុងការអភិវឌ្ឍសក្ដានុពលរបស់ខ្លួនក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងជួយឲ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញបន្ទាប់ពីបានដោះលែង ។

## មាត្រា ៨២._ ការរក្សាអនីតិជន

ត្រូវរក្សាអនីតិជននៅក្នុងមណ្ឌលឃុំនីតិសម្បទាដូចខាងក្រោមនេះ ៖

- អនីតិជនត្រូវដាក់ដោយឡែកពីនីតិជន
- នៅក្នុងអគារដាច់ដោយឡែកទៅតាមភេទផ្សេងគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន ។ អនីតិជនភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា
- នៅក្នុងអគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកសម្រាប់អនីតិជនដែលមានជំងឺឆ្លង ។

ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងពេលបាន និងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលឃុំនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមណ្ឌលឃុំនីតិសម្បទាបន្តរហូតដល់អាយុក្រោម ២៤ (ម្ភៃបួន) ឆ្នាំ។ នៅពេលទណ្ឌិតឈានចូលអាយុគ្រប់ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជន ។

បែបបទនិងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## មាត្រា ៨៣._ ចំណាត់ថ្នាក់សន្តិសុខនៅក្នុងមណ្ឌលឃុំនីតិសម្បទា

ចំណាត់ថ្នាក់សន្តិសុខសម្រាប់អនីតិជននៅក្នុងមណ្ឌលឃុំនីតិសម្បទា ត្រូវស្ថិតក្នុងចំណាត់ថ្នាក់ទាបបំផុត និងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៨៤.- ភ្នាក់ងារក្នុងមណ្ឌលយុវនីតិសម្បទា

ភ្នាក់ងារទាំងអស់ដែលធ្វើការជាមួយអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទា ជាអាទិ៍ មន្ត្រីមណ្ឌលយុវនីតិសម្បទា ភ្នាក់ងារសង្គមកិច្ច-អ្នកជំនាញផ្នែកអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អ្នកពិគ្រោះយោបល់ និងបំណិនជីវិត និងអ្នកចិត្តសាស្ត្រ ឬគ្រូពេទ្យព្យាបាលជំងឺផ្លូវចិត្ត ត្រូវតែទទួលបាននូវការបណ្តុះ បណ្តាលត្រឹមត្រូវអំពីចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ និងការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

មន្ត្រី ឬបុគ្គលិកមណ្ឌលយុវនីតិសម្បទា មិនត្រូវប្រើ ឬបញ្ជាជនដែលកំពុងជាប់ឃុំឲ្យដាក់វិន័យទៅលើអនីតិជន ឬធ្វើកិច្ចការជំនួសខ្លួនឡើយ ។

## មាត្រា ៨៥.- ការធ្វើអធិការកិច្ចមណ្ឌលយុវនីតិសម្បទា

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចជាប្រចាំលើមណ្ឌលយុវនីតិសម្បទា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងធានាថាលក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួនត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមាន ។

យន្តការបង្ការថ្នាក់ជាតិ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់មានសិទ្ធិធ្វើទស្សនកិច្ចមណ្ឌលយុវនីតិសម្បទានានាបានគ្រប់ពេលវេលា ។

# ឧបសម្ព័ន្ធទី៤

ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

## ស្តីពី

នស/រកត/០១២១/០៣០

## ការបន្ធូរបន្ថយទោស និងការលើកលែងទោស

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ត្រាស់បង្គាប់
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ព្រះរាជក្រឹត្យនេះកំណត់អំពីពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ក្នុងគោលបំណងដើម្បីធ្វើសមាហរណកម្មទណ្ឌិតនោះឱ្យចូលទៅរួមរស់ក្នុងសង្គមវិញ ឬក្នុងគោលបំណងផ្នែកមនុស្សធម៌។

**មាត្រា២.-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់ទៅលើការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិតទាំងអស់ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា និងចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយតុលាការនៃជនបរទេស ប៉ុន្តែ ត្រូវបានបញ្ជូនមកឱ្យអនុវត្តទោសនៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមការព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងជនបរទេសនោះ។

ព្រះរាជក្រឹត្យនេះមិនអនុវត្តចំពោះការលើកលែងទោសឱ្យទណ្ឌិត ដូចមានបញ្ញត្តិក្នុងមាត្រា ៧៧ នៃច្បាប់ស្តីពីពន្ធនាគារឡើយ។

## ជំពូកទី២
## ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោស និងការលើកលែងទោស

**មាត្រា៣.-**

ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ត្រូវកំណត់ ៥ (ប្រាំ) ដង ក្នុងមួយឆ្នាំ ដូចតទៅ៖

១-ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍។

២-ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។

៣-ពិធីបុណ្យវិសាខបូជា។

៤-ពិធីបុណ្យឯករាជ្យជាតិ។

៥-ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើផងដែរក្នុងពិធីបុណ្យ ឬព្រឹត្តិការណ៍ធំៗរបស់ជាតិ។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើសម្រាប់ពិធីបុណ្យនីមួយៗខាងលើដាច់ដោយឡែកពីគ្នា ឬរួមគ្នា។

## ជំពូកទី៣
## លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស
### ផ្នែកទី១
### លក្ខខណ្ឌទូទៅនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

ក[illegible]លបានការបន្ធូរបន្ថយទោស និងការលើកលែងទោស មិនមែនជាសិទ្ធិរបស់ទណ្ឌិតនោះទេ [illegible]លបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងព្រះរាជក្រឹត្យនេះ អាចទទួលបានការ[illegible] ជាការបន្ធូរបន្ថយទោស ឬជាការលើកលែងទោសបាន។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តបានតែចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពរប៉ុណ្ណោះ។

មាត្រា៥.-

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តចំពោះទណ្ឌិតដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ភ្ញាក់រលឹកខិតខំកែប្រែគំនិតមារយាទឱ្យក្លាយជាពលរដ្ឋសុចរិត ដើម្បីធ្វើសមាហរណកម្មចូលរួមរស់ក្នុងសង្គមវិញ
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អដល់ទណ្ឌិត និងជនជាប់ឃុំដទៃទៀត
- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀងទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្ម
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមសេចក្តីណែនាំផ្សេងទៀតរបស់ពន្ធនាគារ។

ប្រធានពន្ធនាគារត្រូវធ្វើការវាយតម្លៃ និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌខាងលើរបស់ទណ្ឌិតដែលត្រូវបញ្ចូលឈ្មោះក្នុងបញ្ជីទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត។

មាត្រា៦.-

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តផងដែរក្នុងហេតុផលមនុស្សធម៌ចំពោះទណ្ឌិតដែលមានវ័យចាស់ជរា ជាស្ត្រីមានគភ៌ ឬមានជំងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ វិបល្លាសស្មារតី ឬពិការភាព ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យដែលទទួលស្គាល់ដោយក្រសួងមានសមត្ថកិច្ច។

ប្រធានពន្ធនាគារត្រូវធ្វើការបញ្ជាក់អំពីការបំពេញលក្ខខណ្ឌតាមស្ថានភាពនីមួយៗរបស់ទណ្ឌិតដូចមានចែងក្នុងកថាខណ្ឌខាងលើ ដើម្បីរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។

## ផ្នែកទី២
## លក្ខខណ្ឌដោយឡែកនៃការបន្ធូរបន្ថយទោស

មាត្រា៧.-

ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា៥ នៃព្រះរាជក្រឹត្យនេះ អាចទទួលការបន្ធូរបន្ថយទោសបាន លុះត្រាតែទណ្ឌិតនោះបានទទួលរងទោស ១/៣ (មួយភាគបី) នៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់។

ចំពោះទោសដាក់ពន្ធនាគារមួយជីវិត ទណ្ឌិតត្រូវទទួលរងទោស ១០ (ដប់) ឆ្នាំជាមុនសិន។

មាត្រា៨.-

រយៈពេលនៃការបន្ធូរបន្ថយទោសត្រូវកំណត់ ដូចខាងក្រោម៖

១-ទោសដាក់ពន្ធនាគារកំណត់ពី ១ (មួយ) ឆ្នាំ ដល់ក្រោម ៥ (ប្រាំ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៣ (បី) ខែ។

ទោស និងត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ ពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស យ៉ាងយឺតបំផុត ៣០ (សាមសិប)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យនេះ។

គំរូបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវកំណត់ដោយគណៈកម្មការថ្នាក់ជាតិ។

**មាត្រា១២.-**

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែ មិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួន សាមីខ្លួន ឬអ្នកតំណាងស្របច្បាប់មានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការថ្នាក់ជាតិ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ។ ពាក្យបណ្តឹងតវ៉ានេះ ត្រូវដាក់នៅគណៈកម្មការថ្នាក់ជាតិ ដោយផ្ទាល់ ឬតាមរយៈប្រធានពន្ធនាគារ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ានេះ ប្រធានពន្ធនាគារត្រូវបញ្ជូនពាក្យប្តឹងនេះ មកគណៈកម្មការថ្នាក់ជាតិ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តទោសរបស់ទណ្ឌិតនោះ។

**មាត្រា១៣.-**

គណៈកម្មការថ្នាក់ជាតិ ត្រូវប្រជុំពិនិត្យ និងវាយតម្លៃលើបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស និងរៀបចំបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៥
## ការអនុវត្តព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស

**មាត្រា១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវរៀបចំសំណៅចែកផ្សាយជូនក្រសួងយុត្តិធម៌ដើម្បីចាត់ចែងអនុវត្ត ក្រោយពីបានទទួលព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស។

**មាត្រា១៥.-**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់បញ្ជូនព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស ទៅព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច ដើម្បីអនុវត្ត។

**មាត្រា១៦.-**

ចំពោះទណ្ឌិតដែលត្រូវបានលើកលែងទោសដោយព្រះរាជក្រឹត្យ នឹងត្រូវដោះលែងឱ្យមាន[illegible]ភ្លាម ដោយប្រធានពន្ធនាគារ បន្ទាប់ពីទទួលបានដីកាបង្គាប់ឱ្យដោះលែងទណ្ឌិតរបស់[illegible]អាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច។

[illegible]ដែលត្រូវបានបន្ធូរបន្ថយទោសដោយព្រះរាជក្រឹត្យ លើកលែងឱ្យទណ្ឌិតនោះរួចផុតពីការអនុវត្ត[illegible]ប្រាប់រយៈពេលដែលត្រូវបានបន្ធូរបន្ថយ។ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង

រាជធានី ខេត្តដែលមានសមត្ថកិច្ច និងប្រធានពន្ធនាគារ ត្រូវធ្វើការប្រកាសផ្សព្វផ្សាយព្រះរាជក្រឹត្យបន្ធូរបន្ថយទោស ដល់ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោស។

**មាត្រា១៧.-**

ការបន្ធូរបន្ថយទោស និងការលើកលែងទោស មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនឹងព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការបន្ធូរបន្ថយទោស និងលើកលែងទោសនោះ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៨.-**

ក្រឹត្យលេខ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ អង្គារ ១៤រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២១

នស/រកត.០១២១.០៣២

**បានប្រឡាប់ព្រះរាជលញ្ឆករហើយ**

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**